B/493-6073

# សង្ឃករណីយកិច្ច

គម្រូកិច្ចការដែលសង្ឃគប្បីធ្វើតាម

គម្រូសំបុត្រ—កត់ហេតុ—ក្រាំងបញ្ជី—របៀបកាន់សៀវភៅបញ្ជី
វិធីក្រើនកឋិន - អបលោកន៍កឋិន - វេរវត្ត - បវារណារូបិយៈ
បញ្ចុះខណ្ឌសីមា - ប្រកាសមាឃបូជា - វិសាខបូជា

[illegible]

www.elibraryofcambodia.org

B-50
D-240
N°-461
3/2

បោះពុម្ពលើកទី ២

ព.ស. ២៥១២ គ.ស. ១៩៦៨

តម្លៃ ៣២ រៀល

294:
307596
ROE

National Library of Cambodia
00013240

www.elibraryofcambodia.org

24

294.3

# សង្ឃករណីយកិច្ច

គម្រូលិខិតផ្លូវពុទ្ធចក្រទាក់ទងនឹងអាណាចក្រ ព្រមទាំងពិធីបុណ្យផ្សេង ៗ


ភិក្ខុ មាស-វឿង (ធម្មធរោ)

វត្តជោតនារាម (បឹងកុក) ក្រុងកំពង់ចាម

សញ្ញាប័ត្របឋមសិក្សាជាន់ខ្ពស់ (ឧបមបារាំង)

អតីតសាស្ត្រាចារ្យ សាលាបារាំង-ខ្មែរ

អតីតចៅហ្វាយស្រុក បច្ចុប្បន្ននិស្សិតបរិយត្តិ


និពន្ធ

ក្នុង ព.ស. ២៤៩១ គ.ស. ១៩៤៨

www.elibraryofcambodia.org


ការផ្សាយរបស់

បណ្ណាគារ **សុមនសុវត្ថិ** លេខ ៤២

វិថីសម្តេចកែវ-ជា ក្រុងភ្នំពេញ

បោះពុម្ពគ្រាទីពីរ ជាគម្រប់ ៤០០០ ច្បាប់

ព.ស. ២៥១២ គ.ស. ១៩៦៨


រក្សាសិទ្ធិ

www.elibraryofcambodia.org

# បញ្ជីមាតិកា

វគ្គទី ១ បឋមបរិយាយ ការគ្រប់គ្រងនិងការកសាងវត្ត សម័យ បច្ចុប្បន្ននិងសម័យព្រេងនាយ ......... ទំព័រ ១-២

វគ្គទី ២ កិច្ចសមាគម គោលបំណងរបស់សមាគម សមាគមជំនួញ ប្រៀបធៀបនឹងសមាគមវត្ត .......... ទំព័រ ៣-៦

វគ្គទី ៣ ការរៀបចំទីសេនាសនៈក្នុងវត្ត ទៅតាមរបៀបផែនទី ដែលគូរទុកជាមុន, របៀបកិច្ចការក្នុងក្រុមចំពោះវត្តធំ ៗ ដែលមានក្រុម ............... ទំព័រ ៧-១៣

វគ្គទី ៤ សង្ឃកិច្ច របៀបគេនិមន្តឲ្យបួលខ្លួន ..... ទំព័រ ១៤-១៦

វគ្គទី ៥ ចំនួនសៀវភៅវត្ត, សៀវភៅផ្សេង ៗ ដែលវត្តត្រូវតែ បង្កើតឲ្យមានខានមិនបាន, របៀបកាន់កាប់-របៀបចាប់ ប្រើនិងរបៀបបញ្ចប់សៀវភៅ, មុខងារគ្រូសូត្រស្តាំ-ឆ្វេង ចៅអធិការ, របៀបបណ្ណាល័យ, ប្រជុំទាយកា-សង្ឃដីកា, តម្រូវបញ្ជីប្រាក់ចំណូល - ចំណាយ, ប្រវត្តិរូប, តម្រូវលិខិត គោចរ, តម្រូវបញ្ជីផ្សេង ៗ ........ ទំព័រ ១៧-៣០

វគ្គទី ៦ តម្រូវសំបុត្រមេគណ- អនុគណ- ចៅអធិការ- អាចារ្យវត្ត សរសេរជូនឆ្លើយទៅមក ក្នុងផ្លូវពុទ្ធចក្រ ឬអាណាចក្រ របៀបកត់ហេតុសួរចម្លើយនិងសំបុត្របក, កត់ហេតុរើស រូបចៅអធិការ, តម្រូវសំបុត្រសុំកសាងវត្ត, ទៀនព្យាបវត្ត ៗ ល ៗ បព្វជិតសរសេរទៅកាន់បព្វជិត, គ្រហស្ថទៅ

www.elibraryofcambodia.org

កាន់បព្វជិត, បព្វជិតទៅកាន់ក្សត្រិយ៍, បព្វជិតទៅកាន់មន្ត្រី, បព្វជិតជាសិស្សទៅកាន់បព្វជិតជាគ្រូ, ប្រគេនធនុះ, ច្បាប់ឈប់, ពាក្យសុំចូលសាលាបាលីរង, ពាក្យសុំប្រឡងចូលសាលាបាលីជាន់ខ្ពស់, បព្វជិតទៅកាន់ញាតិញោម មានមាតាបិតាជាដើម, គ្រូជាមន្ត្រីធំជាង ទៅកាន់សិស្ស ជាមន្ត្រីតូចជាង (គ្រហស្ថ), សិស្សជាមន្ត្រីធំជាង ទៅកាន់គ្រូជាមន្ត្រីតូចជាង (គ្រហស្ថ), គម្រូចុតហ្មាយថ្វាយសម្តេចព្រះសង្ឃរាជ, -ថ្វាយព្រះរាជាជាម្ចាស់ផែនដី, សេចក្តីរំលឹក . . . . ទំព័រ ៣៤—៩១

វគ្គទី ៧ បែបបោះពុម្ព, បែបការ្ទងស្រោមសំបុត្រ, គម្រូកម្មវិធីបុណ្យផ្សេង ៗ : បុណ្យកឋិន, បុណ្យផ្កា, បុណ្យឆ្លងកុដិ; កម្មវិធីដង្ហែព្រះបរមធាតុ, របៀបទទួលមន្ត្រីសង្ឃសក្តិធំនៅវត្ត . . . , ពិធីបញ្ចុះខណ្ឌសីមា, ពិធីបម្រើនព្រះជន្ម, ពិធីប្រោះព្រំកីឡាហានអូឡាំពិច ទំព័រ ៩២- ១២១

វគ្គទី ៨ វិធីក្រើនកឋិន - អបលោកន៍កឋិន - វេរផ្កា, វិធីបវារណារូបិយៈ, វិធីធ្វើកប្បិយៈ, វិធីប្រកាសមាឃបូជា - វិសាខបូជា, បណាមគាថា, នមក្ការគាថា . . . . ទំព័រ ១២២—១៤០

វគ្គទី ៩ ការទិងតំណែងសក្តិព្រះសង្ឃនាយក, ព្រះរាជាគណៈ គណៈមហានិកាយ និង ធម្មយុត្តិ . . . ទំព័រ ១៤១—១៤៣

www.elibraryofcambodia.org

# អារម្ភកថា

បុព្វហេតុដែលកើតជាសៀវភៅនេះឡើង មានពីរយ៉ាងគឺ:

១- ខ្ញុំរលឹកដល់ការប្រជុំសាមគ្គីមិត្តដែលជាសព្រហ្មចារីដូចគ្នាសឹងមានពយនាមខាងក្រោមនេះគឺ :

លោកគ្រូអាចារ្យបន្ទុកាសោ ( រង់-ជេត ) ជាប្រធានក្នុងការប្រជុំ, លោកគ្រូសូត្រ គិម ជ្រៀ១, លោកគ្រូសូត្រ ឈាង-គ្រី១, ភិក្ខុសៀង ១, ជុំ ១, កន ១, គជ ១, នី ១ មើលគម្ពីរវិន័យបិដកនិងអដ្ឋកថាវិន័យ ៗ ការប្រជុំធម្មសន្និបាតបានធ្វើនៅក្នុងនទីបព្វតាភម(*)ឃុំអាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម ក្នុង $\frac{\text{ព.ស. ២៤៩១}}{\text{គ.ស. ១៩៤៩}}$ ៗ

២- ដោយយើងពាងអសន្ថានេះ មានឧបាសក ឃោក១, នៃ១, សុត-សាន ១, ប៉ាន់ ១, មុត ១, ឧបាសិកាដៃ ១ ៗលៗ មានមនោសញ្ចេតនាផុសផុលជ្រះថ្លាឡើង ហើយមានគំនិតគិតផ្តើមកសាងវត្តជោតនាភម(បឹងកុក) ដែលសព្វថ្ងៃកំពុងតែកសាងដោយឆាប់រហ័ស ជាវត្តថ្មីស្ថិតនៅក្បែរមាត់បឹងក្នុបឹងកុក នាក្រុងកំពង់ចាម ដែលអ្នកផងគ្រឿងក្រឡេកមើលតាមវិថីក្រុងទៅ ឃើញត្រដឹមត្រដែតត្រៃសគខ្ពស់បញ្ចេញសម្រស់ដោយកំពូលជហ្វាជងក្តារថ្មី ៗ ហាក់ដូចជារុក្ខជាតិដែលត្រូវទឹកភ្លៀង ចំប្រើនលូត

---

*- ជាទស្សនរបស់ខ្ញុំផ្ទាល់ កាលខ្ញុំនៅជាគ្រហស្ថ, លុះខ្ញុំចេញសាងអភិនេស្ក្រមណ៍ ទើបខ្ញុំព្រមទាំងអតីតគ្រូសាវខ្ញុំមូលគំនិតព្រមព្រៀងរៀបចំទីនេះ វេរទទួលចំពោះសង្ឃ ទុកជាគរុភណ្ឌរបស់វត្តជោះនាភម តម្កល់ជាទីធ្វើសមថកម្មផ្គាខក្នុង $\frac{\text{ព.ស. ២៤៩១}}{\text{គ.ស. ១៩៤៩}}$

www.elibraryofcambodia.org

លាស់ឡើងនៅពេលជាខាងចុងនៃគិម្ហរដូវ ។

ដោយអាស្រ័យហេតុទាំងពីរប្រការនេះហើយ ទើបខ្ញុំចំរៀបរៀង សៀវភៅនេះឡើងឲ្យឈ្មោះថា "សង្ឃការណីយកិច្ច" ដើម្បីឧទ្ទិសផលព្រមទាំងទុកជាអនុស្សាវរីយ៍ដល់ពុទ្ធបរិស័ទ :

ទី ១. ដែលជាអ្នកជួយទំនុកបំរុងក្នុងការកសាងវត្តជោតនារាម

ទី ២. ដល់ព្រះគ្រូវិរិយសំវរៈនាម ស្រី–ទេព ជាឧបជ្ឈាយ៍របស់ខ្ញុំ, លោកគ្រូព្រហ្មត្ថេរ ស្រី-យក់ និងលោកគ្រូបន្ទុកាសោ វង់-ជេត ជាឧបសម្បទាចារ្យនិងធម្មាចារ្យរបស់ខ្ញុំ ព្រមទាំង មាតាបិតារបស់ខ្ញុំ

ទី ៣. ចំពោះសម្ដេចព្រះមហាសុមេធាធិបតី (ជ-ណ. ជោតញ្ញាណោ) សង្ឃនាយកគណៈមហានិកាយ ដែលបាននិមន្តទៅទីនោះផ្ទាល់ជាដំបូង មួយអន្លើដោយព្រះគ្រូសង្ឃសត្ថា (ប៉ី.ស. ធម្មារាមោ), ព្រះបាឡាត់សង្ឃវង្សស្ទាង និងភិក្ខុឯទៀតច្រើន ដែលហែហមសម្ដេច ៗ ក៏បានប្រសិទ្ធិពរនិងសុភមង្គលនៅទីអារាមនោះ ហើយបានវាស់វែងគូរផែនទីប្លង់ទៅរាជការ លុះត្រាតែបានសម្រេចច្បាប់វត្តពេញទី សឹងមានព្រះរាជក្រឹត្យលេខ ៦៧ ន.ស ចុះថ្ងៃ ១៤ មីនា ឆ្នាំ ១៩៥១ ព.ស. ២៤៩៣ ជាសំគាន់ ។

អាស្រ័យហេតុដូច្នេះ ទើបពុទ្ធបរិស័ទជើងវត្តមូលមតិគ្នាជាឯកច្ឆន្ទ ដាក់នាមវត្តថា "ជោតនារាម" ដោយយកតាមនាមបញ្ញត្តិរបស់សម្ដេច

“ជោតញ្ញាណោ” ទៅភ្ជាប់ផង ទុកជាអនុស្សាវរីយ៍តទៅ ។

សៀវភៅនេះបែកចេញជា ១០ វគ្គ គឺវគ្គទី ១ បឋមបរិយាយ, វគ្គទី២ និយាយពីកិច្ចរបស់សមាគម, វគ្គទី ៣ និយាយពីការរៀបចំសេនាសនៈក្នុងវត្ត និងផែនទីវត្ត, វគ្គទី ៤ និយាយពីសង្ឃកិច្ច, វគ្គទី ៥ និយាយពីការកាន់បញ្ជីវត្ត និងគម្រូបញ្ជីផ្សេងៗ, វគ្គទី ៦ គម្រូសំបុត្រស្នាម ដែលត្រូវសរសេរឆ្លើយឆ្លង ទៅមកក្នុងផ្លូវពុទ្ធចក្រ-អាណាចក្រ និងគម្រូសំបុត្រដែលបព្វជិតសរសេរទៅកាន់បព្វជិត, គ្រហស្ថទៅកាន់គ្រហស្ថ, បព្វជិតទៅកាន់ក្សត្រិយ៍, បព្វជិតទៅកាន់មន្ត្រី, គ្រូជាគ្រហស្ថទៅកាន់-សិស្ស ។ល។ វគ្គទី ៧ គម្រូកម្មវិធី (ប្រូក្រាម) ធ្វើបុណ្យផ្សេង ៗ បែបបោះពុម្ព, បែបកាខ្នងស្រោមសំបុត្រ, វគ្គទី ៨ វិធីក្រើនកឋិន វេរផ្កា បែបប្រកាសវិសាខបូជា មាឃបូជា, វគ្គទី ៩ ងារនិងតំណែងស័ក្តិព្រះសង្ឃ-នាយក និងព្រះរាជាគណៈ, វគ្គទី ១០ ប្រវត្តិអ្នកប្រាជ្ញ (មិនទាន់មាន) ។

ខ្ញុំមានក្តីសង្ឃឹមថា សៀវភៅនេះនឹងមានប្រយោជន៍ ទុកជាគតិមួយ ជួយបំភ្លឺដល់អស់លោកអ្នកគ្រប់គ្រងនិងអ្នកកសាងវត្ត ព្រមទាំងដល់អស់លោក-អ្នក ទូទៅ ដែលត្រូវការសរសេរសំបុត្រទៅណាមកណា អាចមើលជាគម្រូបានដោយមានច្បាប់ក្នុងនេះស្រាប់ សេចក្តីពន្យល់ជាសង្កាត់ៗ ប្រៀបធៀបទៅតាមវគ្គ ដូចមានរៀបរាប់ខាងលើនេះស្រាប់ ។

www.elibraryofcambodia.org

សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក គណៈមហានិកាយ បានចាត់ការឲ្យពិនិត្យសៀវភៅនេះត្រឹមត្រូវហើយ ។

សូមព្រះពុទ្ធសាសនា ដែលមានការគ្រប់គ្រងល្អ រុងរឿងអស់កាលដ៏អង្វែងទៅ ។

ធ្វើនៅថ្ងៃ ទី ២០ ខែកញ្ញា ព.ស. ២៤៩៦ / គ.ស. ៩៥[illegible]

ធម្មធីរោ ភិក្ខុ មាស រឿង

www.elibraryofcambodia.org

## វគ្គទី ១

## បឋមបរិយាយ

ការគ្រប់គ្រងនឹងការកសាងវត្តសម័យបច្ចុប្បន្នរបស់អ្នកកាន់ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាយើង តែងធ្វើទៅតាមទំនើងចិត្តរៀងខ្លួន គឺធ្វើទៅតាមគំនិតរបស់រូបចៅអធិការនីមួយ ៗ ដែលច្រើនតែខ្វះការអប់រំបំពេញវិជ្ជា គឺខ្វះសង្ឃសមាគមដឹកនាំពន្យល់, ម្ល៉ោះហើយសង្ឃករណីយកិច្ចរបស់បព្វជិតវត្តខ្លះ ក៏ស្ថិតនៅក្នុងការរយីករយាកដូចសព្វថ្ងៃ ថ្វីបើក្រសួងព្រះសង្ឃនាយកខំប្រឹងយកចិត្តទុកដាក់យ៉ាងណាក៏ដោយ ក៏នៅតែខ្សត់ខ្សោយពុំសូវបានផល ព្រោះប្រើសិទ្ធិពុំសូវបានបរិបូណ៌ ៗ

www.elibraryofcambodia.org

ប្រសិនបើរាជការអាណាចក្រជួយជ្រោមជ្រែង ឬបើកអំណាចឲ្យបានទូលាយ ដើម្បីបង្កើតឲ្យមានការប្រជុំ តម្រូវដល់ពួកចៅអធិការ អនុគណមេគណគ្រប់វត្ត ឲ្យចូលមកទទួលការអប់រំខាងវិជ្ជាគ្រប់គ្រងជាដើម ក្នុងមួយឆ្នាំបានចំនួន១ឬ២ខែនៅទីខេត្តរៀងខ្លួន, ការគ្រប់គ្រងនឹងការកសាងវត្ត មុខជានឹងប្រែទៅជាមានរបៀបរៀបរយល្អដូចគ្នាគ្រប់វត្តមិនខាន ៗ

កាលសម័យព្រេងនាយ ព្រះមហាក្សត្រទាំងឡាយ មានព្រះបាទបសេនទិកោសលជាដើម បានថ្វាយអគ្គជាពុទ្ធសាសនូបត្ថម្ភក៍ (អ្នកទំនុកបម្រុងព្រះពុទ្ធសាសនា) បានផ្សាយអំណាចអប់រំអ្នកកាន់ព្រះពុទ្ធសាសនាតាមកាលដ៏គួរ ៗ លុះក្រោយមកព្រះពុទ្ធជាម្ចាស់ចូលព្រះបរមនិព្វានទៅរវាងជាង ២០០ ឆ្នាំ ព្រះពុទ្ធសាសនាក៏មាននៅតែក្នុងមជ្ឈិមប្រទេស

(ប្រទេសឥណ្ឌា)ដែលមានព្រះមហាក្សត្រអង្គមួយព្រះនាមព្រះបាទអសោក បានថ្វាយអង្គជាពុទ្ធសាសនូបត្ថម្ភកដែរ ។

ចាប់តាំងពីពេលនោះមក ព្រះពុទ្ធសាសនាបានចម្រើនរុងរឿងរៀងរាបមក ដោយសារព្រះមហាក្សត្រអង្គនេះ ប្រគល់ភារៈប្រគេនសង្ឃសមាគមទាំងមូល មានព្រះថេរៈជាច្រើនអង្គ ដែលឈ្លៀវឈ្លាសវៀងវៃក្នុងធម៌វិន័យ មានព្រះមោគ្គលីបុត្តតិស្សត្ថេរជាដើម តាំងក្រុមជំនុំសម្រេចរឿងព្រះសង្ឃនិងការត្រួតត្រាគ្រប់គ្រងសង្ឃមណ្ឌលទាំងមូល គឺជាកិច្ចការណាដែលព្រះសង្ឃបានប្រជុំគ្នាសម្រេចហើយ ឥតមានឲ្យសើរើអ្វីបានឡើយ ព្រោះកិច្ចសង្ឃទាំងអស់នៅក្នុងក្របខណ្ឌច្បាប់ព្រះពុទ្ធសាសនា

www.elibraryofcambodia.org

ស្រេចហើយតែជំនុំសង្ឃវិនិច្ឆ័យ ។ ម្យ៉ាងហើយការគ្រប់គ្រងសង្ឃមណ្ឌលសឹងមានសេចក្ដីចំរើនល្អទៅតាមបែបផែនតែមួយ ។

ឯព្រះបាទអសោកគ្រាន់តែផ្សាយព្រះរាជអាជ្ញាអប់រំនិយមតាមសេចក្ដីវិនិច្ឆ័យនិងការគ្រប់គ្រងរបស់ជំនុំសង្ឃប៉ុណ្ណោះ (សឹងមានពិស្ដារក្នុងគម្ពីរបឋមសមន្តបាសាទិកាស្រាប់) ។

ខ្ញុំលើករឿងនេះមកដំណាលបន្តិច ដើម្បីឲ្យឃើញថាកិច្ចការអ្វីនិមួយ ៗ បើមានការឧបត្ថម្ភជាកម្លាំង និងការប្រជុំរឿយ ៗ រួបរួមមួយអន្លើដោយលោកអ្នកឈ្លៀវឈ្លាសក្នុងសង្ឃកិច្ច, នោះសេចក្ដីចំរើនរមែងមានមែនពិត ឥតមានសេចក្ដីវិនាសឡើយ (សឹងដូចមានសំដែងក្នុងអបរិហានីយធម្មសូត្រស្រាប់) ។

កិច្ចការនេះដូចគ្នានិងការគ្រប់គ្រងខាងផ្លូវអាណាចក្រដែរ, អស់ទាំងមន្ត្រីស្រុក - ខេត្ត ដែលរាជការចាត់ឲ្យទៅត្រួតត្រាស្រុក - ខេត្ត សុទ្ធតែជាអ្នកឆ្លាតស្ទាត់ជំនាញ ដោយធ្លាប់បានទទួលការអប់រំវិជ្ជា ពីសាលារៀនជាមុន; កាលបើកិច្ចការគ្រប់គ្រងនោះមិនបានផលល្អទេ, រាជការដំរិះតម្រូវឲ្យផ្លាស់ចេញជាដាច់ខាត ឥតមានបន្ធូរ ។

គួរវត្តនីមួយ ៗ គួរបង្កើតគណៈកម្មការមួយក្រុម សម្រាប់ចាត់ចែងការងារគ្រប់ដំពូកក្នុងវត្ត មានការកសាងទីសេនាសនៈជាដើម ។

---

វគ្គ ទី ២

www.elibraryofcambodia.org

## កិច្ចសមាគម

សមាគមនីមួយ ៗ មានសមាគមជំនួញជាដើម ដែលអាចនឹងកើតឡើងបាន ដោយអាស្រ័យហេតុសំខាន់ ៣ យ៉ាងគឺ :

១- សមាគមនោះមានប្រាក់ដើមទុនគ្រប់គ្រាន់ល្មមធ្វើការបាន ព្រមទាំងតាំងទីសំណាក់ការនៅចំណុចទីដ៏សំខាន់ដែលជាប្រភពនៃផ្លូវគមនាគមន៍ខាងពាណិជ្ជកម្មនិងកសិកម្មជាដើម ។

២- សមាគមនោះមានសៀវភៅផ្សេង ៗ សម្រាប់កត់ត្រាលិខិតចេញចូល មានសៀវភៅប្រាក់ចំណូល—ចំណាយជាដើមដោយសព្វគ្រប់ ។

៣- អ្នកកាន់ការគ្រប់គ្រងសមាគមនោះជាមនុស្សហ្មត់ចត់ត្រឹមត្រូវ

អង់អាចវៃឈ្លាសស្មោះត្រង់ ៗ

សមាគមដែលប្រកបដោយអង្គទាំង ៣ ប្រការដូចពណ៌នាខាងលើនេះ មុខជានឹងកើតតាមបំណង នឹងបាក់ប្រសិទ្ធផលថេរចិរកាលទៅមិនលុបលោយ ដូចគ្នានឹងវត្តនីមួយ ១ ដែលជាទីសមាគមរបស់អ្នកកាន់ព្រះពុទ្ធ-សាសនា គោងអាស្រ័យគោលទាំង ៣ យ៉ាងនេះដែរ គឺ :

១- ពុទ្ធបរិស័ទដើងវត្តព្រមព្រៀងគ្នាបរិច្ចាគទ្រព្យល្មមគ្រប់គ្រាន់កសាងទីអារាម ហើយជ្រើសរើសនាទីតាំងអាវាសនោះ ឲ្យចំពាក់កណ្ដាលភូមិស្រុក ដែលមានផ្លូវគមនាគមន៍ចេញចូលទៅមកបានដោយស្រួល ៗ

២- ចៅអធិការ ត្រូវកាន់សៀវភៅផ្សេង ១ មានសៀវភៅសំបុត្រ www.elibraryofcambodia.org ចេញ-ចូលជាដើម ៗ

៣- ចៅអធិការដែលគ្រប់គ្រងវត្តនោះ ជាអ្នកប្រកបដោយសីលសមាធិ បញ្ញា ស្មោះត្រង់ មានសមត្ថភាពអង់អាចវៃឈ្លាសក្នុងការគ្រប់គ្រង នឹងបាត់បែងការកសាង មិនធុញទ្រាន់នឹងមុខការខ្លួន ៗ

លំដាប់អំពីនេះនឹងដកគោលសំខាន់ទាំង ៣ យ៉ាងដែលពណ៌នាខាងលើនេះយកមកពង្រីកសេចក្ដី ប្រៀបធៀបជាគូគ្នាតាមផ្លូវអាណាចក្រនិងពុទ្ធចក្រដើម្បីជាសណ្ដាប់ធ្នាប់តទៅ, តែមុននឹងអធិប្បាយសូមប្រែពាក្យថា "សមាគម" តាមវចនានុក្រមខ្មែរ <សំ "ព្រម", ÷> ម + អាគម "ការមក, ការមកជួបជុំ, ការប្រជុំ, ការរួបគំនិតគ្នា, ដំណើររួបរួមកិច្ចការជាមួយគ្នា, ដូចពាក្យថា "សង្ឃសមាគម, ពុទ្ធបរិស័ទសមាគម, ពុទ្ធិ-

កសមាគម" ជាដើម ។

១. សមាគមជំនួញនីមួយ ៗ ដែលនឹងកើតឡើងបាន លុះតែមានប្រាក់ដើមទុនល្មមធ្វើការនោះបាន ទើបសម្រេចការនោះទៅកើត; បើប្រាក់ដើមទុននោះតិច, ក៏ធ្វើការនោះមិនកើត; ដូចគ្នានឹងពួកពុទ្ធបរិស័ទដែលនឹងផ្ដើមកសាងអាវាសនីមួយ ៗ លុះតែពួកពុទ្ធបរិស័ទសមាគមនោះស្រុះស្រួលគ្នាបរិច្ចាគធនធានឲ្យល្មមដល់ការកសាងបាននោះផង ទើបចាត់ចែងធ្វើការនោះទៅបានឆាប់ហ័ស មិនស្មុគដំណើរលើលាចោលការនោះពាក់កណ្ដាលផ្លូវ ដូចយ៉ាងវត្តខ្លះក្នុងប្រទេសយើងច្រើនតែកសាងបានបន្តិចបន្តួចក៏ទុកចោលនាពាក់កណ្ដាលផ្លូវ នឹងធ្វើឲ្យទៅជាអាវាសល្មមភិក្ខុសាមណេររៀនសូត្រក្នុងផ្លូវសាសនាពុំបាន, ប្រៀបដូចជាអ្នកតាំងផ្ទះលក់ដូរហើយរលំទៅវិញដោយខ្វះប្រាក់ដើមទុន ឬមួយមានប្រាក់ដើមទុនគ្រប់គ្រាន់ តែតាំងផ្ទះ (ហាង) លក់ដូរនោះមិនត្រូវចំផ្លូវជំនួញ, សមាគមជំនួញនោះក៏ពុំសម្រេច; ដូចគ្នានឹងទីកសាងអារាម បើអ្នកដើមគំនិតកសាងនោះមិនប៉ិនប្រសប់រិះគិតរកទីកន្លែងឲ្យបានចំរើនទៅអនាគតទេ, វត្តនោះក៏ពុំសូវលូតលាស់ក្នុងផ្លូវព្រះពុទ្ធសាសនា, ហេតុនេះមុននឹងចាប់កសាងវត្តនីមួយ ៗ ត្រូវលៃលកជ្រើសរើសនាទីឲ្យបានចំពាក់កណ្ដាលភូមិស្រុក ព្រមទាំងស្រួលដល់ផ្លូវគមនាគមន៍ផង ជាទីស្រួលដល់ការទៅមកកាន់វត្តបានដោយងាយមិនធុញទ្រាន់ ។

www.elibraryofcambodia.org

២. សមាគមជំនួញបើចាត់ការខ្លួនពុំមានបញ្ជីប្រាក់កាន់ឲ្យត្រឹមត្រូវ

តាមច្បាប់ដំនួញទេ, សមាគមនោះមុខជារលាយសាបសូន្យទៅវិញ រ
មុខបាតមិនឃើញ ដោយប្រាក់ចេញចូលខាតបំណេញគ្មានបានកត់ត្រ
ទុកឲ្យត្រឹមត្រូវ ថែមទាំងខ្លួនអ្នកកាន់ការនោះនឹងជាប់ទោសជាតែបំបា
ប្រាក់សមាគមនោះ ហើយនឹងមានពាក្យតំណះតិះដៀលពីអ្នកដែលចូ
ហ៊ុនជាច្រើនប្រការថែមទៀតផង, ដូចគ្នានឹងវត្តនីមួយ ៗ បើចៅអធិការ
អនុគណក្តី មេគណក្តី ពុំបានបង្កើតឬកាន់បញ្ជីវត្តទេ ឬកាន់ដោយមិនយ
ចិត្តទុកដាក់ ឬក៏កាន់ដោយល្ងង់ខ្លៅ ពុំមានរបៀបរៀបរយ, មុខជានឹ
មានសេចក្តីខុសឆ្គាំឆ្គងក្នុងកិច្ចការមុខក្រសួងខ្លួនមិនខាន, តួយ៉ាងដូច
ឆាយាបុសង់ដីកាដែលត្រូវចេញទៅឲ្យភិក្ខុ-សាមណេរ ដែលបួសក្នុងស
www.elibraryofcambodia.org
ណាក់របស់ខ្លួន, ខ្លួនចុះលេខ និងកាលបរិច្ឆេទមិនបានត្រឹមត្រូវ ឬមា
គោសលុបជាដើម ដោយមកពីគ្មានសៀវភៅសម្រាប់ចុះលេខឲ្យមា
របៀបទៅតាមច្បាប់, កាលណាមានរឿងរ៉ាវ រាជការឆែកឆេរឡើង ស្រា
ស្រាវរកដើម—ចុង សួររកបញ្ជីពុំឃើញមាន ឬមានដែរតែចុះមិនត្រឹមត្រូ
មិនមានរបៀប កំហុសនោះមុខជានឹងធ្លាក់មកលើខ្លួនអ្នកចេញលិខិតនោ
មិនខាន (ចូរមើលរបៀបកាន់សៀវភៅទៅខាងមុខ) ។

៣- អ្នកកាន់កាប់សមាគមជាមនុស្សចេះដឹង ស្ទាត់ជំនាញក្នុងមុ
ការរបស់ខ្លួន មានចេះចាត់ចែងមនុស្សក្រោមបង្គាប់ឲ្យកាន់មុខការដោយ
ផ្សេង ៗ រៀងខ្លួន មានមុខការខាងទទួលដំណឹងតម្លៃទំនិញឡើងចុះ ខា
ដើរស៊ើបសួររកទិញទំនិញណាដែលគាប់ចិត្តអ្នកទិញដូរ គួរយកមកដូ

ឲ្យបានចំណេញជាដើម, ដូចគ្នានឹងចៅអធិការវត្ត ត្រូវបេះដាក់ទុកចែករំលែកមុខងារខ្លួនដល់គ្រូសូត្រឆ្វេង-ស្តាំ នាំឲ្យរៀនជួយធ្វើការងារមានការត្រូវបង្កើតសាលាសម្រាប់ក្មេង សាលាបាលី សាលាធម្មវិន័យជាដើម ដែលជាទីបណ្តុះគ្រាប់ផ្កាវិជ្ជាឲ្យមានក្នុងវត្ត, ប្រើមុខវិជ្ជាណាមួយខ្វះខាតក្នុងវត្ត, យើងចង់ឲ្យមានវិជ្ជាដែលខ្វះខាតនោះកើតឡើង ត្រូវបញ្ជូនសិស្សឲ្យទៅរៀនយកវិជ្ជានោះមកពីវត្តដទៃ មិនត្រូវទំរន់ប្រកែកប្រកាន់ឡើយ ដើម្បីយកវិជ្ជានោះមកផ្សាយដល់សិស្សគណនិងពួកបរិស័ទ ជើងវត្តដែលគ្នាខំប្រឹងយកចិត្តទុកដាក់បរិច្ចាគទ្រព្យយកមកទុកឲ្យកសាងវត្ត ត្រូវបនាទ្រព្យអ្នកមានសទ្ធានោះ [illegible] ធ្វើព្រះសង្ឃក្នុងវត្តឲ្យសមរម្យទៅជាស្រែបុណ្យរបស់ទាយកទាយិកាឡើង ។

អាស្រ័យហេតុនេះ ទើបខ្ញុំផ្តើមធ្វើសៀវភៅនេះឡើងឲ្យឈ្មោះថា "សង្ឃការណីយកិច្ច" ដើម្បីជាគតិសម្រាប់ជួយបំភ្លឺដល់លោកអ្នកគ្រប់គ្រងនិងលោកអ្នកកសាងវត្ត ។

---

## វគ្គទី ៣

## ការរៀបចំទីសេនាសនៈក្នុងវត្ត

កាលពីសម័យបុរាណ បុព្វបុរសរបស់យើង ដែលបានកសាងទីអាពម ឧទ្ទិសចំពោះព្រះពុទ្ធសាសនា មានរបៀបរៀបរយណាស់ គួរយ៉ាងដូចជា ប្រាសាទនគរវត្តក្តី នគរពិជ័យក្តី ដែលមាននៅក្នុងកម្ពុជរដ្ឋ ឬវិហារខ្លះ គួរយ៉ាងដូចជាវត្តជេតពន ដែលអនាថបិណ្ឌិកសេដ្ឋី

កសាងនៅមជ្ឈិមប្រទេសជាដើម ដែលបានព្រងចំណាំងមក សឹងសុទ្ធតែមានរបៀបរៀបរយល្អប្លែកជាទីទស្សនាការ, មិនមែនត្រឹមតែជាទីសរសើរនៃពួកអ្នកកាន់ព្រះពុទ្ធសាសនាជាតិស្រុកឆ្ងាយនេះទេ, សូម្បីតែជនបរទេសមានជាតិអឺរ៉ុបជាដើម ដែលជាអ្នកកាន់លទ្ធិសាសនាដទៃ ក៏ចំស្ទះស្វែងគ្រាប់មកមើល ហើយមានសេចក្ដីស្ងើចអួតសរសើរ ចំពោះបូជនីយដ្ឋានអស់នេះ ក៏មកពីការរៀបចំនោះល្អឯក ដោយធ្វើទៅតាមបន្ទាត់ផែនទីដែលគេបានគិតទុកជាមុន ។

ឥឡូវនា អំណើះតពីទីនោះមករហូតមកដល់យើងសព្វថ្ងៃនេះ ពពួកពុទ្ធបរិស័ទ www.elibraryofcambodia.org ដែលកសាងវត្តអារាមជាដើម ច្រើនធ្វើឥតសណ្ដាប់ធ្នាប់ ពុំបានគិតគូរផែនទីឲ្យមានរបៀបរៀបរយទុកជាមុន ម្ល៉ោះហើយវត្តនីមួយ ៗ សេនាសនៈដែលបានសង់នោះច្រើនរកគេតរក្សូតពុំសូវមានរបៀបរៀបរយល្អ ធ្វើតាមតែបាន គឺច្រើនតែធ្វើទៅតាមចិត្តរបស់ចៅអធិការ ១ រូប ១ តាមចិត្តអ្នកម្ចាស់កសាង(១)

១ - ទីបរិវេណវត្ត គួរឲ្យមានទទឹង២០០ម៉ែត្រ បណ្ដោយ ៣០០ ម៉ែត្រ ឬ ៤០០ម៉ែត្រ យ៉ាងតូច (២)

---

១- ការកសាងសេនាសនៈ តាមអំពើចិត្ត ឥតឲ្យសង្ឃសំដែងទីជាមុន ជាហេតុឲ្យភិក្ខុអ្នកកសាងនោះត្រូវអាបត្តិយ៉ាងធ្ងន់គឺសង្ឃាទិសេសក៏មាន ។ ២- ចូរសង្កេតមើលទីបរិវេណវត្តរបស់អ្នកកាន់សាសនាកាតូលិកមានទំហំ ១០ ឬ ២០- ៤០ ហិកតា ដោយគេមានគំនិតឃើញវែងឆ្ងាយ យកដីធ្វើឲ្យបានផលប្រយោជន៍គុបដែនអាវាសរបស់គេតទៅអនាគតផង ។

២- គួរវិហារសង់នៅចំកណ្ដាលវត្ត ឋិតទៅខាងទិសបូពិបច្ចិម, ទីសិក្សាវិជ្ជាផ្សេងៗ (សាលាបាលីរង សាលាបឋមវិជ្ជា) ត្រូវសង់ឲ្យទៅតាមផ្លូវបន្ទាត់គ្នា ឋិតនៅលើទីរាលស្រឡះ ព្រមទាំងមានទីកីឡាសម្រាប់ក្មេងឈប់សម្រាកលេងក្បែរនោះផង (មើលគម្រូផែនទី), កុដិចៅអធិការគួរសង់នៅនាទីណាមួយ ជាការស្រួលដល់ការត្រួតត្រាមើលការខុសត្រូវ, កុដិគ្រូសូត្រឆ្វេង-ស្ដាំ គួរសង់ខាងជើង ១ ខាងត្បូង ១, ឯសេនាសនៈដទៃផ្សេងៗ គួរសង់តាមផ្លូវបន្ទាត់ខាងជើង ខាងត្បូង (មើលគម្រូផែនទី), ចំណែកខាងស្រះទឹក ដែលត្រូវការនឹងជីក គួរធ្វើនៅទីខាងមុខព្រះវិហារ

៣- ចេតិយ៍ មិនត្រូវអនុញ្ញាតឲ្យសាងតាមសេចក្ដីស្ម័គ្ររបស់អ្នកស្រុកសុំនោះទេ, គួរចាត់ចែងដីខាងមុខវិហារមួយអន្លើឃ្លាតចំនួន ៣០ ឬ ៤០ ម៉ែត្រខាងមុខវិហារ រៀបជាជួរពីជើងទៅត្បូង ដើម្បីកុំឲ្យស្មុកស្កះបង្អៀតទីវត្ត (ចូរមើលផែនទី) ។

៤- បង្គន់ត្រូវសង់នៅទីណាដែលឆ្ងាយពីផ្លូវដើរ ។

៥- គួរធ្វើផ្លូវខ្វាត់ខ្វែងក្នុងវត្តមានទំហំប្រហែលជា២ឬ៣ម៉ែត្រ ហើយឲ្យមានសួនច្បារ មានដាំដើមផ្កា ជាគ្រឿងសក្ការបូជាជាដើម ពល់តែមុខសេនាសនៈនិងមុខវិហារ ដើម្បីជាអលង្ការរបស់វត្ត; ឯដើមឈើស្រុកបរិ-ភោគផ្លែ ដូចដូងខ្នុរស្វាយជាដើម គួរដាំទៅខាងព្រំវត្តខ្លះ និងទីដទៃផ្សេងៗ ក្នុងវត្តតាមការគួរ ។

ហេតុដូច្នេះ ដើម្បីនឹងរៀបចំកសាងវត្តនីមួយៗ ឲ្យត្រូវទៅតាមក្បួន

www.elibraryofcambodia.org

អនាម័យផង ឲ្យបានរៀបរយល្អផង ជាទីទស្សនានៃពុទ្ធបរិស័ទផង គួរតែគិតគូរផែនទីទុកជាមុនសិន បន្ទុលនាទីដែលត្រូវសង់គួវិហារក្តី សេនាសនៈផ្សេង ៗ ក្តី ឬជីកស្រះអណ្តូងទឹកក្តី គួរលៃលកទៅតាមសភាពដីវត្ត ឲ្យបានជារបៀបរៀបរយឡើង ៗ ផែនទីព្រាងនេះដែលគេទុកខាងក្រោយ ល្មមយកជាគតិសម្រាប់បំភ្លឺគំនិតនៃអ្នកកសាងអារាមថ្មីទៅអនាគត ។

## របៀបកិច្ចការក្នុងក្រុម (១)

រាល់ក្រុមទាំងអស់ក្នុងវត្ត (២) មេក្រុមមួយ ៗ ត្រូវត្រួតត្រាលើមេកុដិដែលនៅក្នុងក្រុមរបស់ខ្លួន ឲ្យមានរបៀបរៀបរយល្អ ដោយស្ថានដូចមានតទៅនេះ

www.elibraryofcambodia.org

### ១- អំពីធ្វើបញ្ជីរាល់កុដិក្នុងវត្ត

មេកុដិនីមួយ ៗ ត្រូវធ្វើបញ្ជីរាយឈ្មោះភិក្ខុ–សាមណេរ និងក្មេងវត្តដែលនៅក្នុងកុដិរបស់ខ្លួន ៗ បញ្ជីនោះត្រូវប្រាប់អាយុ–ស្រុកកំណើតនិងមុខការសព្វថ្ងៃ គឺរៀនអ្វី ? ធ្វើការអ្វី ? ហើយចុះស៊ីញ៉េបោះត្រា រួចជូនបញ្ជីនោះទៅមេក្រុម ។ កាលបើបានពិនិត្យឃើញថាត្រឹមត្រូវហើយ ត្រូវសរសេរចុះសេចក្តីក្នុងបញ្ជីនោះថា "បានពិនិត្យឃើញត្រឹមត្រូវហើយ" រួចចុះស៊ីញ៉េបោះត្រា ហើយបញ្ជូនបញ្ជីនោះទៅចៅអធិការ ។ ទាំងលោក

---

១ ចម្លងតាមរបៀបដែលសម្តេចព្រះមហាសុមេធាធិបតី ជ.ណ. ជោតញ្ញាណោ តែង ។

២. សំដៅវត្តណាធំ ៗ ឬវត្តក្នុងក្រុងជាដើមដែលមានបង្កើតមេក្រុម ។

មេក្រុមក៏ត្រូវធ្វើបញ្ជីសម្រាប់កុដិរបស់ខ្លួនដូច្នោះដែរ ។

បើប្រសិនជាមានលោកមេកុដិណាមួយ លាក់បំបិទបំបាំងឈ្មោះណាមួយមិនចុះបញ្ជី, ពុំនោះនៅវេលាដែលធ្វើបញ្ជីរួចជូនស្រេចហើយមានភិក្ខុ—សាមណេរ ឬក្មេងណាមួយមកនៅថ្មី ហើយលោកមេកុដិពុំបានចុះឈ្មោះជូនទៅមេក្រុម, កាលបើមេក្រុមបានដឹងថាមានឈ្មោះដែលពុំទាន់បានចុះក្នុងបញ្ជីសម្រាប់វត្ត នោះមេក្រុមត្រូវប្រគេនដំណឹងនោះដល់ចៅអធិការ, ហើយត្រូវបណ្តេញឈ្មោះនោះចេញពីវត្តនេះមួយរំពេច, ទាំងលោកដែលបំបិទបំបាំងឈ្មោះនោះ ក៏ត្រូវមានទណ្ឌកម្មតាមទោសានុ-ទោស ។ បើមានភិក្ខុ-សាមណេរ ឬក្មេងមកនៅថ្មី, មេកុដិត្រូវធ្វើបញ្ជីបន្ថែមប្រគេនទៅលោកមេក្រុមក្នុងរវាង ៣ ថ្ងៃយ៉ាងយូរ ។ ឯភិក្ខុសាមណេរដែលចូលមកសូមនៅនោះ, លុះតែមានសំបុត្របរិសុទ្ធឬសំបុត្រអនុញ្ញាតពីវត្តដើម កាន់មកជាសម្គាល់ ទើបត្រូវទទួលឲ្យនៅបាន ។ មេក្រុមកាលបានទទួលបញ្ជីបន្ថែមពីមេកុដិណាមួយហើយ ត្រូវជូនទៅចៅអធិការ ១ ពិនិត្យបញ្ជាក់ បើឃើញថាគួរឲ្យនៅបាន នោះត្រូវចុះឈ្មោះនោះបន្ថែមទៅក្នុងបញ្ជីមុន, បើឃើញថាមិនគួរឲ្យនៅទេ, មេកុដិនឹងទទួលឈ្មោះនោះឲ្យនៅពុំបានឡើយ ។ មួយយ៉ាងទៀត បើមានឈ្មោះណាមួយលែងនៅហើយឬលាចាកសិក្ខាបទទៅជាគ្រហស្ថហើយ, ត្រូវមេកុដិជូនដំណឹងដល់មេក្រុម ១ ត្រូវជូនដំណឹងនោះដល់ចៅអធិការ ដើម្បីនឹងលុបឈ្មោះនោះពីក្នុងបញ្ជី ។

www.elibraryofcambodia.org

## ២- អំពីការសុំសំណាក់ក្នុងវត្ត

កល់កុដិទាំងអស់ បើមានគ្រហស្ថមកសូមសំណាក់, ត្រូវពិនិត្យមើលដោយហ្មត់ចត់, បើឥតមាននរណាមួយក្នុងកុដិស្គាល់អ្នកសុំសំណាក់នោះទេ, មិនត្រូវទទួលឲ្យសំណាក់អាស្រ័យឡើយ, បើមានស្គាល់ ទើបឲ្យសំណាក់បាន, ប៉ុន្តែការព្រមទទួលឲ្យសំណាក់នេះត្រូវលោកមេកុដិទទួលខុសត្រូវលើខ្លួន ។ បើគ្រហស្ថនោះជាស្ត្រីភាព, ទោះបីស្គាល់ក្តី, បើឥតមានទីកន្លែងដាច់ដោយឡែកទេ, ក៏មិនត្រូវឲ្យសំណាក់អាស្រ័យក្នុងកុដិមួយរួមជាមួយគ្នាឡើយ ។ ការឲ្យសំណាក់នោះយ៉ាងយូរបានត្រឹម៧ថ្ងៃ, វៀរលែងតែមានអនុញ្ញាតពិសេសអំពីចៅអធិការ ដែលគួរអនុញ្ញាតឲ្យនឹងខានពុំបាន ។ ទោះបីបព្វជិតផងគ្នាក៏ដោយ ត្រូវតែមេកុដិពិនិត្យឲ្យល្អិតល្អសិនសឹមឲ្យសំណាក់, ត្រូវមេកុដិនាំខ្លួនបព្វជិតនោះព្រមទាំងលិខិត ទៅឲ្យមេក្រុម ឲ្យមេក្រុមចុះសេចក្តីលើខ្នងលិខិតហើយស៊ីញ៉េបោះត្រា សំគាល់ការចូលមកដល់នឹងចេញទៅវិញ; ត្រូវមេក្រុមសរសេរត្រង់កន្លែងថា “ចៅអធិការ” នោះថា “ព្រះ ..... ជាមេក្រុមនៅវត្ត ...” ហើយស៊ីញ៉េបោះត្រាត្រង់កន្លែងនោះ ។

www.elibraryofcambodia.org

## ៣- អំពីការសំអាត

មេក្រុមត្រូវចាត់ការបង្គាប់បញ្ជាទៅលើមេកុដិក្នុងក្រុមរបស់ខ្លួនឲ្យសំអាតទីកុដិ និងជុំវិញកុដិ និងនាទីដីដែលកុដិមួយ ៗ ត្រូវសំអាតពីត្រឹមណាទៅត្រឹមណានោះឲ្យស្អាតជានិច្ច ។ ការសំអាតនេះជាកិច្ចមួយដ៏សំខាន់

នឹងធ្វេសប្រហែសពុំបាន ត្រូវតែត្រួតត្រាយ៉ាងប្រងិតប្រដី, ដោយហេតុនេះ ត្រូវមេក្រុមតាំងលោកណាមួយក្នុងអំណាចរបស់ខ្លួនឲ្យជាអ្នកដើរត្រួតត្រាមើលបន្ថែមគ្រប់ទីកុដិក្នុងក្រុមរបស់ខ្លួន ។

៤- អំពីការសំអាតទីវិហារនិងចេតិយធំ

ទីមុខវិហារនិងទីចេតិយជាទីឱកាសផ្សេងមិនទាក់ទងដោយកុដិណាមួយឡើយ ជាទីសាធារណៈ សម្រាប់វត្តទាំងមូល ត្រូវសង្ឃទាំងអស់ក្នុងវត្តយកចិត្តទុកដាក់ជួយថែទាំសម្អាតឲ្យបានស្អាតជានិច្ច ។ ការថែទាំទីវិហារនិងទីចេតិយនោះ ត្រូវដាក់ជាវេនតាមក្រុម គឺក្នុងក្រុមមួយ ៗ ត្រូវទទួលវេនបន្តៗគ្នា ត្រូវwww.elibraryofcambodia.org[illegible]នរាយតាមកុដិក្នុងក្រុមរបស់ខ្លួន ឲ្យសាមណេរនិងក្មេងបោសសម្អាត, បើមានស្មៅដុះ, ត្រូវមើលស្មៅចេញ គឺ ត្រូវធ្វើកុំឲ្យមានជាតិស្មៅដុះបាន ត្រូវកាន់វារតាមលំដាប់វេនជានិច្ចទៅ តាំងពីវេនទី ១ ទី ២ ជាដើមរៀងតាមលំដាប់ដរាបដល់វេនទី ... ចួបមកដល់វេនទី ១ វិញ ។ ការត្រួតត្រាករណីយកិច្ចនេះជាភារៈលើមេក្រុមមួយៗដែលត្រូវវេន ៗ មួយយ៉ាងទៀត សង្ឃ-ករណីយកិច្ចដទៃក្រៅពីនេះ ជាសាធារណៈក្នុងវត្ត ដែលមានមួយដងមួយកាល ក៏ត្រូវមេក្រុមទាំងអស់យកចិត្តទុកដាក់ជួយធ្វើដែរ ។

៥- អំពីការសំអាតទីជុំវិញកំផែងវិហារ

កុដិណាដែលនៅពីខាងក្រៅជិតកំផែងវិហារ, បើកុដិនោះនៅក្នុងក្រុមណា, ត្រូវមេក្រុមនោះតម្រូវឲ្យបោសសម្អាតផ្លូវប្រចកំផែងវិហារគ្រប់

មុខកុដិរបស់ខ្លួនឲ្យស្អាតជានិច្ច ។

### ៦. អំពីរបងរាល់កុដិ

របងដែលធ្លាប់តែមានតាមនាទីដីរាល់កុដិ រៀងមកហើយក៏ត្រូវឲ្យនៅមានដូចនោះសិនចុះ, ប៉ុន្តែត្រូវរៀបចំ តម្រឹមតម្រង់ឲ្យរៀបរយតាមផ្លូវតាមរបៀបកុំឲ្យទាស់ទំនង, ចាំងឃ្នងឬទ្រុងសម្រាប់ទុកអុសជាដើមបើមាន, ក៏ត្រូវរៀបចំឲ្យស្រួលបួលដូចរបងដែរ, បើទាស់ទំនង, ត្រូវតែរុះរើចេញតាមការតម្រូវរបស់ក្រុមជំនុំរៀបចំវត្ត ។ ដែលនឹងដាំឈើ ឬធ្វើរបងក្នុងវត្តនោះត្រូវមានអនុញ្ញាតពីចៅអធិការទើបដាំឬធ្វើបាន ។

### ៧. អំពីសណ្តាប់ធ្នាប់ក្នុងវត្ត

www.elibraryofcambodia.org

សព្វថ្ងៃនេះ ពួកក្មេងក្នុងវត្ត ច្រើនតែឥតរបបមិនត្រូវបែបបទ មកពីការបណ្តែតបណ្តោយ ។ ដោយហេតុនេះត្រូវមេកុដិទាំងអស់ខ្នានប្រៀនប្រដៅក្មេងដែលនៅក្នុងរក្សខ្លួនឲ្យមានសណ្តាប់ធ្នាប់ល្អ កុំឲ្យឥតរបប ។ រាល់កុដិ បើឃើញក្មេងវត្តក្តី មនុស្សមកពីក្រៅក្តី លេងល្បែងផ្សេងៗមានល្បែងអាប៉ោងជាដើម ឬសំដែងអាការឥតរបបនៅកុដិរបស់ខ្លួន, ត្រូវស្តីថាហាមប្រាមភ្លាមៗកុំបណ្តែតបណ្តោយ ត្រូវសួរបញ្ជាក់ឲ្យដឹងថាក្មេងនោះនៅកុដិណា ឬមនុស្សនោះមកពីណា, បើបានដឹងហើយត្រូវជូនដំណឹងនោះដល់មេក្រុមរបស់ខ្លួន; មេក្រុមត្រូវកត់សម្គាល់តាមដំណើរដែលមេកុដិនោះឲ្យដំណឹង, បើក្មេងនោះនៅកុដិក្នុងក្រុមរបស់ខ្លួន, ត្រូវរំឭកហាមប្រាមបញ្ញត្តឲ្យមេកុដិនោះស្តីប្រដៅក្មេងនោះ

កុំឲ្យប្រព្រឹត្តដូច្នោះទៀត ។ បើក្មេងនោះនៅកុដិក្រៅពីក្រុមរបស់ខ្លួន, ត្រូវឲ្យមេក្រុមនោះប្រគេនដំណឹងដល់ទៅអធិការៗ នឹងបាឋបញ្ញត្តដល់មេក្រុមជានាយកលើមេកុដិដែលក្មេងនោះនៅ ឲ្យស្តីប្រដៅក្មេងនោះឲ្យមានសណ្តាប់ធ្នាប់ល្អឡើង ។

៨. អំពីការហាមប្រាមមិនឲ្យដើរលេង

មេកុដិមួយៗត្រូវហាមប្រាមភិក្ខុសាមណេរដែលនៅក្នុងកុដិរបស់ខ្លួន ឲ្យយ៉ាងតឹងតែងកុំឲ្យដើរលេងតាមផ្សារផ្សាជាដើម ដោយឥតការ, ត្រូវបញ្ញត្តដោយដាច់ខាតថា បើមានការចេញទៅណា (ខុសពីដំណើរការសិក្សាជាប្រក្រតី) ត្រូវតែលាមេកុដិនឹងខានពុំបាន, មេកុដិត្រូវបញ្ជាក់ការឲ្យច្បាស់ប្រាកដ, បើឃើញថាមិនគួរនឹងបើកឲ្យទៅទេ, ត្រូវឃាត់កុំឲ្យទៅឲ្យសោះ ។ មេកុដិទាំងអស់ត្រូវយកចិត្តទុកដាក់ដាស់តឿនក្រើនរំឭកភិក្ខុ-សាមណេរក្នុងពួករបស់ខ្លួន ឲ្យពេញចិត្តស្រឡាញ់សិក្ខាបទក្នុងបាតិមោក្ខជាដើម កុំឲ្យហ៊ានប្រព្រឹត្តពាយឆាយតាមអំពើចិត្ត ។

៩. អំពីដើរបិណ្ឌបាត

មេក្រុមមួយៗត្រូវរំឭកមេកុដិឲ្យរឿយៗ អំពីការហាមប្រាមមិនឲ្យភិក្ខុសាមណេរក្នុងកុដិនីមួយៗដើរបិណ្ឌបាតឥតសណ្តាប់ធ្នាប់ មានការដើរលុកលុយដជ្រែកមមកក្នុងទីប្រជុំផ្សារ និងការចូលជ្រៀតជ្រែកដណ្តើមបាយគ្នាជាដើម ។ ត្រូវឲ្យមេកុដិទាំងអស់យកចិត្តទុកដាក់ប្រិតប្រៀនប្រដៅភិក្ខុ-សាមណេរគ្រប់រូបឲ្យពេញចិត្ត ប្រព្រឹត្តកាន់តាមច្បាប់វិន័យសេក្ខិយ-

www.elibraryofcambodia.org

វត្ត កុំឲ្យប្រព្រឹត្តតាយឆាយខ្ជីខ្ជា តាមតែអំពើចិត្តខ្លួន ពុំគោរពកោតក្រែង ច្បាប់នោះឡើយ ។

## ១០- អំពីការចូលធ្វើឧបោសថកម្ម

ដល់ថ្ងៃឧបោសថ ភិក្ខុគ្រប់រូបពល់កុដិត្រូវចូលកាន់ទីប្រជុំធ្វើឧបោ-សថកម្មកុំខាន វៀរលែងតែមានកិច្ចធុរៈនិងវេលាដែលមិននៅ ឬភិក្ខុណាមួយត្រូវឧក្ខេបនីយកម្ម ។ ដល់ថ្ងៃឧបោសថម្តងៗបើមានកិច្ចធុៈមិនអាចនឹងចូលកាន់ទីប្រជុំធ្វើឧបោសថកម្មបានទេ, ត្រូវប្រគេនដំណឹងដល់មេកុដិដែលខ្លួននៅ; បើមេកុដិ, ត្រូវប្រគេនដំណឹងដល់មេក្រុម; បើមេក្រុម, ត្រូវប្រគេនដំណឹងដល់លោកអធិការ ដើម្បីឲ្យផ្តុំសង្ឃបានដឹងថាមានកិច្ចធុរៈឬមិននៅ ។ មេកុដិមួយៗត្រូវយកចិត្តទុកដាក់ប្រឹងប្រែងដាស់តឿនក្រើនរំឭកភិក្ខុជាបរិស័ទដែលនៅក្នុងឱវាទរបស់ខ្លួន ឲ្យមានសេចក្តីពេញចិត្តក្នុងការធ្វើឧបោសថកម្ម ។ បើភិក្ខុណាដែលមេកុដិរំឭកដាស់តឿនញឹកញយហើយនៅតែមិនទទួលប្រតិបត្តិតាម, នោះត្រូវមេកុដិឲ្យដំណឹងដល់មេក្រុមៗត្រូវជួយរំឭកដាស់តឿនតាមធម៌វិន័យនិយាយពន្យល់ភិក្ខុនោះដោយសព្វគ្រប់, បើនៅតែមិនទទួលស្តាប់ នៅតែមិនប្រព្រឹត្តតាមឱវាទទេ, ត្រូវឲ្យបណ្តេញភិក្ខុនោះចេញ លែងឲ្យនៅក្នុងវត្តនេះតទៅទៀត ដោយលោកអធិការបានយល់ព្រមផង ។

មួយយ៉ាងទៀត ត្រូវមេកុដិទាំងអស់ឧស្សាហ៍ឲ្យឱវាទប្រិតប្រៀន-ប្រដៅភិក្ខុ-សាមណេរនិងក្មេង ដែលនៅក្រោមឱវាទរបស់ខ្លួនឲ្យមាន

www.elibraryofcambodia.org

អភិសមាចារិកវត្តរៀបរយល្អ ឲ្យចេះគោរពគ្នា ចេះសង្គ្រោះគ្នា តាមចាស់-ក្មេង តាមភេទបព្វជិតនិងគ្រហស្ថ, កុំបណ្តែតបណ្តោយឲ្យប្រព្រឹត្តប្រឡោងខាមពាយផាយ តាមតែអំពើចិត្តនោះឡើយ ។

## ១១- អំពីការប្រជុំម្តងៗក្នុងវត្ត

ក្នុងឱកាសដែលមានការប្រជុំម្តងៗចំពោះកិច្ចការជាសាធារណៈក្នុងវត្តទាំងមូល, សូមអស់លោកជាមេកុដិ និងមេក្រុម និមន្តទៅកាន់ទីប្រជុំដោយខ្លួនឯង ឲ្យទៀងទាត់តាមម៉ោងពេលដែលកំណត់ កុំចាត់លោកឯ-ទៀតឲ្យទៅជំនួស, វៀរលែងតែមានធុរៈដោយជម្ងឺឈឺចាប់ផ្ទាល់លើខ្លួន ឬមានកិច្ចធុរៈណាមួយដែលជាឧបសគ្គ រាំងដំណើរមិនឲ្យទៅកាន់ទីប្រជុំបាន, បើមិនដូច្នោះទេ, ត្រូវតែនិមន្តទៅកាន់ទីប្រជុំនោះកុំខានឲ្យសោះ ។ សេចក្តីត្រង់នេះត្រូវឲ្យអស់លោកមេក្រុមសង្កេតមើលភិក្ខុអបរិហានីយធម៌ក្នុងគម្ពីរអង្គុត្តរនិកាយ ឲ្យជាក់លាក់ផង ទើបអាចនឹងប្រតិបត្តិក្នុងសង្ឃ-ករណីយកិច្ចនេះឲ្យពេញលេញមិនឆ្គង ។

## ១២- អំពីទទួលបញ្ញើនិងការរំលងគយ

បើមានគ្រហស្ថយកទ្រព្យរបស់ណាមួយមកសុំផ្ញើទុកក្នុងកុដិ ដោយលក្ខណៈជារបស់ផ្ញើពេញទី, មេកុដិណាមួយមិនត្រូវទទួលបញ្ញើនោះឡើយ ។ មួយទៀត ត្រូវលោកមេកុដិ ហាមប្រាមដោយដាច់ខាតកុំឲ្យភិក្ខុសាមណេរហ៊ានលាក់បិទបាំងរបស់ដែលត្រូវជាប់ពន្ធមានថ្នាំខែរជាដើម ទោះបីរបស់ខ្លួនក្តី របស់គ្រហស្ថក្តី បើមានលក្ខណៈនិងទម្ងន់ដែល

ត្រូវតែបង់ពន្ធ ត្រូវទៅបង់ពន្ធជាដរាប ៗ មួយយ៉ាងទៀតរបស់អ្វីដែលមានទំនងពុំគួរជាវពុំគួរទិញ, ក៏ត្រូវកុំជាវកុំទិញជាដាច់ខាត មានរបស់ដែលជាប់មន្ទិលសង្ស័យថាបានមកពីលួចជាដើម ៗ

---

## វគ្គទី ៤

## សង្ឃកិច្ច

### របៀបគេនិមន្តឲ្យចូលខ្លួន

តាមច្បាប់ ទោះបីក្នុងផ្លូវអាណាចក្រក្ដី ក្នុងផ្លូវពុទ្ធចក្រក្ដី បើមានការតម្រូវឲ្យនិមន្តទៅជាផ្លូវរាជការ, ត្រូវតែពើឲ្យណាស់ កុំគប្បីធ្វេសប្រហែស មិនទៅមិនឆ្លើយដូចយ៉ាងទម្លាប់សព្វថ្ងៃនេះ ដែលទំនងប្រកាន់បក្សពាក្រ-អែស ច្រើនតែចូលចិត្តតាត់បម្រើឲ្យទៅជំនួសខ្លួន ឬខ្លះពុំសូវយកចិត្តទុកដាក់នឹងទៅផងទៀតនោះឡើយ ៗ អាកប្បកិរិយាបែបនេះ ជាការមើលងាយ ទាំងជាការនាំឲ្យធ្លាក់សទ្ធារបស់អ្នកដែលត្រូវការប្រាស្រ័យជាមួយផង, ដ្បិតថាការប្រជុំក្នុងទីសន្និបាតណាមួយ ជាការនាំឲ្យមានសាមគ្គីរវាងគ្នានឹងគ្នា, សេចក្ដីចម្រើនក៏នឹងកើតឡើងប្រាកដ, សេចក្ដីវិនាសរមែងមិនកើតមាន, ព្រមទាំងជាទម្លាប់ល្អដល់សិស្សានុសិស្ស ជាខាងក្រោយផង ៗ កិច្ចទាំងអស់នេះសឹងមានសំដែងក្នុងអបរិហានិយធម៌ស្រាប់ ដែលព្រះអង្គទ្រង់ប្រារព្ធចំពោះភិក្ខុទាំងឡាយថា :

យាវកីវញ្ច ភិក្ខវេ ភិក្ខូ អភិណ្ហាសន្និបាតា

www.elibraryofcambodia.org

ភវិស្សន្តិ សន្និបាតពហុលា, វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ល។

ម្នាលភិក្ខុទាំងឡាយ, បើពួកភិក្ខុនឹងមានការប្រជុំគ្នារឿយ ៗ ព្រមទាំងសម្បូរដោយការប្រជុំគ្នា អស់កាលត្រឹមណា, ម្នាលភិក្ខុទាំងឡាយ សេចក្ដីចម្រើនមែនពិត នឹងកើតប្រាកដដល់ពួកភិក្ខុ, ឥតមានសេចក្ដីវិនាសឡើយ (អស់កាលត្រឹមនោះ) ។

---

## វគ្គទី ៤

### ១. សៀវភៅដែលត្រូវឲ្យមាន

ក្នុងវត្តនីមួយ ៗ ត្រូវបង្កើតសៀវភៅដូចតទៅនេះ ៖ www.elibraryofcambodia.org

ក ) សៀវភៅសំណៅសំបុត្រចូល ១

ខ ) ” សំណៅសំបុត្រចេញ ១

គ ) ” គមិកភិក្ខុ-សាមណេរចេញពីវត្ត ១

ឃ ) ” អាគន្តុកភិក្ខុ-សាមណេរចូលមកកាន់វត្ត ១

ង ) ” ចុះលេខធាយា ១

ច ) ” ចុះលេខសន្សំដីកា ១

ឆ ) ” បញ្ជូនលិខិត ១

ជ ) ” រាយនាមភិក្ខុ-សាមណេរនិងក្មេងវត្ត ១

ឈ ) ” ចុះទឹកប្រាក់ចំណូល-ចំណាយ (កាន់រួបរួមនឹងអាចារ្យវត្ត) ១

២. សៀវភៅនីមួយ ៗ ត្រូវចាប់ប្រើពីថ្ងៃទី ១ ខែមករា (ដាក់លេខ) ១

ទៅទល់នឹងថ្ងៃ ៣១ ខែធ្នូ ។ នៅថ្ងៃ ៣១ធ្នូ ត្រូវបញ្ឈប់ជាដរាបត្រឹមលេខចុងក្រោយបំផុត ដូចមានគម្រូខាងក្រោមនេះ :

“បញ្ឈប់សៀវភៅនេះត្រឹមលេខ . . . នៅថ្ងៃ . . . ខែ . . . ឆ្នាំ . . . ”

នាម ហត្ថលេខា និងត្រាចៅអធិការ

ដល់ចូលឆ្នាំថ្មីបើសៀវភៅនេះនៅសល់, ត្រូវប្រើសៀវភៅនេះដដែល, តែត្រូវចុះលេខ ១ ជាថ្មី ចាប់តាំងពីថ្ងៃ ១ មករា, ហើយត្រូវបញ្ឈប់នៅថ្ងៃ៣១ធ្នូ ត្រឹមលេខចុងបំផុត ដូចឆ្នាំដែលកន្លងទៅហើយ រៀងរាប់ដរាបទៅ ។

៣– មុខងារគ្រូសូត្រស្ដាំ-ឆ្វេងនិងចៅអធិការ

www.elibraryofcambodia.org

ក) គ្រូសូត្រស្ដាំត្រូវកាន់សៀវភៅសំណៅសំបុត្រចេញ-ចូល, លេខធាយា-សង្ឃដីកា, បញ្ជីរាយនាមភិក្ខុ-សាមណេរក្នុងវត្តនិងសៀវភៅគមិកៈអាគន្តុកៈ ចេញចូល ព្រមទាំងត្រួតត្រាវត្ថុទាំងមូលជំនួសចៅអធិការ ។

ខ) គ្រូសូត្រឆ្វេងត្រូវកាន់បញ្ជីគរុភណ្ឌព្រមទាំងត្រួតត្រាមើលបញ្ជីប្រាក់ចំណូលចំណាយរួបរួមជាមួយនឹងអាចារ្យវត្ត ។

គ) គ្រូសូត្រឆ្វេងត្រូវត្រួតត្រាសាលាសិក្សាទាំងអស់ក្នុងវត្តព្រមទាំងប្រាស្រ័យទៅកាន់រាជការមុខក្រសួងខាងសិក្សា ហើយសម្អាតទីវត្តជួសជុលប្តូរសង់សេនាសនៈ រួបរួមជាមួយអាចារ្យវត្ត ។

៤ – មុខក្រសួងចៅអធិការត្រូវត្រួតត្រាទូទៅក្នុងវត្តទាំងមូលរួបរួមជាមួយនឹងគ្រូសូត្រ ស្ដាំ-ឆ្វេង ត្រូវចុះហត្ថលេខា លើលិខិតចេញ-ចូលផ្សេងៗ ទៅកាន់រាជការអាណាចក្រនិងពុទ្ធចក្រ ដោយទទួលខុសត្រូវ

ផ្ទាល់ខ្លួន, ត្រូវចេញមុខទៅប្រាស្រ័យនឹងពួកបរិស័ទ មានឥស្សរជន អនុគណ មេគណ និងចៅហ្វាយស្រុក ចៅហ្វាយខេត្តជាដើម ក្នុងកិច្ចការទាំងពួង, បើមានធុរៈ ត្រូវចាត់គ្រូសូត្រស្តាំឬឆ្វេងឲ្យទៅជំនួសខ្លួន

បណ្ណាល័យវត្ត.— ត្រូវបង្កើតតុ ទូ សម្រាប់តម្កល់គម្ពីរដីកាមានគម្ពីរព្រះត្រៃបិដកជាដើម ឧស្សាហ៍ស្វែងរកសន្សំគម្ពីរដែលខ្វះខាតសម្រាប់សិស្សគណរៀនសូត្រ កុំឲ្យមានខ្វះមុខណាឡើយ ទុកជាសម្បត្តិវត្ត ដូចគ្នានឹងអ្នកជំនួញលក់ ដូរ ដែលមានឃ្លាំងសម្រាប់ដាក់ទំនិញតែងស្វែងរកទំនិញគ្រប់មុខ យកមកទុកសម្រាប់តម្រូវដល់អ្នកទិញដូរដូច្នោះដែរ ។

បណ្ណាល័យ មានប្រយោជន៍ដ៏សំខាន់របស់ចៅអធិការ-អនុគណ-មេគណ មិនត្រឹមតែ ដើម្បីតម្កល់គម្ពីរក្បួនខ្នាតប៉ុណ្ណោះទេ គឺមានប្រយោជន៍សម្រាប់ទុកដាក់បញ្ជីផ្សេង ៗ មានលិខិតចេញចូលក្តី សង្ឃប្រកាសក្តី ឬសារាចរ ក្រិត្យ ក្រមជាដើមក្តី ។ លិខិតអស់ទាំងនេះត្រូវទុកដាក់រក្សាឲ្យមាំមួនកុំឲ្យបាត់ ទុកជាកស្តុតាង ហើយត្រូវរៀបចំទុកដាក់តាមរឿងដែលស្របរឿងគ្នា គឺដាក់ក្នុងក្រដាសទ្រនាប់តាមសំណុំរឿងនោះ ៗ កុំឲ្យច្របូកច្របល់គ្នា ឲ្យទៅជារបៀបងាយនឹងរើរកឆាប់ឃើញផង ។ កាលបើយើងមានតុ-ទូ ទុកដាក់មានរបៀបហើយ, សូម្បីតែមនុស្សណាក្រៅពីខ្លួនយើងអ្នកកាន់កាប់បញ្ជី ក៏នឹងអាចទៅរកឃើញសំណុំរឿងទាំងនោះបានដោយស្រួល ។

មួយទៀត នៅក្នុងបន្ទប់ធ្វើការ គួរបង្កើតតារាងសម្រាប់បិទឈ្មោះ

www.elibraryofcambodia.org

ភិក្ខុ-សាមណេរ ឬក្មេងក្នុងវត្ត ឬឈ្មោះវត្តនិងចំនួនវត្តដែលត្រូវឡើង គឺនៅក្នុងអំណាចត្រួតត្រារបស់ខ្លួនដែលជាអនុគណ ឬមេគណ ព្រមទាំងចំនួនភិក្ខុសាមណេរក្នុងវត្តនីមួយៗ ។ ត្រូវឲ្យមានផែនទីប្រទេសកម្ពុជាមួយព្យួរនៅជញ្ជាំងសម្រាប់មើលផែនទី ភូមិ-ស្រុក-ខេត្ត; ធ្វើតារាងកម្រិតសម្រាប់បង្អុលឲ្យដឹងចំនួនភិក្ខុ-សាមណេរដែលមានចំនួនកើនលើសឬថយក្នុងឆ្នាំនីមួយ ៗ ដើម្បីសម្គាល់បានឆាប់រហ័ស កាលបើក្រឡេកភ្នែកមើលទៅអាចនឹងដឹងចំនួនថយឬកើន (ចូរមើលគម្រូតារាងខាងមុខពន្យល់ឲ្យធ្វើតាម) ។

មួយទៀត កាលបើមានហេតុកើតឡើងក្នុងវត្ត(១) ត្រូវប្រញាប់ប្រញាលប្តឹងមេឃុំដែលនៅជិតនោះជាមុន ហើយសឹមប្តឹងទៅនាយចៅហ្វាយរបស់ខ្លួនផ្ទាល់ជាក្រោយ ហើយត្រូវធ្វើសេចក្តីកត់ហេតុរួមជាមួយនឹងគ្រូសូត្រឬមេឃុំឲ្យជាសាក្សីដឹងឮជាមួយផង ។

អំពីប្រឆួនឆាយាឬសង្ឃដីកាដែលវិនាស

កាលបើឆាយាឬសង្ឃដីកានោះអន្តរាយដោយហេតុអ្វីមួយ ចៅអធិការត្រូវចេញឆាយាឬសង្ឃដីកាជាថ្មីដែលហៅថា "ប្រឆួន" ឲ្យទៅរូបភិក្ខុឬសាមណេរ ដែលធ្វើឲ្យបាត់ឬវិនាសនោះដោយចម្លងតាមតែគម្រូដើម គឺចម្លងពីក្បាលសៀវភៅដើមកុំឲ្យល្អៀងសោះឡើយ គឺយកតាមលេខ, ថ្ងៃ,ខែ,ឆ្នាំរបស់ឆាយាឬសង្ឃដីកាដើមទាំងអស់ កុំរលុប កុំកែប្រែ គ្រាន់

(១) ដូចជារឿងភិក្ខុសាមណេរទាស់គ្នាឯង ឬជាមួយនឹងគ្រហស្ថ ឬមួយមានការរោរលួចប្លន់ ឬភ្លើងឆេះជាដើម ។

តែថែមនាម ហត្ថលេខា និងត្រាចៅអធិការអ្នកចម្លងប៉ុណ្ណោះ ។

| | |
|---|---|
| ឧបមាដូចជាឆាយាចាស់ឬឆាយាដើមរបស់ភិក្ខុឈ្មោះសុខ - សាន្ត នាមឆាយា(ព្រហ្មគ្រូ) អាយុកាលបួស២១ឆ្នាំ កុដិឃុំសោម ស្រុកគិរីវង់ ខេត្តតាកែវ លេខឆាយា ៤០ ចុះថ្ងៃ ៤ ៗ ៧ ៨ ឆ្នាំកុរនពស័ក ព.ស. ២៤៩០ ត្រូវនឹងថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ១៩៤៧ ។ល។ | |
| បានចម្លងផ្ទៀងត្រឹមត្រូវ<br>តាមឆាយាដើមហើយ | ហត្ថលេខា ចៅអធិការ (ចាស់)<br>ហង្ស |
| ហត្ថលេខា ចៅអធិការ (ថ្មី) អ្នកចម្លង<br>ជា-អ៊ុំ | |

ឆាយា(១) ឬសន្លឹកដីកា[illegible]ត្រូវតែចម្លងតាមក្បាលសៀវភៅដើមទាំងអស់ ឥតមានកែប្រែថែមថយឡើយ ដូចមានគម្រូខាងលើនេះពន្យល់ស្រាប់, ហើយត្រូវសរសេរខាងលើត្រង់លេខឆាយាឬសន្លឹកដីកានោះថា " ប្រឌូន " នឹងទឹកសរសេរក្រហម ។

www.elibraryofcambodia.org

បើចៅអធិការដែលចុះហត្ថលេខាលើឆាយាឬសន្លឹកដីកាដើមនោះសឹកឬអនិច្ចធម្មទៅក្តី ចៅអធិការថ្មីនោះត្រូវចុះហត្ថលេខារបស់ខ្លួននៅត្រង់ទីផ្សេងក្បែរកន្លែងដែលចៅអធិការដើមចុះហត្ថលេខា សរសេរបញ្ជាក់ថា:

បានចម្លងផ្ទៀងត្រឹមត្រូវតាមដើមហើយ

តាមហត្ថលេខានឹងត្រាចៅអធិការ

១- បើមានរូបថតបិទនៅកន្លែងដែលសម្រាប់ទុកឲ្យបិទ គួរតែបិទរូបថត ។ ឯចៅអធិការត្រូវបោះត្រានៅជ្រុងរូបថតនោះទុកជាសម្គាល់ដូចគម្រូខាងលើនេះ ។

# គម្រូបញ្ជីប្រាក់ចំណូល(១)

| លេខរៀង | ភាយមុខចំណូល | ទឹកប្រាក់ | | ថ្ងៃ ខែ ឆ្នាំ | សេចក្ដីផ្សេង ៗ |
|---|---|---|---|---|---|
| | | រៀល | សេន | | |
| ១ | បុណ្យផ្កា | ២.៥០០ | ២២ | ៣ ១ ២ ឆ្នាំជូតអដ្ឋស័ក | |
| ២ | បុណ្យកឋិន | ២.២០០ | ៣២ | ២ ៣ ១២ ឆ្នាំជូត ——— | |
| | បូក | ៤.៧០០ | ៥៩ | (២) | |

# គម្រូបញ្ជីប្រាក់ចំណាយ

www.elibraryofcambodia.org

| លេខរៀង | ភាយមុខចំណាយ | ទឹកប្រាក់ | | ថ្ងៃ ខែ ឆ្នាំ | សេចក្ដីផ្សេង ៗ |
|---|---|---|---|---|---|
| | | រៀល | សេន | | |
| ១ | ទិញឈើធ្វើវិហារ | ១.២០០ | ៧០ | ១ ៧ ៤ ឆ្នាំឆ្លូវនព្វស័ក | |
| ៣ | ទិញស៊ីម៉ង់ត៍១០បាវ | ៧០០ | ០០ | ៤ ៩ ២ ឆ្នាំឆ្លូវ ——— | |
| ២ | ឈ្នួលរទេះដឹកដីឡាប់ | ១៥០ | ០០ | ៥ ៥ ៦ ឆ្នាំឆ្លូវ ——— | |
| | បូក . . . | ២.០៥០ | ៧០ | (៣) | |

---

១- បើសៀវភៅនេះក្រាស់ល្មមរំលែកធ្វើជាពីរផ្នែក ឲ្យរំលែកពាក់កណ្ដាលទុក, ខាងដើមទុកសម្រាប់ក
ចំណូល, ពាក់កណ្ដាលខាងក្នុង ទុកចុះទឹកប្រាក់ចំណាយ; ឬមួយធ្វើសៀវភៅចំណូល ១ ចំណាយ ១ ក៏បា

២-៣- បើទឹកប្រាក់សល់ពីឆ្នាំចាស់ចំណាយមិនអស់ កាលបើបញ្ឈប់សៀវភៅនៅចុងឆ្នាំហើយ ត្រូ
ទឹកប្រាក់សល់នោះ យកទៅចុះក្នុងប្រាក់ចំណូលនៅឆ្នាំបន្ទាប់តទៅ ។

## គម្រូបញ្ជីគុរុភណ្ឌ (របស់ដែលគេនាំមកដាក់វត្ត)[១]

| លេខរៀង | រាយមុខរបស់ | ចំនួន | ថ្ងៃខែដែលបានមក | សេចក្ដីផ្សេងៗ (២) |
|---|---|---|---|---|
| ១ | នាលិកាយោល | ២ | ២៧៥ ឆ្នាំខាលទោ– ៤ | ខូចប្រើការមិនកើតពីថ្ងៃ ... |
| ២ | ចង្កៀងមង្ស៊ុង | ៣ | | |
| ៣ | កន្ទេលក្រហមវែង | ៥ខ្សែ | | |
| ៤ | ចានទៀបបាកាំង | ៥០ | | បែកអស់ ២០ នៅថ្ងៃ ... |
| ៥ | ទូដាក់សៀវភៅ | ៣ | លោក សុមន សាងពីថ្ងៃ ១ ៣/៧៥ ឆ្នាំខាលទោ .. | |

www.elibraryofcambodia.org

## គម្រូបញ្ជីគុរុភណ្ឌ (ដែលកើតក្នុងទីវត្ត)[៣]

| លេខរៀង | រាយមុខរបស់ សវិញ្ញាណកៈ អវិញ្ញាណកៈ | ចំនួន | ថ្ងៃ ខែ ឆ្នាំ ដែលសាងហើយ | សេចក្ដីផ្សេងៗ |
|---|---|---|---|---|
| ១ | វិហារ | ១ | | |
| ២ | កុដិថ្ម | ២ | | |
| ៣ | កុដិឈើ ៤ សាលាបាលី១ | ៥ | | |
| ៤ | ដើមគគីរ១០០ដើមស្វាយ១១ | | លោក សុត ផាំពី ថ្ងៃ ៩-៧-៥ | |
| | គរ ១០ ដូង ២០ ស្លា ៣០ | ៧០ | | |

១- របស់ចូលមកពីក្រៅ ។ ២- បើរបស់នោះបាក់បែកខូច ត្រូវសរសេរត្រង់សេចក្ដីផ្សេងៗ ផ្ទួចត្រង់គម្រូនេះ ។
៣- របស់ដែលកើតមានក្នុងវត្ត ដូចសេនាសនៈនិងរុក្ខជាតិផ្សេងៗ ។

# ប្រវត្តិរូប

(គម្រូខាងក្រោមនេះជាតួយ៉ាងទុកឲ្យមើលធ្វើតាម)

| | |
|---|---|
| ១–នាមគោត្រ | ឌិន |
| ២–នាមខ្លួន | ជុំ |
| ៣–នាមបញ្ញាតិ | ជោតញ្ញោ |
| ៤–អាយុប៉ុន្មាន | ៥៤ ឆ្នាំ |
| ៥–វស្សាប៉ុន្មាន | ១៥ វស្សា |
| ៦–ថ្ងៃ ខែ ឆ្នាំដែលកើត | ថ្ងៃអាទិត្យ ខែមិគសិរ ឆ្នាំបបត្វាស័ក ព.ស. .... គ.ស. .... |
| ៧–ស្រុកកំណើត | ឃុំព្រែកពោធិសួស្តី ស្រុកស្រីសន្ធរ ខែត្រកំពង់ចាម |
| ៨–នាមមាតាបិតា | ឌិន-មៅ ឆាតសួរ |
| ៩–ទីលំនៅមាតាបិតា | ឃុំព្រែកពោធិសួស្តី ស្រុកស្រីសន្ធរ ខែត្រកំពង់ចាម |
| ១០–ថ្ងៃ ខែ ឆ្នាំ ដែល បួសជាសាមណេរ | ថ្ងៃ ២ ៤ ៣ ឆ្នាំខ្សាញ់ ទោស័កព.ស. ២៤៧០ |
| ១១– បួសជាភិក្ខុ | ថ្ងៃ ២ ៥ ៦ ឆ្នាំខាលត្រីស័ក ព.ស. ២៤៨០ |
| ១២–បួសនៅវត្តណា | វត្តព្រែកពោធិមង្គល |
| ១៣–នាមឧបជ្ឈាយ៍ | សុវណ្ណជោត ( ស៊ុន ) |

www.elibraryofcambodia.org

| | |
|---|---|
| ១៤-នាមឧបសម្បទាចារ្យ | សុវណ្ណត្ថេរ (កុល)<br>ធម្មជោត (ទៀវ) |
| ១៥-យសស័ក្តិជាដំបូង | ភិក្ខុ |
| ១៦-ងារនិងយសស័ក្តិសព្វថ្ងៃ | ភិក្ខុ |
| ១៧-មានឥស្សរិយយសអ្វីខ្លះ | គ្មាន |
| ១៨-បានរៀនចេះវិជ្ជាអ្វីខ្លះ | ចេះវិបស្សនាធុរៈ |
| ១៩-បើចេះព្រះត្រៃបិដក មានប្រយោគឬទេ ? | គ្មាន |
| ២០-បានចេះភាសាដទៃអ្វីខ្លះ | ចេះភាសាសៀមខ្លះ |
| ២១-បានគង់ប់នៅវត្តណាខ្លះ | ធ្លាប់នៅវត្តពោធិមង្គលមេធិរាបមក |
| ២២-ដែលមានទោសឬទេ | គ្មាន |
| ២៣-បានធ្វើការអ្វីខ្លះក្នុងព្រះពុទ្ធសាសនា | បានជួយសាងកុដិ-សាលា-វិហារ |

ធ្វើនៅថ្ងៃ . . . ខែ . . . ឆ្នាំ . . .

ហត្ថលេខា ចៅអធិការ(១)

បានឃើញ

ចៅហ្វាយស្រុក អនុគណ មេឃុំ

(១)សាមីរូបគឺចៅអធិការក្តី គ្រូសូត្រក្តី មេគណក្តី អនុគណក្តី ត្រូវចុះបំពេញខ្លួនឯង

www.elibraryofcambodia.org

លេខ ______________ល.គ.

ថ្ងៃទី__________ ខែ__________ ឆ្នាំ ១៩៥ ________

____________________________________________________________

____________________________ បានអនុញ្ញាតដល់ ______________

នាមបញ្ញត្តិ______________________ អាយុ__________ ឆ្នាំ វស្សា______

កាន់ ______________ លេខ ______________ សព្វថ្ងៃនៅវត្ត (១)______________

____________________________________________________________

ក្នុងក្រុម (២) ______________________ កុដិ ______________________ ឱ្យទៅកាន់

______________________________ ឃុំ ______________ ស្រុក______________

ខេត្ត ______________________ ចំនួន __________ ថ្ងៃ ដោយមានការ______________

________________________________________

www.elibraryofcambodia.org

សុំលោក (៣)______________________________

______________________ ចុះហត្ថលេខាអនុញ្ញាតតាមប្រការ ៣ នៃព្រះសង្ឃបញ្ញត្តិ

លេខ ៤ ចុះថ្ងៃទី ១១ មេសា ១៩៥២ ត្រង់អនុប្រការ (ឃ) ។

---

១- ត្រូវចុះឈ្មោះវត្ត ឃុំ ស្រុក-ខេត្ត បើក្រុងភ្នំពេញ ត្រូវចុះថាសង្កាត់លេខ . . . ក្រុងភ្នំពេញ ។ ២ បើខេត្តក្រៅមិនបាច់ដាក់ទេ ។ ៣ ចុះថា សុំលោកមេឃុំ ស្រុក-ខេត្ត, បើភ្នំពេញថា សុំលោកចៅសង្កាត់លេខ . . . . ក្រុងភ្នំពេញ ។ ល.គ. គឺលិខិតគោចរ ។

# បញ្ជីកម្រិតចំនួនភិក្ខុ-សាមណេរវាង(៧ឆ្នាំ)

| ចំនួនភិក្ខុសាមណេរ | ឆ្នាំ ១៩៥០ | ឆ្នាំ ១៩៥១ | ឆ្នាំ ៩៥២ | ឆ្នាំ ១៩៥៣ | ឆ្នាំ ១៩៥៤ | ឆ្នាំ ១៩៥៥ | ឆ្នាំ ១៩៥៦ | |
|---|---|---|---|---|---|---|---|---|
| ៥៥០ | | | | o | | | | |
| ៥០០ | | | | | | | | |
| ៤៥០ | | | | | | | | |
| ៤០០ | | | o | | | | | |
| ៣៥០ | o | | | | | | | |
| ៣០០ | | o | | | | | | |
| ២៥០ | | | | | | | | |
| ២០០ | | | | | | | | |
| ១៥០ | | | | | | | | |
| ១០០ | | | | | | | | |
| ៥០ | | | | | | | | |

www.elibraryofcambodia.org

១ ឧបមាថ្វីបជាឆ្នាំ១៩៥០ មានចំនួនភិក្ខុ សាមណេរ ៣៥០, ដល់ឆ្នាំ១៩៥១ ចំនួនភិក្ខុសាមណេរថយមកនៅត្រឹម ៣០០វិញ, ដល់ឆ្នាំ ១៩៥២ ចំនួននោះឡើងទៅ៤០០វិញ, ដល់ទៅឆ្នាំ ១៩៥៣ឡើងទៅ៥៥០ ។ ត្រូវទាញបន្ទាត់ទៅតាមខ្ទង់ចំនួនភិក្ខុ-សាមណេរ និងទៅតាមខ្ទង់ឆ្នាំខាងលើ ដោយគិតទៅតាមចំនួនភិក្ខុ-សាមណេរ ដែលឡើងចុះរាល់ឆ្នាំនោះ ។

ព្រះរាជអាណាចក្រកម្ពុជា

*

លេខ ________

(១)

សាលាគណខេត្ត ________ គណៈ ________

# ដីកាអម

បញ្ជូនមក ____________________________________

____________________________________

| រាយលិខិត | ចំនួន | សេចក្ដីផ្សេងៗ |
| --- | --- | --- |
| | | |
| | | |
| | | |
| | | |

www.elibraryofcambodia.org

វត្ត ________ ថ្ងៃ... ។ ... ឆ្នាំ ________ ស័ក ព.ស.២៤៩ ____

ត្រូវនឹងថ្ងៃទី ______ ខែ ______ គ.ស.១៩៥ ______

នាម ហត្ថលេខា និងត្រា

---

១ បើជាសាលាអនុគណវិញ ឲ្យដាក់ថា “សាលាអនុគណស្រុក ... ខេត្ត ...” ។ បើជាមុខការរបស់ចៅអធិការសាមញ្ញ ឲ្យដាក់ថា “វត្ត ... ឃុំ ... ស្រុក ... ខេត្ត ...”

ខេត្ត ____________

ស្រុក ____________ របាយការណ៍ភិក្ខុ-សាមណេរ វត្ត ____________

សង្កាត់ ____________

| លេខរៀង | គោត្តនាម និងបកតិនាម | ភិក្ខុឬ សាមណេរ | ថ្ងៃ ខែ ឆ្នាំ ដែលបួស | បដិញ្ញាណរបស់ចៅសង្កាត់ | | | | |
|---|---|---|---|---|---|---|---|---|
| | | | | លេខ | ថ្ងៃ ខែ ឆ្នាំ | ទីដែលចេញបដិញ្ញា | | |
| | | | | | | សង្កាត់ | ស្រុក | ខេ |
| | | | | | | | | |

www.elibraryofcambodia.org

(១) បញ្ជីនេះប្រើបានទូទៅ (សម្រាប់ចុះភិក្ខុសាមណេរដែលនៅចាំវស្សាក្តី ឬប្រើជាបញ្ជីផ្លាស់ឆ្នាំក្តី) ។

(២) ត្រង់សេចក្តីផ្សេង ៗ នេះ ត្រូវចុះទីលំនៅនិងថ្ងៃខែឆ្នាំរបស់បព្វជិតដែលមកសុំសំណាក់ ឬចាកសិក្ខាបទ

ចាំវស្សាក្នុងវត្ត . . . . ឆ្នាំនេះ មានចំនួន . . . ច្បាប់ តាមបង្គាប់ពី . . .

លេខ . . .ចុះថ្ងៃ . . . . ខែ . . . ឆ្នាំ . . . ដើម្បីបញ្ជូនចូលទៅក្រសួង

នាម ហត្ថលេខា និងត្រា

ចៅអធិការ

ាវៀ (១)

______ដែលគង់នៅសព្វថ្ងៃ ។

| ណា / ខេត្រ | ឆាយាឬសង្ឃដីកា | | | | | អាយុ | វស្សា | សេចក្ដីផ្សេង ៗ (២) |
|---|---|---|---|---|---|---|---|---|
| | លេខ | ថ្ងៃ ខែ ឆ្នាំ | ទីលំនៅឧបជ្ឈាយ៍គង់ | | | | | |
| | | | សង្កាត់ | ស្រុក | ខេត្រ | | | |
| | | | | | | | | |

ព.ស. ២៥១______

ធ្វើនៅវត្ត ______ ថ្ងៃទី ______ ខែ ______

www.elibraryofcambodia.org

គ.ស. ១៩៦______

ចៅអធិការវត្ត

។

វត្ត______ ថ្ងៃ... ។ ... ឆ្នាំ______ ស័ក ព.ស. ២៤៩______

ត្រូវនឹងថ្ងៃទី______ ខែ______ គ.ស. ១៩៥______

តាម ហត្ថលេខា និងត្រា

១ បើជាសាលាអនុគណវិញ ឲ្យដាក់ថា "សាលាអនុគណស្រុក ... ខេត្រ ..." ។ បើជាមុខការរបស់ចៅអធិការសាមញ្ញ ឲ្យដាក់ថា "វត្ត ... ឃុំ ... ស្រុក ... ខេត្ត ..."

## វគ្គទី ៦

## គម្រូសំបុត្រក្នុងដំណើរពុទ្ធចក្រ ឬ អាណាចក្រ
## ចៅអធិការសរសេរទៅចៅសង្កាត់

លេខ . . .

វត្ត ...... នៅថ្ងៃ ... ។ ... ឆ្នាំ .... ស័ក

ត្រូវនឹងថ្ងៃទី . . . ខែ . . . ព.ស. ២៥៩ . . . / គ.ស. ១៩៥ . . .

ចៅអធិការវត្ត . . . . . . សង្កាត់ . . . . ស្រុក . . . .

www.elibraryofcambodia.org

ខេត្ត . . .

ចំរើនពរមកលោក ចៅពញារក្សាគិបាល ចៅសង្កាត់ . . .

ជ្រាប ។

អាត្មាភាពសុំជូនភ្ជាប់មកជាមួយនេះបញ្ជីភិក្ខុសាមណេរ ដែលនៅចាំវស្សាក្នុងវត្ត . . . . ឆ្នាំនេះ មានចំនួន . . . ច្បាប់ តាមបង្គាប់ពី . . . លេខ . . .ចុះថ្ងៃ . . . . ខែ . . . ឆ្នាំ . . . ដើម្បីបញ្ជូនចូលទៅក្រសួង

នាម ហត្ថលេខា និងត្រា

ចៅអធិការ

គម្រូសំបុត្រចៅអធិការសរសេរទៅចៅហ្វាយស្រុក

ឆ្លើយដោះសាពីភិក្ខុកាន់ឆាយាពុំត្រឹមត្រូវ

លេខ...

វត្ត.... នៅថ្ងៃ... ៗ .. ឆ្នាំ .. ស័ក ព.ស. ២៤៩....

ត្រូវនឹងថ្ងៃទី..ខែ... ឆ្នាំ១៩...

ចៅអធិការវត្ត .. សង្កាត់.... ស្រុក... ខេត្ត...

ចម្រើនពរបួលមកលោកអ្នកឧកញ៉ា(១) .....ចៅហ្វាយស្រុក ....

សូមជ្រាប ។

www.elibraryofcambodia.org

តាមបញ្ជីបរិយាយស្រុក លេខ១... ចុះថ្ងៃ... ខែ... ឆ្នាំ... ដែលឲ្យឆ្លើយពត៌មានរបស់ភិក្ខុឈ្មោះ.... ដែលជាប់ចោទសង្ស័យពីកាន់ឆាយាដោយមានកោសល្យប ព្រមទាំងកាន់លិខិតដើរផ្លូវហួសកំណត់ ។

ឯភិក្ខុ ឈ្មោះ... នេះ ពិតជាបានបួសរៀនក្នុងពុទ្ធសីមាវត្ត ... នេះមែន កាន់ឆាយាលេខ... ចុះថ្ងៃ... ខែ... ឆ្នាំ...

ឯឆាយានោះអាត្មាភាពបានសរសេរកត់ប្រថ្យមានកោសល្យបខ្លះ តែមិនបានចុះហត្ថលេខាបញ្ជាក់ត្រង់កន្លែងកោសល្យបនោះដោយល្ងង់ខ្លៅ ។ ចំណែកលិខិតគោចរដែលហួសកំណត់ថ្ងៃខែនោះ គឺភិក្ខុ.... នេះ

(១) ត្រូវចុះទៅតាមគោរមងារនោះ ៗ ។ លោកចៅហ្វាយស្រុកខ្លះទីព្រះ ខ្លះទីឧកញ៉ា, ដើម្បីសរសេរទៅកុំឲ្យខុស ស្រេចនឹងមើលបុគហ្វាយពីសាលាស្រុកផង ។

បានលាអាត្មាភាពថាទៅសួរញាតិញោមឯស្រុក... តែត្រឹមកំណត់ ៣ ខែ ឥឡូវស្រាប់តែបាត់យូរហួសច្បាប់ ។ ពីកិរិយាមារយាទរបស់ភិក្ខុនេះជាសិស្សអាត្មាភាពធ្លាប់មានមារយាទសុចរិតល្អ ពុំធ្លាប់មានរឿងក៏អ្វីទេ ។ សូមពជការត្រាប្រណីទោសជាដំបូងនេះឲ្យបាន បើពុំមានរឿងអ្វីធ្ងន់ក្រៅពីនេះទេ ។

តាម ហត្ថលេខានិងត្រា ចៅអធិការ

x x x

## គម្រូសំបុត្រចៅអធិការសរសេរទៅលោកគ្រូ
## អនុគណ ឬ មេគណ

www.elibraryofcambodia.org

លេខ...

វត្ត... នៅថ្ងៃ... ។ ... ឆ្នាំ.. ស័ក ព.ស. ២៥៩...

ត្រូវនឹងថ្ងៃទី... ខែ... ឆ្នាំ... ១៩៦...

ចៅ ធិការ វត្ត... សង្កាត់... ស្រុក .. ខេត្ត...

សូមនមស្ការចូលមក

ព្រះតេជព្រះគុណ ព្រះ... អនុគណ(១) ស្រុក...

សូមបានជ្រាប ។

សូមបញ្ជូនភិក្ខុឈ្មោះ .. ១ ភិក្ខុ... ១ ភិក្ខុ... ១ ទាំង ៣ រូបនេះ ឲ្យចូលមករៀនធម្មវិន័យតាមសង្ឃដីកាបង្គាប់ពីសាលាអនុគណ(២)

---

១- បើសរសេរទៅលោកគ្រូមេគណ, ត្រូវថាមេគណខេត្ត ។ ២- បើសង្ឃដីកាបង្គាប់ពីលោកគ្រូមេគណ, ត្រូវថាសាលាមេគណ ។

លេខ . . . ចុះថ្ងៃ... ខែ... ឆ្នាំ... ដែលតម្រូវឲ្យចូលទៅរៀនគឺ ភិក្ខុ ... រៀនកំណត់មួយឆ្នាំ, ភិក្ខុ... រៀនកំណត់ ២ ឆ្នាំ, ភិក្ខុ . . . រៀនកំណត់ ៣ ឆ្នាំ ។

មួយទៀតសូមបញ្ជូនតុមួយមកសម្រាប់អង្គុយរៀនព្រមទាំងស្បៀងអាហារសម្រាប់ភិក្ខុទាំង ៣ រូបនេះផង ។

សូមមេត្តាទទួលចុះឈ្មោះភិក្ខុទាំង ៣ រូបនេះក្នុងបញ្ជីសិស្សសាលាធម្មវិន័យឲ្យបានតាមការ ។ ឯស្បៀងអាហារដែលខ្វះខាតទៅអនាគតនឹងចាត់ឲ្យអាចារ្យវត្តរៃអង្គាសបញ្ជូនមកបណ្ដើរ ៗ ។

តាម ហត្ថលេខានិងត្រា ចៅអធិការ

www.elibraryofcambodia.org

※※※

មេគណសរសេរទៅចៅអធិការ ឬ អនុគណ

លេខ...

វត្ត... ទៅថ្ងៃ... ៗ ... ឆ្នាំ... ស័ក ព.ស. ២៤៩...

ត្រូវនឹងថ្ងៃទី.... ខែ... ឆ្នាំ ១៩៥ ..

ព្រះ... មេគណខេត្ត...

ពិតមកចៅអធិការគ្រប់វត្តក្នុងខេត្ត

បានជ្រាប ។

ដ្បិតមានព្រះសង្ឃប្រកាសលេខ... ចុះថ្ងៃ... ខែ... ឆ្នាំ១៩៥... រំលឹកហាមប្រាមដល់អស់បព្វជិតទាំងឡាយ ដែលលង់ទៅក្នុងផ្លូវនយោ-បាយនិងដោយការឃោសនាអកុសលរបស់ពួកឧទ្ទាម ហើយពោលពាក្យ

បរិហាររិះគន់ចំពោះរដ្ឋាភិបាលបច្ចុប្បន្ន ហើយថែមទាំងជួយជ្រោមជ្រែងដល់ពួកឧទ្ទាមឲ្យយល់ឃ្លាងពីឧត្តមគតិរបស់រដ្ឋាភិបាល សឹងដូចមានព្រះសង្ឃប្រកាសផ្សឹកជាប់នៅនេះស្រាប់ ៗ

សុំឲ្យព្រះអនុគណនិងចៅអធិការគ្រប់វត្ត ប្រជុំបព្វជិតក្នុងវត្តរៀងខ្លួន ហើយសូត្រសង្ឃប្រកាសនេះឲ្យស្តាប់គ្រប់អង្គ ព្រមទាំងដាក់កម្រិតឲ្យយ៉ាងម៉ឺងម៉ាត់កុំឲ្យមានល្អៀង ៗ ល្គឹកតែបព្វជិតរូបណាប្រព្រឹត្តកន្លងព្រះសង្ឃប្រកាសនេះ, បព្វជិតរូបនោះនឹងមានកំហុសតាមច្បាប់បញ្ញត្តិ ឥតមានត្រាប្រណី ៗ

បើបានទទួលហើយ សុំឲ្យឆ្លើយតបទៅវិញថាបានប្រតិបត្តិតាមហើយ ៗ

www.elibraryofcambodia.org

ព្រះ... មេគណខេត្ត...

តាម ហត្ថលេខា និងត្រា

x x x

ចៅអធិការសរសេរទៅអនុគណ ឬមេគណ

លេខ . . .

វត្ត . . . នៅថ្ងៃ . . . ៗ . . . ឆ្នាំ . . . ស័ក ព.ស.២៤៩ . . .

ត្រូវនឹងថ្ងៃទី . . . ខែ . . . ឆ្នាំ ១៩៥ . . .

ចៅអធិការវត្ត . . . ឃុំ . . . ស្រុក . . . ខេត្ត . . .

សូមក្រាបប្រណិប័តន៍ចូលមក

ព្រះតេជព្រះគុណព្រះ . . . មេគណខេត្ត[១] . . .

១ បើសរសេរទៅលោកគ្រូអនុគណ, ត្រូវថាអនុគណស្រុក ៗ

សូមទានជ្រាប ។

សូមតបទឹងដីកាបញ្ជូនលេខ ... ចុះថ្ងៃ ... ខែ ...
ឆ្នាំ ... ដែលបញ្ជូនសង្ឃប្រកាសលេខ ... ចុះថ្ងៃ ... ខែ ...
ឆ្នាំ ... បញ្ញត្តពីភិក្ខុសាមណេរគង់វត្ត ធ្វើនយោបាយពាស់ខុសនឹងផ្លូវសាសនាចក្រ ដោយមិនសមរម្យនឹងភេទបព្វជិត នោះខ្ញុំព្រះករុណា បានប្រតិបត្តិតាមដោយហ្មត់ចត់ឥតមានល្ហែង ព្រមទាំងបានហាមប្រាមដល់ភិក្ខុសាមណេរយ៉ាងម៉ឺងម៉ាត់ ពីការគោចរទៅណាមកណាឆ្ងាយពីវត្ត ដែលត្រូវមានអនុញ្ញាតបុត្រលិខិតគោចរ(ត្រៃមាស) ដែលចៅអធិការចេញឲ្យ ទើបទៅបាន ។

www.elibraryofcambodia.org

សូមមេត្តាជ្រាបតាមការ

តាម ហត្ថលេខា និងត្រា ចៅអធិការ

※ ※ ※

ចៅអធិការសរសេរទៅអនុគណ ឬមេគណ

លេខ ...

វត្ត ... នៅថ្ងៃ ... ៗ ... ឆ្នាំ ... ស័ក ព.ស. ២៤៩ ...

ត្រូវនឹងថ្ងៃទី ... ខែ ... ឆ្នាំ១៩៥ ...

សូមតបទឹងសង្ឃដីកាលេខ .. ចុះថ្ងៃ... ខែ... ឆ្នាំ ... ដែលបង្គាប់ឲ្យចូលទៅសាលាអនុគណ[១] តាមបង្គាប់ (សង្ឃដីកាឬសំបុត្រ) លេខ ...

---

១ បើគឺការបង្គាប់ឲ្យចូលទៅទីណា, ត្រូវដាក់ទីនោះ ។

ចុះថ្ងៃ ... ខែ ... ឆ្នាំ ... ឥឡូវខ្ញុំព្រះករុណាសូមចាត់គ្រូសូត្រឈ្មោះ ... ជាគ្រូសូត្រ (១) ... ឲ្យមកជំនួស ព្រមទាំងអាចារ្យវត្ត ដើម្បីទទួលស្តាប់ការ ដោយខ្ញុំព្រះករុណាមានធុរៈ (២) ... ។

សេចក្តីគួរពុំគួរសូមអភ័យទោស

តាម ហត្ថលេខា និងត្រា

※ ※ ※

ចៅអធិការសរសេរទៅលោកអធិការបឋមសិក្សា

លេខ...

វត្ត... នៅថ្ងៃទី... ខែ... ឆ្នាំ...

ចម្រើនពរមកលោកអធិការបឋមសិក្សាខេត្ត... សូមជ្រាប ។

www.elibraryofcambodia.org

អាត្មាភាពបានចាត់គ្រូបង្រៀនសាលាវត្តឲ្យនាំកូនសិស្សវត្តចំនួន... ដូចមានបញ្ជីជា ២ ច្បាប់ជូនជាប់មកនៅនេះស្រាប់ ដែលត្រូវប្រឡង... តាមបង្គាប់សំបុត្រលេខ... ចុះថ្ងៃ.. ខែ .. ឆ្នាំ ..

តាម ហត្ថលេខា និងត្រា

※※※

ចៅអធិការសរសេរទៅអនុគណ ឬមេគណ

លេខ..

វត្ត.. នៅថ្ងៃ... ។ ... ឆ្នាំ... ស័ក ព.ស. ២៤...

ត្រូវនឹងថ្ងៃទី... ខែ.. ឆ្នាំ ១៩...

គ្រូសូត្រស្តាំស្តីទីចៅអធិការបណ្ណោះអាសន្ន វត្ត...

---

១- ស្តាំឬឆ្វេង ។ ២- ប្រាប់ឲ្យចំកិច្ចធុរៈ ។

សូមនមស្ការចូលមក

ព្រះតេជព្រះគុណព្រះ...     អនុគណស្រុក[១]...

សូមទានជ្រាប ។

សូមបញ្ជូនជាប់មកនៅនេះបញ្ជីភិក្ខុសាមណេរចំនួន ៤ ច្បាប់ដូចគ្នា ដែលមានអំណាចបោះឆ្នោតរើសចៅអធិការវត្តនេះនៅថ្ងៃ... ខែ... ឆ្នាំ... ។

នាម ហត្ថលេខា និងត្រា

x x x

អនុគណ ឬ មេគណសរសេរទៅសម្តេចព្រះសង្ឃ
www.elibraryofcambodia.org

នាយក

លេខ...

វត្ត...  នៅថ្ងៃ .. ។ ...  ឆ្នាំ...   ស័ក ព.ស. ២៤...

ត្រូវនឹងថ្ងៃទី...   ខែ...   គ.ស. ១៩...

ព្រះគ្រូ...   អនុគណ  ស្រុក...   ខេត្ត...

សូមនមស្ការក្រាបបង្គំ

ក្រោមព្រះបាទ

សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ[២]

សូមទានជ្រាប ។

---

១- បើទៅលោកមេគណជា មេគណខេត្ត ។ ២- ត្រូវកុះតាមគណៈ ។

សូមបញ្ជូនជាប់មកនៅនេះ សំណុំរឿងមានចំនួន...ច្បាប់ ដែលបានធ្វើអង្កេតរួបរួមជាមួយនឹងលោកចៅហ្វាយស្រុក ... អំពីចៅអធិការវត្ត... ជាប់ចោទថាតែបំបាត់របស់គរុភណ្ឌ(១)សម្រាប់វត្ត, ឃើញថាតាមចម្លើយសាក្សី ដែលបានស៊ើបសួរទៅ ពុំឃើញមានជាប់ពិរុទ្ធជាសំខាន់ដល់ចៅអធិការនេះទេ សឹងដូចមានសេចក្ដីកត់ហេតុសួរចម្លើយជូនមកជាប់នៅនេះស្រាប់ ។

តាម ហត្ថលេខា និងត្រា

x x x

អនុគណសរសេរទៅចៅអធិការ

លេខ...

www.elibraryofcambodia.org

វត្ត... នៅថ្ងៃ... ៗ ... ឆ្នាំ... ស័ក

ត្រូវនឹងថ្ងៃទី... ខែ... ព.ស. ២៤៩... / គ.ស. ១៩៥...

ព្រះ... អនុគណស្រុក... ខេត្ត...

ពិតមកចៅអធិការគ្រប់វត្តក្នុងស្រុក...

បានជ្រាប ៗ

ដ្បិតមានសង្ឃដីកាលេខ... ចុះថ្ងៃ... ខែ... ឆ្នាំ ១៩... ពីក្រសួងព្រះសង្ឃនាយកគណៈមហានិកាយ បញ្ជូនសេចក្ដីរំលឹកដាស់តឿនអំពីសាលាធម្មវិន័យ សម្រាប់វត្តនិមួយៗ ដែលកើតមានឡើងចាប់តាំងពីក្នុងឆ្នាំម្សាញ់បញ្ចស័ក ព.ស. ២៤៩៦ / គ.ស. ១៩៥៣ ថាសុំឲ្យលោកគ្រូ

---

១- ត្រូវចុះតាមរឿងនោះ ៗ ៗ

ចៅអធិការគ្រប់វត្តខំប្រឹងខ្នះខ្នែង ឲ្យការសិក្សានេះបានលូតលាស់ចម្រើន, ព្រោះសាលាធម្មវិន័យនេះ ជាគោលចារឹករបស់ព្រះពុទ្ធសាសនានិងអក្សរសាស្ត្រជាតិក្នុងប្រទេសកម្ពុជា ។ ត្រូវយើងនាំគ្នាខំប្រឹងប្រែងជួយឧបត្ថម្ភឲ្យពេញកម្លាំង សឹងដូចមានសេចក្តីរំលឹកដាស់តឿនក្នុងឱកាសអនុសំវច្ឆរមហាសន្និបាតទី ៩ នៃមន្ត្រីសង្ឃ ព.ស. ២៤៩៥ / គ.ស. ១៩៥២ ដែលជូនជាប់មកនៅនេះស្រាប់, បើបានទទួលហើយ, សុំឲ្យឆ្លើយចូលទៅវិញ ។

តាម ហត្ថលេខា និងត្រា

x x x

## សេចក្តីកត់ហេតុសួរចម្លើយ

ពុទ្ធសករាជពីរពាន់បួនរយកៅសិប(១)... ថ្ងៃ... ខែ... ឆ្នាំ... ស័ក ត្រូវនឹងថ្ងៃទី... ខែ... ឆ្នាំមួយពាន់ប្រាំបួនរយ... ពេលម៉ោង... ព្រឹក(២)នៅទីវត្ត...

យើងព្រះ(៣)... ចៅអធិការ វត្ត .. បានរួបរួមជាមួយនឹងលោកមេឃុំ ៗ ...សួរចម្លើយភិក្ខុឈ្មោះ... សេចក្តីដូចមានខាងក្រោម :

សួរ—នាមត្រកូលនិងឈ្មោះ

ឆ្លើយ—ខ្ញុំព្រះករុណាឈ្មោះ... នាមតាយា... អាយុ... ឆ្នាំ វស្សាបាន... បួសក្នុងពុទ្ធសីមាវត្ត .. មានលោកគ្រូនាម... ជាឧបជ្ឈាយ៍, លោកគ្រូ... ជាឧបសម្បទាចារ្យ

---

១-បំពេញថ្ងៃ ខែ ជាតួអក្សរ ។ ២-ត្រូវចុះពេលវេលា។ ៣-ត្រូវចុះគោរម្យងារអ្នកធ្វើសេចក្តី ។

www.elibraryofcambodia.org

សួរ—ពីមុនមកធ្លាប់មានរឿងក្ដីអ្វីដែរឬទេ ?

ឆ្លើយ—ពីមុនមកមិនធ្លាប់មានរឿងក្ដីអ្វីទេ (១) ។

សួរ—ចុះលោកបានសេពមេថុនធម្មជាមួយនឹងនាង . . . នៅភូមិ ... មានតាំងផ្ទៃពោះផងមែនឬទេ ?

ឆ្លើយ—បានប្រោសមិនមែនទេ ។

សួរ—ម្ដេចក៏លោកថាមិនមែន បើសាមីខ្លួននាង . . . ឆ្លើយថាខ្លួនលោកបានសហាយស្មាមកចំនួន ៥-៦ ខែហើយ ព្រមទាំងឲ្យអីវ៉ាន់ប្រចាំចិត្តផង ចូរឆ្លើយឲ្យត្រង់ !

ឆ្លើយ—មិនមែនទេ គឺនាងនេះឆ្លើយបង្កាច់ខ្ញុំព្រះករុណាដោយមានគេបញ្ចុះឲ្យឆ្លើយដាក់ ។

បញ្ឈប់សេចក្ដីកត់ហេតុនៅពេលម៉ោងដូចខាងលើ

ស្នាម ហត្ថលេខា និងត្រា មេឃុំ

ស្នាម ហត្ថលេខានិងត្រា ចៅអធិការ

※ ※ ※

សំបុត្របគារអនុគណប្ដីទៅចៅហ្វាយស្រុក

លេខ . . .

វត្ត . . . នៅថ្ងៃ . . . ។ . . . ឆ្នាំ . . . ស័ក ព.ស ២៤ ...

ត្រូវនឹងថ្ងៃទី . . . ខែ . . . ឆ្នាំ ១៩ . .

ព្រះ . . . អនុគណស្រុក . . .

---

១- បើធ្លាប់មានរឿងពីមុនមកខ្លះផង ។ បំពេញហេតុដែលគួរបំពេញទៅតាមរឿងនោះ

www.elibraryofcambodia.org

បម្រើនពរចូលមកលោកអ្នកឧកញ៉ា ... ចៅហ្វាយស្រុក ...

(តាមរយៈលោកគ្រូមេគណខេត្ត ...[1])

សូមជ្រាប ។

សូមបញ្ជូនជាប់មកជាមួយនេះសេចក្ដីកត់ហេតុចុះថ្ងៃ ... ខែ ... ឆ្នាំ ... អំពីសាកសពភិក្ខុឈ្មោះ ... ដែលចងកសម្លាប់ខ្លួនឯង នៅទីវត្ត ... ដើម្បីសុំឲ្យចាត់គ្រូពេទ្យចេញទៅពិនិត្យប្រញាប់ ឬមានបង្គាប់យ៉ាងណាសុំឲ្យដំណឹងទៅវិញនឹងបានចាត់ការតាម ។

បានសាកសួរអង្កេតពីខ្មោចនេះដែលស្លាប់ ឃើញថាខ្មោចភិក្ខុនេះចងកដោយ[illegible]ខ្លួនឯង សូមជូនមានសេចក្ដីអង្កេតដែលជូនមកជាមួយនឹងសំណុំរឿងនេះស្រាប់ ។

www.elibraryofcambodia.org

តាម ហត្ថលេខា និងត្រា

x x x

## សេចក្ដីកត់ហេតុ [2]

ពុទ្ធសករាជពីរពាន់ប្រាំរយកៅសិប... ថ្ងៃ... ខែ.. ឆ្នាំ...

---

១ បើត្រូវការសរសេរទៅលោកចៅហ្វាយស្រុកផ្ទាល់ក៏បាន, បើត្រូវការឲ្យលោកមេគណជ្រាបផង ដីកានេះត្រូវដាក់ផ្លូវឆ្លង ។ ចំណែកខាងមេគណបើត្រូវការសរសេរចូលទៅកាន់សម្ដេចព្រះសង្ឃនាយកជាមេគណៈរបស់ខ្លួន ឬសរសេរទៅក្រសួងធម្មការ ត្រូវដាក់ ("តាមរយៈលោកចៅហ្វាយស្រុក ឬចៅហ្វាយខេត្ត") ក្នុងគម្រូខាងលើនេះ ឲ្យចំត្រង់កណ្ដាលបន្ទាត់ ។

២ កាលបើមានហេតុភេទក្នុងវត្តក្ដី ឬពិនិត្យរូបអសុភក្ដី ឬសួរយកចម្លើយក្ដី ត្រូវធ្វើសេចក្ដីកត់ហេតុតាមគម្រូនេះ ។ ឯការកត់ហេតុនីមួយ ៗ ត្រូវឲ្យមានគ្នាចំនួន ២ នាក់ឡើងទៅ ដើម្បីជាសាក្សី ។

ស័ក ត្រូវនឹងថ្ងៃទី... ខែ... ឆ្នាំមួយពាន់ប្រាំបួនរយ... ពេលម៉ោង... រសៀល(១) នៅទីវត្ត... យើងព្រះ... អនុគណស្រុក... បានរួបរួមជាមួយនឹងលោកមេឃុំ(២)... បានពិនិត្យរូបអសុកភិក្ខុឈ្មោះ(៣)... ដែលចងកសម្លាប់ខ្លួនឯងនៅទីព្រៃខាងជើងវត្ត(៤)... ឃើញរូបអសុកនេះព្យួរនៅមែកឈើ កំពស់ប្រមាណ ១ម,៧០ ពីដី មានសំពត់ស្បតចងក ។

យើងបានពិនិត្យរបួសស្នាកស្នាមនៅលើខ្លួន ពុំឃើញមានហេតុអ្វីគួរឲ្យសង្ស័យថាមានមនុស្សដទៃសម្លាប់ ហើយក្លែងយកទៅព្យួរនៅលើដើមឈើនោះទេ ។

www.elibraryofcambodia.org

បានស៊ើបអង្កេតអ្នកជិតខាងក្នុងវត្តទៅឃើញថា ខ្មោចភិក្ខុនេះចំនួន ២-៣ ថ្ងៃមុនមានមុខក្រៀមក្រំ ប្រហែលជាមានព្រួយនឹងប្រឡងធ្លាក់, ស្រាប់តែដល់មកថ្ងៃ... ពេលថ្ងៃត្រង់ចេញបាត់ពីកុដិទៅ, ថាបានលើកគ្នាដើរត្រាសរកទៅប្រទះឃើញព្យួរកស្លាប់នៅលើដើមស្ដៅខាងជើងវត្ត ។

ឯរូបអសុកនេះ បានទុកឲ្យនៅទីដដែលរង់ចាំគ្រូពេទ្យទៅពិនិត្យសម្រេចតាមការ ។

បញ្ចប់នៅពេលម៉ោងដូចខាងលើ ។

តាម ហត្ថលេខា អនុគណ　　　　តាម ហត្ថលេខា មេឃុំ

x x x

---

១ ចុះពេលវេលា ។ ២ អ្នកដែលធ្វើអត្តិពជ មួយ ។ ៣ ឈ្មោះភិក្ខុឬសាមណេរដែលស្លាប់។ ៤ ចុះទីកន្លែងដែលហេតុនោះឧប្បត្តិឡើង ។

សេចក្តីកត់ហេតុរើសរូបទៅអធិការ(១)..

លេខ...

ឆ្នាំមួយពាន់ប្រាំបួនរយ... ខែ... ថ្ងៃទី... ពេលម៉ោង...

យើង(២)... ព្រះគ្រូ ..(៣) អនុគណស្រុក... ជាអធិបតី

" ... ចៅហ្វាយស្រុក... ជាសមាជិក

" ... មេឃុំ... "

" ... អាចារ្យវត្ត... "

បានឃើញព្រះរាជក្រមលេខ ១២ ន.ស. ចុះថ្ងៃអង្គារ ៥ កើតខែមាឃ ឆ្នាំមមីចត្វាស័ក ព.ស. ២៤៨៩ ត្រូវនឹងថ្ងៃទី ៩ ខែហ្វេព្រីយេរ ១៩៤៣ ។

www.elibraryofcambodia.org

បានឃើញព្រះសង្ឃប្រកាសលេខ ៥ ចុះថ្ងៃសុក្រ ១០ កើត ខែចេត្រ ឆ្នាំជូតសំរឹទ្ធិស័ក ព.ស. ២៤៩១ ត្រូវនឹងថ្ងៃ១៨ ខែមេសា ១៩៤៩ បញ្ញត្តិពីរបៀបរើសរូបទៅអធិការ

បានឃើញសំណុំរឿងរើសរូបទៅអធិការនឹងគ្រូសូត្រឆ្វេងស្តាំវត្ត... ឃុំ... លេខ .. ចុះថ្ងៃ... ខែ... ឆ្នាំ... ដែលព្រះ... ជាអនុគណ បញ្ជូនមកដោយយល់ព្រមផង ។

បានមកជួបជុំនៅទីវត្ត... ឃុំ... នៅថ្ងៃខែឆ្នាំដូចខាងលើនេះ ។

បានឃើញកំណត់ដែលបានបិទប្រកាសផ្សាយត្រឹមត្រូវហើយ ។

បានប្រជុំភិក្ខុ–សាមណេរ ដែលគង់នៅវត្តនេះ ដូចមានពយនាមភិក្ខុ

១ សម្រាប់កុះឈ្មោះទៅអធិការឬគ្រូសូត្រដែលត្រូវរើស ។ ២ នាមកំណើត ។ ៣ ងារ ។

សាមណេរមានសិទ្ធិបោះឆ្នោតដែលបានបិទផ្សាយនៅវត្ត . . . ពីថ្ងៃ . . . ខែ . . . ឆ្នាំ . .

លុះភិក្ខុសាមណេរជួបជុំហើយទើបឲ្យចូលបោះឆ្នោតម្នាក់ម្តងជាលំ-ដាប់, ភិក្ខុសាមណេរដែលគ្មានឈ្មោះក្នុងបញ្ជីមិនមានចូលបោះឆ្នោតទេ ។ នៅពេលថ្ងៃ.. ម៉ោង. យើងបានរើសឆ្នោតចេញពីហិប, បានផ្ទៀងផ្ទាត់សន្លឹកឆ្នោតទៅឃើញថ្លើយជាក់ទាំងអស់គ្នាទៅលើភិក្ខុ(១) . . . ព្រះជន្ម . . . ឆ្នាំ វស្សាបាន . . . ចាស់ជាងគេដែលឈរឈ្មោះជាបេក្ខសមណៈ, យើងបានប្រកាសក្នុងវេលានោះភ្លាមដល់ភិក្ខុសាមណេរក្នុងវត្តទាំងអស់ថា ចៅអធិការ(២)បានទៅលើភិក្ខុនាម . . . ៈបើសមណៈអង្គណាមានការតវ៉ាទាស់ដូចម្តេច, ត្រូវតវ៉ាតាមការ ។ នៅឱកាសនោះពុំមានឈ្មោះណាតវ៉ាទេ(៣) ។

យើងបញ្ឈប់សេចក្តីកត់ហេតុនេះនៅពេលម៉ោង . . . នៃថ្ងៃខែឆ្នាំ ដូចមានខាងលើ ។

យើងសម្រេចបញ្ជូនសេចក្តីកត់ហេតុព្រមទាំងសំណុំរឿងរើសចៅអធិការនេះទៅរាជការមុខក្រសួងសុំឲ្យសម្រេចតាំងភិក្ខុ... មានសមត្ថភាពមាំមួន មានកិរិយាមារយាទត្រឹមត្រូវល្អ ជាអ្នកឈ្លាសវៃក្នុងធម៌វិន័យ មានសមត្ថភាពអាចទូន្មានខ្លួននិងអ្នកដទៃបាន ជាអ្នកបរិសុទ្ធក្នុងជំនុំសង្ឃផង ឲ្យធ្វើជាចៅអធិការគ្រប់គ្រងសង្ឃមណ្ឌលក្នុងវត្តនេះតទៅជំនួសចៅ

---

១ ចុះនាមភិក្ខុដែលរើសបាន ។ ២ បើរើសគ្រូសូត្រត្រូវថា "គ្រូសូត្រ" ។ ៣- បើមានតវ៉ាត្រូវសរសេរពីហេតុនោះឲ្យលម្អិតគ្រប់ផង ។

www.elibraryofcambodia.org

អធិការ...ដែលទទួលអនិច្ចធម្ម( ) ៗ

នាមនិង ហត្ថលេខា
ក្រុមសន្និបាត

នាមនិង ហត្ថលេខាសាមីខ្លួន
ទទួលយល់ព្រម

※ ※ ※

## គម្រូសំបុត្រសុំកសាងវត្ត(១)

វត្ត... ថ្ងៃទី . . . ខែ... ព.ស.២៤៩... / គ.ស.១៩៥...

សូមបានឈ្មោះ... ជាអ្នកតំណាងពុទ្ធបរិស័ទភូមិ... សង្កាត់.. ស្រុក... ខេត្ត. .

សូមក្រាបប្រណិប័តន៍ចូលមក

លោកអនុគណ ប្រចាំស្រុក...

សូមបានជ្រាប ៗ

ដ្បិតពុទ្ធបរិស័ទ ដូចមានរាយឈ្មោះផ្តិតមេដៃ ទាំងស្រី–ប្រុស ចំនួន២៥៨(៣)នាក់ មានទីលំនៅឆ្ងាយពីវត្តជិតខាង ចម្ងាយប្រហែល ៥ គីឡូម៉ែត្រ លំបាកនឹងបញ្ជូនកូនចៅឲ្យទៅរៀនសូត្រនឹងទៅមកធ្វើបុណ្យ បានតាមសណ្តាប់បវេណី ទើបព្រមព្រៀងគ្នាចង់កសាងវត្តមួយ ៗ

ម្យ៉ាងទៀត ភូមិនេះសម្បូរដោយទឹកដី ដែលបម្រុងកាប់គាស់ធ្វើរបរដំណាំចិញ្ចឹមជីវិតបានដោយស្រួល ជាទីប្រជុំជនមួយយ៉ាងស្តុកស្តម្ភតទៅអនាគត ៗ យើងខ្ញុំបម្រុងនឹងបង្កើតសាលារៀនជាដំបូង ដើម្បីនឹងឲ្យ

១ ដាក់តាមដំណើរបាត់បង់នៃចៅអធិការមុន ។ ២ ត្រូវយកទៅជូនមេឃុំ ។ ៣ ត្រូវដាក់តាមចំនួនមនុស្សជើងវត្តថ្មី ។

កូនចៅបានរៀនសូត្រ ។

មួយទៀតទីដែលបម្រុងកសាងវត្តថ្មីនេះ ស្ថិតនៅចំកណ្ដាលភូមិ មានផ្លូវគមនាគមន៍ទៅមកបានដោយស្រួល, ដីនេះមានទំហំទទឹងប្រមាណ ១៥០ ម៉ែត្រ បណ្ដោយ ៣០០ ម៉ែត្រ(១) ជាទីទួលប្រតិស្ឋានឆ្ងាយពីមាត់ទន្លេ មិនវិនាសដោយច្រាំងបាក់ជាដើម, ជាដីរបស់ឈ្មោះ.. និង... ដែលព្រមព្រៀងវេរ ទុកសម្រាប់កសាងវត្តថ្មីនេះ សឹងដូចមានសំបុត្រម្ចាស់ដី និងប្លង់ដីនេះ ជូនជាប់មកជាមួយនេះស្រាប់ ។

ហេតុនេះ សូមលោកអ្នកឧកញ៉ាជាចៅហ្វាយ ចេញទៅពិនិត្យដល់ទីកន្លែង ហើយប្ដឹងទៅរាជការមុខក្រសួង សុំអនុញ្ញាតកសាងវត្តថ្មីនៅទីភូមិ... នេះ ឲ្យបានតាមសុំ និងបានសង់សាលារៀន ព្រមទាំងបានធ្វើបុណ្យបានតាមបវេណីតរៀងទៅ ។

www.elibraryofcambodia.org

សេចក្ដីតំគល់សូមមេត្តាអភ័យទោស

តាមនិង ហត្ថលេខា អ្នកតំណាង

※ ※ ※

## គម្រូសំបុត្រវេរដីទុកសម្រាប់កសាងវត្ត

ថ្ងៃទី... ខែ... ព.ស. ២៤៩... / គ.ស. ១៩៥...

សូមបានឈ្មោះ... ជាតិជាខ្មែរ អាយុ... ឆ្នាំ ប្រពន្ធឈ្មោះ... ទីលំនៅ ។ ភូមិ... សង្កាត់... ស្រុក .. ខេត្ត...

---

១- ត្រូវគូរផែនទីវត្តចុះព្រំប្រទល់ឲ្យច្បាស់លាស់ជូនទៅភ្ជាប់ជាមួយនឹងពាក្យសុំផង ។

ខ្ញុំបាទទាំងពីរនាក់ប្ដីប្រពន្ធ បានស្ម័គ្រចិត្តវេរដីមួយកន្លែង(១) ទទឹង... ម៉ែត្រ បណ្ដោយ... ម៉ែត្រ ជាដីចំការនៅក្នុងភូមិ... សង្កាត់... ស្រុក... ដូចមានប្លង់ផែនទីជូនជាប់មកនៅនេះស្រាប់ សម្រាប់កសាងវត្តថ្មី ដែលមានឈ្មោះ... ជាតំណាងពុទ្ធបរិស័ទសុំកសាង ។

បើមានឈ្មោះណាមកទាមទារតវ៉ាដោយប្រការដូចម្ដេច មានរូបខ្ញុំបាទទាំងពីរនេះទទួលខុសត្រូវស្រាប់ ។

ក្រែងពុំប្រាកដ ខ្ញុំបាទទាំងប្ដី–ប្រពន្ធសូមផ្ដិតមេដៃ ទុកជាសម្គាល់តទៅ ។

ស្នាមមេដៃប្ដី –ប្រពន្ធ –កូន(២)

www.elibraryofcambodia.org

x x x

គម្រូសំបុត្រអាចារ្យវត្តសរសេរទៅរាជការ
តឿនច្បាប់កសាងវត្ត ដែលសុំយូរឆ្នាំហើយ
ឲ្យបានច្បាប់ពេញទីឡើង(៣)

ថ្ងៃទី... ខែ... ព.ស. ២៤៩៦
គ.ស. ១៩៥៣

សូមបានឈ្មោះ... អាយុ... ឆ្នាំ នៅភូមិ...
និងឈ្មោះ .. អាយុ... ឆ្នាំ នៅភូមិ សង្កាត់...
ស្រុក .. ខេត្ត... ជាតំណាងពុទ្ធបរិស័ទជើងវត្ត ..

---

១. បើដីច្រើនកន្លែងចុះតាមចំនួនដីនោះ, មួយទៀតឲ្យមេឃុំបញ្ជាក់សំបុត្រវេរដីនេះជាដាច់ខាត ។ ២ បើមានកូនពេញការត្រូវចុះឈ្មោះកូនទាំងអស់នោះផង ។ ៣ សំបុត្រនេះត្រូវជូនទៅមេឃុំបញ្ជាក់ជាដរាប

សាធារណរដ្ឋប្រជាមានិតកម្ពុជា
បណ្ណាល័យជាតិ
លេខកូដ : ..........................
ថ្ងៃខែឆ្នាំ : ..........................

សូមក្រាបប្រណិប័តន៍ចូលមក

លោកឧកញ៉ា... ចៅហ្វាយស្រុក...

សូមបានជ្រាប ។

ដ្បិតវត្ត ..នេះ បានកសាងចំនួន ២០ ឆ្នាំមកហើយ ឋិតនៅលើដីដែលជាប្រពៃណីសម្រាប់វត្តនេះជាយូរអង្វែងឆ្នាំហើយ ។ ដីវត្តនេះទទឹង...ម៉ែត្រ បណ្ដោយ...ម៉ែត្រ មានសួនច្បារដំណាំជាទីមនោរម្យផង ។ ចំនួនជាង ៥ ឆ្នាំហើយ រាជការក្រសួងសុរិយោដីខេត្ត... បានចាត់ចែនទីឲ្យមកវាស់ចុះក្នុងបញ្ជីដីសម្រាប់វត្ត... នេះ ដូចមានក្នុងបញ្ជីរាជការស្រាប់ ។ សព្វថ្ងៃមានអ្នកស្រុកពីរភូមិគឺ ភូមិ... ១ ភូមិ... ១ ដែលមានឧបាសក—ឧបាសិកាចំនួន... នាក់ មកធ្វើបុណ្យទានក្នុងវត្តនេះ ។ មានផ្ទះអ្នកស្រុក ចំនួន... ខ្នង ។ ស្រុកនេះសម្បូរដោយទឹកដី សម្រាប់អ្នកស្រុកជើងវត្តធ្វើរបរដំណាំផ្សេងៗ មានចំការស្រែជាដើម, មានបឹងនិងព្រែកខ្វាត់ខ្វែងសម្រាប់អ្នកស្រុកអាស្រ័យប្រើប្រាស់, ព្រមទាំងប្រកបដោយផ្លូវគមនាគមន៍ចេញចូលទាំងប្រាំងទាំងវស្សា បានដោយស្រួល ។ វត្ត... នេះ ឋិតនៅចំនួន ៤ គីឡូម៉ែត្រពីវត្តជិតខាង, អ្នកស្រុកមានសេចក្ដីលំបាកនឹងទៅធ្វើបុណ្យទានឯវត្តជិតខាងដែលឃ្លាតឆ្ងាយពីគ្នាពេក ហើយមានអូរព្រែកឃាំងច្រើនផង ។ ម្យ៉ាងទៀតភូមិទាំងពីរនេះក៏កាន់តែរីកធំឡើងៗ តែរៀងរាល់ឆ្នាំ ។

សព្វថ្ងៃនេះពុទ្ធបរិស័ទជើងវត្ត...នេះបាននាំគ្នាកសាងព្រះវិហារមួយ

www.elibraryofcambodia.org

ដោយគ្រឿងឈើប្រក់ក្បឿង បណ្ដោយ... ម៉ែត្រ ទទឹង... ម៉ែត្រ (ដែលបម្រុងនឹងរាតរង់តទៅទៀត) សម្រាប់សង្ឃធ្វើសង្ឃកម្ម ព្រមទាំងបានកសាងសេនាសនៈផ្សេងៗ មានកុដិសាលាគ្រឿងឈើប្រក់ក្បឿងចំនួន... ខ្នងស្រេចហើយផង គឺសាលាបឋមសិក្សាសម្រាប់កុមារា-កុមារីមួយខ្នង ដែលមានទទឹង... ម៉ែត្រ បណ្ដោយ... ម៉ែត្រ មានតុសម្រាប់រៀនសូត្រសព្វថ្ងៃ; បានយកកុដិ ១ ខ្នង ប្រក់ក្បឿងគ្រឿងឈើធ្វើជាសាលាបឋមវិជ្ជាបណ្ដោះអាសន្ន មានកុដិធំមួយ គ្រឿងឈើប្រក់ក្បឿង សម្រាប់ភិក្ខុសាមណេរនៅអាស្រ័យ, ឯសេនាសនៈផ្សេងៗទៀតបេះតែធ្វើបន្តទៅទៀតសព្វថ្ងៃ, មានឡដុតក្បឿង-ឥដ្ឋមួយ ឋិតនៅក្បែរវត្ត ដែលជារបស់វត្តសម្រាប់ដុតក្បឿង-ឥដ្ឋយកមកសាងវត្តនេះផង ដូចមានផែនទីបរិវេណវត្តនិងសេនាសនៈ ដែលមានក្នុងវត្តសព្វថ្ងៃ បង្អុលឲ្យឃើញថាទីទឹកដីវត្តថ្មីនេះ ពុទ្ធបរិស័ទបានខំប្រឹងប្រែងកសាងយ៉ាងម៉ឺងម៉ាត់ ។

វត្ត... នេះ សព្វថ្ងៃមានភិក្ខុសាមណេរចំនួន... រូប គង់ចាំវស្សាព្រមទាំងខំប្រឹងប្រែងរៀនសូត្រតាមពុទ្ធប្បញ្ញត្តិផង ។

វត្តនេះបានសុំច្បាប់តាមផ្លូវរាជការជាហូរហែមកយូរឆ្នាំហើយ, តែពុំទាន់ឃើញរាជការសម្រេចយ៉ាងណា, ទើបតែចំនួនជាង... ឆ្នាំហើយឃើញសាលាស្រុក... ចាត់បម្រើឲ្យទៅអង្កេតដល់កន្លែង ព្រមទាំងក្រសួងសង្ឃ (អនុគណ) ក៏បានទៅអង្កេតហូរហែមកដែរ តែនៅពុំទាន់ឃើញសម្រេចដូចម្ដេច រហូតមកដល់សព្វថ្ងៃនេះ ។

www.elibraryofcambodia.org

ឥឡូវមានសារាចរ ពីក្រសួងធម្មការលេខ ៦ ចុះថ្ងៃ ២៨ ឧសភា ឆ្នាំ ១៩៥២ និងបុគហ្វាយក្រសួងធម្មការលេខ ១.១១៣ ចុះថ្ងៃទី ២៥ វិច្ឆិកា ឆ្នាំ ១៩៥២ អនុញ្ញាតឲ្យប្តឹងសុំជាវត្តពេញទី អស់ទាំងវត្តណា ដែលមិនទាន់បានច្បាប់ពេញទី ។

ហេតុនេះ សូមលោកឧកញ៉ា អើរកសំណុំរឿងចាស់ដែលបានអង្កេតហួរហែពីដើមមកពិនិត្យប្តឹងបញ្ជូនទៅរាជការមុខក្រសួងសម្រេច ឲ្យបានវត្ត...នេះស្ថិតស៊ប់សួនជាស្ថាពរដូចវត្តទាំងពួងក្នុងព្រះរាជអាណាចក្រ តទៅតាមបញ្ញត្តិបុគហ្វាយលេខ ១.១១៣ ចុះថ្ងៃទី ២៥ វិច្ឆិកា ឆ្នាំ ១៩៥២ ពីក្រសួងធម្មការឲ្យទាន ព្រោះវត្ត[illegible]ទាន់ បាន សង់សាលាកុមារដ្ឋានមាំមួន មានទាំងគ្រូសម្រាប់រៀនសព្វគ្រប់ ។

សូមជូនមកជាប់នៅនេះបញ្ជីផ្តិតម្រាមដៃអ្នកស្រុកមួយច្បាប់ បញ្ជីគរុកណ្ឌវត្តមួយច្បាប់, បញ្ជីភិក្ខុសាមណេរមួយច្បាប់ រូបថតវត្ត...សន្ទឹកៗ

តាម ហត្ថលេខា

x x x x

គម្រូសំបុត្រអាចារ្យវត្តសរសេរទៅលោកចៅហ្វាយស្រុកសុំច្បាប់កាប់ឈើរួចពន្ធយកមកកសាង

សេនាសនៈមានវិហារជាដើម ។

លេខ(១)... វត្ត... នៅថ្ងៃទី... ខែ... ព.ស. ២៤...
គ.ស ១៩...

១- លេខសំបុត្រអាចារ្យវត្ត ដើររៀងជាមួយនឹងលេខសំបុត្របោរាណធិការ ។ សំណៅនៅលើដៃបោរាណធិការឬគ្រូសូត្រស្តាំ ។

www.elibraryofcambodia.org

សូមទានឈ្មោះ... លេខកាត្រ... ជាតិជាខ្មែរ...

ទីលំនៅៗភូមិ... ជាអាចារ្យវត្ត... សង្កាត់ .. ស្រុក. . ខេត្ត...

សូមក្រាបប្រណិប័តន៍ចូលមក

លោកអ្នកឧកញ៉ា... ចៅហ្វាយស្រុក...

សូមទានជ្រាប ៗ

ដ្បិតព្រះវិហារ(១)វត្ត... ដែលពុទ្ធបរិស័ទកសាងមកយូរឆ្នាំហើយ
ឥឡូវទ្រុឌទ្រោមគ្រាំគ្រាទីងទុកតទៅទៀតក្រែងប៉ោះការ ៗ ក្រុមពុទ្ធបរិស័
ដើងវត្តព្រមព្រៀងគ្នាបរិច្ចាគទ្រព្យដើម្បីរុះរើធ្វើជាថ្មី ៗ ត្រូវការសុំច្បា
កាប់ឈើរបពន្ធបន្ទួបមានខាងក្រោមនេះ នៅទីព្រៃ(២)... សង្កាត់.
ស្រុក... ខេត្ត... ៗ ឈើទាំងនេះនឹងប្រជុំនៅទី... ដើម្បីវាយត្រា
សូមមេត្តាចាត់ការបញ្ជូនតាមមុខក្រសួងឲ្យបានអនុញ្ញាតច្បាប់នេះឲ្យទាន

| ចំនួនឈើ | ភេទមុខឈើ | ទំហំ | | សេចក្ដីផ្សេងៗ |
|---|---|---|---|---|
| | ស្រឡៅ (ហុប) | បណ្ដោយ ១០ម. | មុខ៤តឹក | |
| | សរសរសុក្រម | បណ្ដោយ ៣ម. | មុខ៣តឹក | |
| | ឈើទាល (ដើម) | បណ្ដោយ ១០ម. | មុខ៦តឹក | |
| | ឫស្សី (ដើម) | | | |

តាម ហត្ថលេខា អាចារ្យវត្ត (៣)

១ បើសាងវិហារឬសាលាបាលីក្ដី ឲ្យចុះតាមឈ្មោះសេនាសនៈនោះ ។ ២ ប្រាប់ទីកន្លែ
កាប់ឈើ និងទីប្រជុំឈើភាបត្រា ផង ។ ៣ អាចារ្យវត្តត្រូវយកសំបុត្រនេះទៅឲ្យមេឃុំបញ្ជ
យល់ព្រមជាមុនផង ។

# គម្រូសំបុត្រសុំច្បាប់បញ្ចុះសីមា

លេខ...

វត្ត... នៅថ្ងៃទី... ខែ... គ.ស.២៥... / ព.ស.១៩៥...

សូមជានឈ្មោះ... ជាតិខ្មែរ អាយុ... ឆ្នាំ ទីលំនៅ ៗ ភូមិ... ជាអាចារ្យវត្ត.. សង្កាត់... ស្រុក... ខេត្ត...

សូមក្រាបប្រណិប័តន៍ចូលមក

លោកអ្នកឧកញ៉ា... ចៅហ្វាយស្រុក...

សូមជានជ្រាប ។

ដ្បិតវត្ត... នៅសង្កាត់... ស្រុក... ខេត្ត... ដែលមានព្រះរាជក្រឹត្យលេខ... ចុះថ្ងៃ... ខែ... ឆ្នាំ... អនុញ្ញាតឲ្យកសាងនោះ ឥឡូវបានកសាងព្រះវិហាររួចហើយ ព្រមទាំងសេ-នាសនៈឯទៀតខ្លះផង ។

www.elibraryofcambodia.org

ដូច្នេះសូមព្រះតេជព្រះគុណមេត្តាចាត់ការបញ្ជូនពាក្យនេះទៅរាជការធំ សូមអនុញ្ញាតច្បាប់បញ្ចុះសីមានៅទីវត្តថ្មីនេះ ឲ្យបានសម្រេចឲ្យមាន ដើម្បីនឹងបានភិក្ខុសង្ឃធ្វើសង្ឃកម្មផ្សេងៗតទៅ ។

សូមជូនមកជាប់នៅនេះប្រាក់ចំនួន.... រៀល ជាតម្លៃប្រថាប់ព្រះលញ្ឆករ ។

ហត្ថលេខា និងនាម

x x x

## គម្រូសំបុត្រសុំច្បាប់រួចពន្ធដីប្រពៃណីវត្ត

លេខ...

វត្ត .. នៅថ្ងៃទី... ខែ... ព.ស. ២៤... / គ.ស. ១៩...

សូមមានឈ្មោះ... ជាតិជាខ្មែរ លេខកាត្រ...

ទីលំនៅភូមិ... ជាអាចារ្យវត្ត... សង្កាត់... ស្រុក... ខេត្ត...

សូមជំរាបមកលោកចៅពញារក្សាគិបាលចៅសង្កាត់..

សូមជ្រាប

ដ្បិតឧបាសកឈ្មោះ .. ប្រពន្ធឈ្មោះនាង...

ទីលំនៅភូមិ... សង្កាត់... ស្រុក... ខេត្ត... បានស

www.elibraryofcambodia.org

ចិត្តទាំងប្ដីទាំងប្រពន្ធ វេរដី[១]... សម្រាប់ជាប្រពៃណីវត្ត... សីង

មានសំបុត្រអំណោយ[២] ចុះថ្ងៃទី... ខែ... ឆ្នាំ...

ផែនទីដីលេខ... ចំនួន... ហិតា ជូនមកជាប់ជាមួយនេះស្រាប់

សុំលោកចៅសង្កាត់ចាំងជូនលិខិតនេះ ទៅពជការមុខក្រសួងសុំ

ឈ្មោះម្ចាស់ដីនេះ បញ្ចូលទៅជាដីប្រពៃណីសម្រាប់វត្តឲ្យមាន ហើយ

ឲ្យរួចប្រាក់ពន្ធតាមបញ្ញត្តិច្បាប់ឲ្យមានតាមសុំ ។

គួរពុំគួរសូមអភ័យទោស ។

ហត្ថលេខា និងនាម អាចារ្យវត្ត

x x x

---

១ បេញឈ្មោះដីចំការឬស្រែ ។ ២. សំបុត្រអំណោយនេះត្រូវឲ្យប្ដីប្រពន្ធព្រមទាំង

ទៅចុះហត្ថលេខាយល់ព្រមផង ទើបទុកជាបានការ ។

www.elibraryofcambodia.org




www.elibraryofcambodia.org

២៥០

១ស



www.elibraryofcambodia.org

www.elibraryofcambodia.org

## គម្រូសំបុត្រអាចារ្យវត្តប្តឹងទៅហ្វាយស្រុក សុំច្បាប់តម្កល់សពលោកគ្រូចៅអធិការវត្ត

លេខ...

វត្ត... នៅថ្ងៃទី... ខែ... គ.ស. ២៤.... / ព.ស. ១៩...

សូមបាទឈ្មោះ... ជាតិជាខ្មែរ ទីលំនៅ ១ ភូមិ...

ជាអាចារ្យវត្ត... សង្កាត់... ស្រុក... ខេត្ត...

សូមក្រាបប្រណិប័តន៍ចូលមក

លោកអ្នកឧកញ៉ា... ចៅហ្វាយស្រុក...

សូមបានជ្រាប ។

www.elibraryofcambodia.org

ដ្បិតលោកគ្រូចៅអធិការ(១) វត្ត... ទទួលអនិច្ចធម្មនៅថ្ងៃ... ខែ... ឆ្នាំនេះ ដោយរោគ(២) ក្នុងជន្មាយុ... ឆ្នាំ ។

ពុទ្ធបរិស័ទបានចាត់ចែងធ្វើឡតដោយដែកស័ង្កសីផ្សារយ៉ាងជិតតម្កល់ក្នុងក្តារមឈូសឈើ មានដាក់វត្ថុផ្សេង ៗ សម្រាប់ម្លាប់រោគតាមក្បួនពេទ្យ ។ សុំច្បាប់តម្កល់សពនេះទុកធ្វើបុណ្យដល់ទៅខែ.... ឆ្នាំ.... ចំនួន...ខែ ទើបពួកសិស្សានុសិស្សនឹងនាំគ្នាធ្វើបុណ្យរំលាយសព តាមប្រពៃណី ។

ហេតុនេះសូមលោកអ្នកឧកញ៉ាអនុញ្ញាតច្បាប់តម្កល់សពនេះ តាម

---

១- បើសរមេគណត្រូវដាក់តាមនោះ ។ ២- ប្រាប់ឈ្មោះរោគ, តាមបញ្ញត្តិពេទ្យបើជំងឺអាសន្នរោគ, ហាមមិនឲ្យតម្កល់ទេ ។

សុំឲ្យបាន ៗ

គួរពុំគួរសូមអភ័យទោស

ហត្ថលេខា និងនាម អាចារ្យវត្ត

x x x

## គម្រូសំបុត្រអាចារ្យវត្ត សុំធ្វើបុណ្យរំលាយសព

## លោកគ្រូចៅអធិការវត្ត

លេខ...

វត្ត... នៅថ្ងៃទី... ខែ... គ.ស.២៥... / ព.ស.១៩...

សូមបានឈ្មោះ... ជាតិជាខ្មែរទីលំនៅ ។ ភូមិ...

ជាកម្មការវត្ត... សង្កាត់... ស្រុក... ខេត្ត...

www.elibraryofcambodia.org

សូមក្រាបប្រណិប័តន៍ចូលមក

លោកអ្នកឧកញ៉ា... ចៅហ្វាយស្រុក...

តាមរយៈលោកចៅសង្កាត់...

សូមបានជ្រាប

ដ្បិតព្រះសពនាម... ជាចៅអធិការវត្ត(១)... ដែលទទួលអនិ

ធម្មតាំងពីកន្លងខែ... ឆ្នាំ... ឥឡូវពួកសិស្សានុសិស្សបានសម្រេ

ចាត់ធ្វើបុណ្យរំលាយសពនេះនៅថ្ងៃ... ខែ... ឆ្នាំនេះ ។ បុណ្យ

កំណត់ ៣ ថ្ងៃ ចាប់ពីថ្ងៃ... ខែ... ដល់ថ្ងៃ... ខែដដែលជាថ្ងៃបូ

រំលាយសព ដូចមានកម្មវិធីជូនជាប់មកជាមួយនេះស្រាប់ ។

១ បើលោកនោះទីចៅអធិការក្តី មេគណក្តី ។ល។ ឲ្យប្តូរតាមឋានន្តរនោះ ៗ

សូមលោកអ្នកឧកញ៉ាអនុញ្ញាតច្បាប់ឲ្យបាន ទាំងសូមអញ្ជើញអស់លោកមន្ត្រីសាលាស្រុកទាំងអស់ ទៅជាអធិបតីក្នុងទានសប្បុណ្យនេះផង ដើម្បីបានអនុមោទនាមគ្គផលតាមសទ្ធា ។

សេចក្តីគួរពុំគួរសូមទានអភ័យទោស

ហត្ថលេខា និងនាម អាចារ្យវត្ត

x x x

គម្រូសំបុត្រអាចារ្យវត្តសុំរាជការរើសរូបចៅអធិការថ្មី ជំនួសចៅអធិការចាស់ ដែលទទួលអនិច្ចធម្ម(១)

លេខ...

វត្ត... នៅថ្ងៃទី... ខែ... ព.ស. ២៥... / គ.ស. ១៩...

www.elibraryofcambodia.org

សូមទានឈ្មោះ... ជាតិជាខ្មែរ ទីលំនៅភូមិ... ជាអាចារ្យវត្ត... សង្កាត់... ស្រុក... ខេត្ត... ជាអ្នកតំណាងពុទ្ធបរិស័ទ

សូមក្រាបប្រណិប័តន៍ ចូលមក

លោកអ្នកឧកញ៉ា... ចៅហ្វាយស្រុក...

សូមទានជ្រាប ។

ដ្បិតវត្ត... ដែលឥតពីព្រះសពនាម... ទទួលអនិច្ចធម្មទៅចំនួន(២)...ឆ្នាំហើយ ពុំទាន់បានរូបចៅអធិការនៅឡើយ ។ ដើម្បីចៀសវាងកុំឲ្យមានកើតហេតុទៅមុខបាន សូមលោក

---

១ បើលោកលាចាកសិក្ខាបទត្រូវប្តូរតាមនោះ ។ ២ ចំនួនពេលវេលាដែលទទួលអនិច្ចធម្មឬសឹកចេញ ។

មេត្តាចាត់ការឲ្យរើសរូបថតអធិការថ្មីយ៉ាងឆាប់ឲ្យបាន និងបានគ្រប់

សង្ឃមណ្ឌលក្នុងវត្តនេះតទៅ ។

សូមជូនមកជាប់នៅនេះ បញ្ជីកិក្ខុ-សាមណេរ ២ ច្បាប់ជូ

ដែលមានអំណាចបោះឆ្នោតរើសរូបថតអធិការថ្មីនេះ ដើម្បីបិទឲ្យដំណ

តាមបញ្ញត្តិច្បាប់ និងបញ្ជីតរុក័ណ្ឌ ២ ច្បាប់ ។

គួរពុំគួរសូមទានអភ័យទោស

ហត្ថលេខា និងនាម អាចារ្យវត្ត

x x x

គម្រូសំបុត្រអាចារ្យវត្តសរសេរនៅចៅហ្វាយស្រុក

សុំគ្រូពេទ្យមកគាបណ្ដាះអុតឬចាក់ថ្នាំផ្សេង ៗ

www.elibraryofcambodia.org

លេខ...

វត្ត... នៅថ្ងៃទី... ខែ... ព.ស. ២៥... / គ.ស. ១៩...

សូមទានឈ្មោះ... ជាតិជាខ្មែរ ទីលំនៅភូមិ .. ជាអាចារ្យវត្ត

សង្កាត់... ស្រុក... ខេត្ត...

សូមក្រាបប្រណិប័តន៍ ចូលមក

លោកអ្នកឧកញ៉ា... ចៅហ្វាយស្រុក[1] ..

សូមទានជ្រាប

ដ្បិតនៅទីវត្ត .. សព្វថ្ងៃមានកើតជម្ងឺអុត[2] និងជម្ងឺគ្រុនចាញ់

សូមលោកអ្នកឧកញ៉ាចាត់ចែងទៅរាជការពេទ្យ សុំឲ្យទៅចាក់ថ្នាំការ

---

១ សំបុត្រនេះឲ្យហៅសក្តិបញ្ជាក់ជាមុន ។ ២ បើកើតជម្ងឺអ្វីឲ្យដាក់ឈ្មោះជម្ងឺនោ

ពេលនេះឲ្យបាន ព្រមទាំងសុំឲ្យយកថ្នាំគ្រុន ថ្នាំគមរមាស់ទៅចែកឲ្យភិក្ខុ សាមណេរនិងក្មេងវត្តឲ្យបានផង ។

ហត្ថលេខា និងនាម អាចារ្យវត្ត

x x x

គម្រូសំបុត្រអាចារ្យវត្តសរសេរទៅមេឃុំសុំច្បាប់ហែផ្កា

វត្ត... នៅថ្ងៃទី... ខែ... ព.ស. ២៥... / គ.ស. ១៩...

ខ្ញុំបាទឈ្មោះ(១)... (ជាអាចារ្យវត្ត...) ទីលំនៅភូមិ ...

សូមជំរាបចូលមក(២) អ្នកចៅពញារក្សាតិបាលចៅសង្កាត់...

សូមជ្រាប ។

ដ្បិតពពួកពុទ្ធបរិស័ទជើងវត្ត... មានសទ្ធានាំគ្នាធ្វើបុណ្យផ្កា ដង្ហែទៅវេរចំពោះសង្ឃគង់ឯវត្ត... (ដើម្បីជួយបង្ហើយកិច្ចកសាងសេនាសនៈ) ក្នុងសង្កាត់... ស្រុក... ខេត្ត... នៅថ្ងៃ... ខែ... ឆ្នាំ... កំណត់ចូលបុណ្យនៅថ្ងៃ... ខែ... ឆ្នាំ... ពុទ្ធបរិស័ទនិមន្តព្រះសង្ឃចម្រើនព្រះបរិត្តនៅក្នុងវត្ត... លុះព្រឹកឡើងនឹងដង្ហែឆ្ពោះទៅកាន់វត្ត... មានភ្លេងតូរ្យតន្ត្រីហែកំដរបុណ្យនេះផង ។

សូមមេត្តាប្តឹងទៅរាជការធំ សូមអនុញ្ញាតច្បាប់ឲ្យបានតាមសុំ(៣) ។

ហត្ថលេខា និងនាម អាចារ្យវត្ត

---

១ សម្រាប់ចុះឈ្មោះអាចារ្យឬនរណាដែលផ្តើមបុណ្យ ។ ២ សូមក្រាបប្រណិប័តន៍ចូរមក កំពូរ ។ ៣ កាលបើត្រូវការសុំច្បាប់ហែផ្កាក្តី កឋិនក្តី ទៅកាន់ខេត្តក្រៅ តោងសុំច្បាប់ប្តឹងទៅរាជការជាមុនជាដរាប ដើម្បីរាជការស្រុកនោះ ឲ្យដំណឹងទៅមន្ត្រីស្រុកក្រៅ ខេត្តក្រៅ ដែលហែផ្កាឬកឋិនចូលទៅ ព្រមទាំងប្រាប់ថ្ងៃខែឲ្យជាក់លាក់ផង ។

## គម្រូសំបុត្រអាចារ្យវត្តសរសេរទៅចៅហ្វាយស្រុក ឬចៅហ្វាយខេត្ត(១) សុំច្បាប់ហែកឋិនចេញទៅខេត្តក្រៅលំនៅ

លេខ...

វត្ត... នៅថ្ងៃទី ខែ... ព.ស. ២៥.... / គ.ស. ១៩..

សូមទានឈ្មោះ.. (២)អាចារ្យវត្ត... សង្កាត់.. ស្រុក...ខេត្ត...

សូមក្រាបប្រណិប័តន៍ ចូលមក

លោកអ្នកឧកញ៉ា... ចៅហ្វាយស្រុក...

សូមទានជ្រាប ។

www.elibraryofcambodia.org

ដ្បិតពុទ្ធបរិស័ទជើងវត្ត... មានសទ្ធាព្រមព្រៀងគ្នាបរិច្ចាគទ្រព្យ ធ្វើអង្គព្រះកឋិនទាន ដើម្បីដង្ហែទៅវេរចំពោះសង្ឃគង់ចាំវស្សាក្នុងពុទ្ធសីមាវត្ត .. ។

ពិធីបុណ្យនេះពុទ្ធបរិស័ទប្រជុំគ្នានិមន្តព្រះសង្ឃចម្រើនព្រះបរិត្តអង្គាសចតុប្បច្ច័យនៅនាទីវត្ត... នៅថ្ងៃ ... ខែ... ឆ្នាំ... លុះព្រឹកឡើង

---

១ បើសរសេរទៅចៅហ្វាយខេត្តមានស័ក្តិធំជាព្រះរាជប្រតិភូ ត្រូវសរសេរថា: ឯកឧត្តម ជំនួសពាក្យថា: លោក ។ ២ បើអ្នកម្ចាស់កឋិននោះ ធ្វើចេញឈ្មោះតែម្នាក់ឯង ត្រូវសាមីខ្លួនធ្វើសំបុត្រចេញឈ្មោះខ្លួនឯងសុំក៏បាន, បើជើងវត្តចូលគ្នាធ្វើ គោងតែចេញឈ្មោះអាចារ្យវត្តជាអ្នកសុំច្បាប់តំណាងពុទ្ធបរិស័ទជើងវត្ត ។ ត្រង់ស៊ីញេសំបុត្រ បើអាចារ្យធំមានធុរៈឬចាស់ជរា ត្រូវអាចារ្យរងស៊ីញេឈ្មោះជំនួសឥតទាស់ ។ មុននឹងកាន់សំបុត្រនេះទៅជូនលោកចៅហ្វាយស្រុក ត្រូវយកទៅឱ្យចៅសង្កាត់បញ្ជាក់សិន ។

ថ្ងៃ... ខែ... ឆ្នាំ... ទីដែលផ្ញើអង្គកឋិនទាននេះឆ្ពោះទៅកាន់

វត្ត.. សង្កាត់.. ស្រុក... ខេត្ត... ។

សូមមេត្តាអនុញ្ញាតច្បាប់ព្រមទាំងជូនដំណឹងនេះទៅអស់លោកមន្ត្រី ស្រុក–ខេត្ត ដែលខ្ញុំបាទនាំហែកឋិនទាននេះចូលទៅនោះ ជាដំណឹងតាមផ្លូវការឲ្យបាន ។ ឯបុណ្យនេះមានភ្លេងតូរ្យតន្ត្រី ព្រមទាំងទូកងប្រណាំងហែអមទៅផង ។

នាម និងហត្ថលេខា

x x x x

គម្រូសំបុត្រអាចារ្យវត្តសរសេរទៅចៅហ្វាយស្រុក
សុំគ្រូបង្រៀន

www.elibraryofcambodia.org

លេខ . . .

វត្ត ... នៅថ្ងៃទី ... ព.ស. ២៥... / គ.ស. ១៩...

សូមបានឈ្មោះ... ជាតិជាខ្មែរ ទីលំនៅភូមិ...

ជាអាចារ្យវត្ត... សង្កាត់ ... ស្រុក... ខែត្រ...

សូមក្រាបប្រណិប័តន៍ចូលមក

លោកអ្នកឧកញ៉ា... ចៅហ្វាយស្រុក(១)...

សូមបានជ្រាប ។

ដ្បិតវត្ត... មានសាលាបឋមសិក្សាមួយខ្នង ធ្វើដោយឈើប្រក់ក្បឿង

១ សំបុត្រនេះត្រូវយកទៅជូនចៅសង្កាត់នាទីនោះបញ្ជាក់មុនជាដំបូង ។

ទទឹង... ម៉ែត្រ បណ្ដោយ .. ម៉ែត្រ ចែកចេញជាពីរថ្នាក់ ។

សាលានេះកសាងឡើងដោយសទ្ធាជ្រះថ្លានៃពួកពុទ្ធបរិស័ទជើងវត្តនេះ ដោយបំណងចង់ឲ្យកូនចៅរៀនសូត្រ ។ សព្វថ្ងៃមានកូនសិស្សស្រី-ប្រុសចំនួន ៧០ ពាយនាក់ ដែលត្រូវការទឹងរៀនសូត្រ តែខ្វះគ្រូទាំងពីរថ្នាក់ ពុំទាន់មានគ្រូបង្ហាត់បង្រៀននៅឡើយ ។

សេចក្ដីនេះសូមលោកមេត្តាប្ដឹងទៅរាជការក្រសួងសិក្សាធិការ សូមឲ្យបាត់គ្រូរាជការ ២ នាក់ ដើម្បីទឹងបានចាប់បង្រៀនតាំងពីឥឡូវនេះទៅ ឲ្យបានតាមសុំ ។

នាមហត្ថលេខានិងត្រាចៅអធិការ x x x នាម និងហត្ថលេខា អាចារ្យវត្ត

www.elibraryofcambodia.org

គម្រូសំបុត្រអាចារ្យវត្ត[1]សរសេរទៅចៅហ្វាយស្រុកសុំ
ឲ្យចាត់អ្នករាជការទៅចុះឈ្មោះក្មេងសិស្សទាំងឡាយ
ដែលធ្វេសប្រហែសពុំបានចុះអេតាស៊ីវិលកំណើត
ដល់ធានីសាលាសង្កាត់

វត្ត... នៅថ្ងៃទី... ខែ... ពស២៥... / គស១៩...

សូមទានឈ្មោះ... អាចារ្យវត្ត... សង្កាត់... ស្រុក... ខេត្ត...

សូមក្រាបប្រណិប័តន៍ ចូលមក

លោកអ្នកព្រះ[2]... ចៅហ្វាយស្រុក...

សូមទានជ្រាប ។

---

១ សំបុត្រនេះត្រូវផ្ញើនៈទៅចៅសង្កាត់បញ្ជាក់មុនជាគិរាប ។ ២ ចៅហ្វាយស្រុកខ្លះស័ក្តិតូច ហានៈត្រឹមព្រះកម្មាន ។

ដ្បិតកូនសិស្សប្រុស-ស្រីសាលាបឋមសិក្សានៅនាវត្ត...
មានច្រើនឈ្មោះ ដែលមាតាបិតាធ្វេសប្រហែសពុំបានប្ដឹងចៅសង្កាត់ ឲ្យចុះកំណើតកូន ដោយសេចក្ដីល្ងង់ខ្លៅ ។

សូមលោកអ្នកព្រះមេត្តាចាត់បម្រើទៅស្រង់ឈ្មោះកុមារ-កុមារីទាំងនោះ បញ្ជូនទៅសាលាលហុចុះសំបុត្រកំណើតឲ្យបាន ឬមួយសូមអនុញ្ញាតឲ្យចៅសង្កាត់នាទីនោះចាត់ចែងឲ្យបានក៏បាន ដើម្បីចៀសវាងកុំឲ្យមានខាតបង់ប្រាក់កាស ព្រោះគ្នាច្រើនធ្វើដំណើរឆ្ងាយទៅសាលាដំបូង ។

សេចក្ដីគួរពុំគួរសូមទានអភ័យទោស

តាម និងហត្ថលេខា

www.elibraryofcambodia.org

x x x

គម្រូសំបុត្រអាចារ្យវត្តប្ដឹងទៅចៅសង្កាត់ពីមនុស្ស
ដែលមានលំនៅលើដីវត្តយូរឆ្នាំ មិនព្រមដើរចេញ

:ល ខ...

វត្ត... នៅថ្ងៃទី... ខែ... ពស២៥... / គស១៩...

ខ្ញុំបាទឈ្មោះ... ជាអាចារ្យវត្ត... សង្កាត់... ស្រុក... ខេត្ត...
សូមជំរាបមកអ្នកចៅពញារក្សាភិបាលចៅសង្កាត់...

សូមជ្រាប ។

ដ្បិតឈ្មោះ... ១ ឈ្មោះ... ១ ។ល។ ជាតិជាខ្មែរ ទីលំនៅ ភូមិ...
ង៍សង្កាត់នេះ កាលព្រះសពនាម... គង់ព្រះជន្មនៅឡើយ គឺក្នុងកាល

ឆ្នាំ... ចំនួន ១០ ឆ្នាំហើយ បានមកសុំលោកថា សុំសង់ផ្ទះស្នាក់[១] នៅបណ្ដោះអាសន្នទំរាំខ្លួនពល់គ្នារកដីបាន មានប្រាក់កាសនឹងរើលំនៅពីទីនេះទៅនៅតាមនាទីរៀងខ្លួន ៗ ឥឡូវខ្ញុំបាទនឹងចាស់ស្រុកជើងវត្តហៅមកនិយាយឲ្យរកទីលំនៅថ្មីទៅ ដ្បិតវត្តត្រូវការចាក់ដីរៀបចំធ្វើរបងនិងសេនាសនៈ ៗ ឈ្មោះទាំងនេះពុំព្រមដើរចេញចេះតែនិយាយអង្វរបណ្ដោះបណ្ដែខែនេះជាខែនោះ រំលងមក ២ ឆ្នាំហើយពុំព្រមដើរចេញ, មើលទៅទំនងជាមនុស្សទាំងនេះមិនងាយនឹងរុះរើលំនៅទេ បើគ្មានអាជ្ញាពីកជការៗ

សេចក្ដីនេះសូមលោកចៅសង្កាត់កោះហៅឈ្មោះទាំងនេះ មកបង្គាប់ឲ្យរើទីលំនៅពីទីវត្តចេញជាប្រញាប់ ដើម្បីនឹងបានចាត់ចែងរៀបចំវត្ត; បើឈ្មោះទាំងនេះពុំព្រមទេ, សូមបញ្ជូនពាក្យនេះទៅសាសាមុខក្រសួងសម្រេចតាមច្បាប់ឲ្យទាន ៗ

ហត្ថលេខា និងឈ្មោះ អាចារ្យវត្ត

x x x

គម្រូសំបុត្រអាចារ្យវត្តប្ដឹងសាលាដំបូង
ពីមនុស្សលបលួចបង្ខិតគោលព្រំដីវត្ត

លេខ...

វត្ត... នៅថ្ងៃទី... ខែ... ពស ២៥... / គស ១៩...

សូមទានឈ្មោះ... ជាតិជាខ្មែរ ទីលំនៅភូមិ...

ជាអាចារ្យវត្ត... សង្កាត់... ស្រុក... ខេត្ត...

---

១ បើផ្តួលស្រែវត្តឬសុំដីវត្តធ្វើរបរដំណាំ ក៏ត្រូវនិយាយទៅតាមទំនងនោះៗ ។

www.elibraryofcambodia.org

សូមក្រាបប្រណិប័តន៍ ចូលមក

លោកអ្នកឧកញ៉ា... ចាងហ្វាងសាលាដំបូង...

សូមបានជ្រាប ។

ដ្បិតឈ្មោះ... ជាតិជាខ្មែរ ប្រពន្ធឈ្មោះ... ទីលំនៅ ។ ភូមិ... សង្កាត់... ស្រុក... ខេត្ត... ដែលមានដីចម្ការ(១) ជាប់ព្រំនឹងដីវត្ត... នេះ មានចិត្តលោភពន់ប្រមាណ ពលតែឆ្នាំចេះតែលបបន្តិតគោលព្រំវត្តពីត្រង់ដីខ្លួនឲ្យចូលមកក្នុងដីវត្ត, ខ្ញុំប្របាទបានឃាត់ដោយវាចាស្រួលច្រើនលើកហើយ, ឈ្មោះនេះនៅតែពុំព្រមស្គាល់ប្រកាន់ថាដីខ្លួនមានព្រំនៅទីនេះ, ខ្ញុំប្របាទហើយនិងចាស់ស្រុកបានប្តឹងជំទប់.... ឃុំនេះឲ្យមកជួយនិយាយ, តែឈ្មោះនេះនៅតែរឹងទទឹងពុំព្រមបន្ថយគោលព្រំដីទៅនៅទីដើមវិញតម្រូវទៅតាមផែនទីរបស់ខ្លួនសោះ ។

ហេតុនេះសូមលោកអ្នកឧកញ៉ា កោះហៅឈ្មោះ... មកជំនុំជម្រះតាមច្បាប់ឲ្យបានត្រឹមត្រូវតាមផែនទីដីរៀងខ្លួនឲ្យបាន ។

គួរពុំគួរសូមអភ័យទោស

ហត្ថលេខា និងនាម អាជ្ញាវិក្ត

x x x

១ បើមានដីស្រែត្រូវដាក់ថាស្រែ ។



www.elibraryofcambodia.org

## គម្រូពុតហ្មាយថ្វាយសម្តេចព្រះសង្ឃរាជ(១)

*សូមព្រះតេជៈគុណលើត្បូង*

*សូមព្រះរាជទានក្រាបបង្គំទូល ក្រោមល្អងធូលីព្រះបាទនៃ*

*សម្តេចព្រះសង្ឃរាជជាអម្ចាស់*

*សូមទ្រង់ជ្រាប ។*

*(តាមរយៈសាលាសង្កាត់...          )*

*(តាមរយៈសាលាអនុគណស្រុក...)*

កម្មវត្ថុ : *(២)ការសូមស្តេចសម្តេចទៅទ្រង់ព្រះរាជទានភ្លើងសពព្រះ...*

---

១ ខ្ញុំ (ឈឹម-ស៊ុម) បានក្រាបបង្គំទូលស្នើសូមធ្វើគម្រូពុតហ្មាយនេះ ។ ពុតហ្មាយនេះត្រូវតែផ្ញើទៅ [illegible] ចំពោះទៅសាលាស្រុក ដោយមានសេចក្តីយល់ព្រមផង តែត្រូវប្រគេនទៅលោកគ្រូអនុគណសិន ។ លោកគ្រូអនុគណត្រូវធ្វើផ្លូវការដែរផ្ញើទៅសាលាស្រុក ។ ២ ត្រង់កម្មវត្ថុនេះ ពុំមែនជាការត្រូវធ្វើទៀងទាត់ដូចគម្រូនេះទេ គឺថាត្រូវបំប្រួញសេចក្តីក្នុងផ្ទៃរឿងទាំងស្រុងឲ្យយកខ្លឹមបំផុតមកដាក់ជាកម្មវត្ថុនេះ ។ ឯសេចក្តីក្នុងផ្ទៃរឿងស្រេចតែយើងមានការដូចម្តេច ត្រូវសរសេរផ្ទៃរឿងនោះឲ្យច្បាស់លាស់ក្បោះក្បាយងាយស្តាប់។

មួយទៀតពាក្យដែលសរសេរ ឬនិយាយចំពោះសម្តេចព្រះសង្ឃរាជនោះត្រូវប្រើរាជស័ព្ទពេញលក្ខណៈ ព្រោះសម្តេចព្រះប្រមុខរដ្ឋទ្រង់ព្រះមេត្តាប្រោសព្រះរាជទានព្រះបរមរាជានុញ្ញាតឲ្យពលរដ្ឋខ្មែរប្រើរាជស័ព្ទចំពោះសម្តេចព្រះសង្ឃរាជដូចក្សត្រធំមួយព្រះអង្គ ។ ខ្ញុំសូមបញ្ជាក់ថាក្សត្រធំៗ មានក្សត្រាមានក្សត្រី, ទាំងអ្នកដែលនិយាយស្រដីទៅរកព្រះអង្គ ក៏មានប្រុសមានស្រីមានទាំងបព្វជិតផង នោះសុទ្ធតែត្រូវផ្លាស់ប្តូរពាក្យរាជស័ព្ទតាមភេទ ។ ឯសម្តេចព្រះសង្ឃរាជជាអគ្គបុរស គេត្រូវប្រើពាក្យសម្រាប់ក្សត្រា ។ អ្នកដែលនិយាយទៅរកព្រះអង្គ ទោះបីគ្រហស្ថក្តី បព្វជិតក្តី ប្រើពាក្យដូចគ្នា លើកលែងតែអ្នកនិយាយជាស្រីនោះត្រូវនិយាយពាក្យជំនួសឈ្មោះខ្លួនថា "ខ្ញុំម្ចាស់" ប្រុសថា "ទូលព្រះបង្គំជាខ្ញុំ" ។ ស្រីឆ្លើយថា "ពរម្ចាស់" ប្រុសឆ្លើយថា "ព្រះករុណាវិសេស" ។ (កាលសម្តេចព្រះសង្ឃរាជព្រះនាម ទៀង គេមិនបណ្តោយឲ្យមនុស្សសាមញ្ញនិយាយផ្ទាល់នឹងព្រះអង្គទេ, ត្រូវព្រះបាឡាត់សង្ឃវង្សជាអ្នកទូលឆ្លង) ។

មេគណខេត្ត... ព្រមទាំងព្រះរាជាគណធម៌ទេសនាផង ។

ដ្បិត . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . .

គួរពុំគួរសូមទ្រង់ព្រះមេត្តាប្រោស

ក្រាបបង្គំទូលថ្វាយនៅថ្ងៃ... ។ ... ឆ្នាំ... ស័ក ព.ស... ត្រូវនឹងថ្ងៃទី .. ខែ... ឆ្នាំ១៩...

ទូលព្រះបង្គំជាខ្ញុំ[១]... ប្រធានគណៈកម្មការចាត់ការបុណ្យសពជាតំណាងសិស្សានុសិស្សនិងពុទ្ធបរិស័ទ ។ ហត្ថលេខា

x x x

បព្វជិតឬគ្រហស្ថ [illegible] ព្រះ

សង្ឃនាយក[២]

... ថ្ងៃទី ... ខែ ... ព.ស. ២៥... / គ.ស. ១៩ ...

សូមនមស្ការក្រាបបង្គំ

ក្រោមព្រះបាទសម្ដេចជាអម្ចាស់ សូមជ្រាប[៣]

ដ្បិតពុទ្ធបរិ[៤]ស័ទដើងវត្ត ... នឹងធ្វើបុណ្យ... នៅថ្ងៃ ... មានសេចក្ដីប្រាថ្នានិមន្តសម្ដេចទៅសម្ដែងធម្មទេសនា[៥] នៅឱកាសបុណ្យ

---

១ ត្រូវសរសេរតាមពិតប្រាកដហើយចុះហត្ថលេខាខាងក្រោមបំផុត ។ ២ ព្រះរាជនិពន្ធសម្ដេចព្រះរាជអប្បយ្យកោវិទប្រណពិទ្ធ ។ ៣ ក្នុងពាក្យថា “ទ្រង់ជ្រាប” ទេ ព្រោះមិនពេញជាស្ដេចសង្ឃ គ្រាន់តែជាសង្ឃតាមរាជនិងប្រើពាក្យថា “ជ្រាប” ជា “សោយ” ពុំបាន ។ ៤ បើខ្លួនឯងត្រូវជាខ្ញុំព្រះករុណា ។ ៥ បើមិនត្រូវជាអធិការឲ្យដាក់តាមសេចក្ដីនោះ ។

www.elibraryofcambodia.org

នេះនៅវេលាយប់ថ្ងៃ... ។ បើមេត្តាសង្គ្រោះនិមន្ត, ខ្ញុំព្រះករុណានឹងយកយានមកទទួលនៅថ្ងៃ... ពេលម៉ោង... ព្រឹក ។

សេចក្ដីគោរពគួរសមបានមេត្តាអភ័យទោស

នាម ហត្ថលេខា និគ្រោ

x x x

បញ្ជិតខ្មីរស្ត្រើនៅកិត្តុចាស់ស្ត្រ

ប្តុក្រហាស្ដើប្រគេនភិក្ខុនាំជូន

... នៅថ្ងៃទី... ខែ... ព.ស. ២៥...
គ.ស. ១៩...

សូមនមស្ការចូលមកលោកគ្រូ

www.elibraryofcambodia.org

សូមបានជ្រាប ។

សូមអភ័យទោស, ដ្បិតខ្ញុំព្រះករុណា មិនដែលបានមកថ្វាយបង្គំសួរសុខ—ទុក្ខសោះ តាំងពីបែកទៅយូរយារណាស់ហើយ ដោយការពលិពោធរវល់(១) ដូចព្រះគុណជ្រាបស្រាប់ ។

សព្វថ្ងៃព្រះគុណបានសេចក្ដីសុខ-ទុក្ខដូចម្ដេច ?

ចំណែកខាងខ្ញុំព្រះករុណា(២)សព្វថ្ងៃបានសេចក្ដីសុខ-ទុក្ខដូចធម្មតារៀងមកទេ, ប៉ុន្តែរមែងមានចិត្តនឹករលឹកមកព្រះគុណជារឿយ ៗ ។

ប្រហែលជាដល់ទៅលំហើយឆ្នាំនេះ នឹងឆ្លៀតមកថ្វាយបង្គំព្រមទាំង

---

១ បើមានធុរៈឈឺឬមានធុរៈអ្វីចម្ដែចត្រូវដាក់តាមធុរៈនោះ ៗ ។ ២ បើជាគ្រហស្ថមានគ្រួសារ ឲ្យចុះជាព្រមទាំងគ្រួសារ ។

មកនិមន្តឲ្យទៅជាអធិបតីក្នុងពិធីបុណ្យផ្កា(១)ផង ។

សេចក្តីគោរពពីខ្ញុំករុណា

នាម និងហត្ថលេខា

x x x

បព្វជិតចាស់វស្សា(២) ផ្ញើទៅភិក្ខុខ្ចីវស្សាជាង

ឬវស្សាស្មើគ្នា

វត្ត... នៅថ្ងៃទី...ខែ... ពស២៥... / គស១៩...

ពិតមកលោក... បានជ្រាប (៣) ។

អំពីចុតហ្មាយ(៤) លោក ចុះថ្ងៃ... ខែ... ឆ្នាំ... ដែលនិមន្តខ្ញុំ(៥)ករុណាទៅសំដែងធម្មទេសនា(៦)នោះ សំបុត្រនេះទើបតែដល់ទៅខ្ញុំករុណានៅថ្ងៃ... ។

ខ្ញុំករុណាបានទទួលនិមន្តន៍គេហួសទៅហើយ, ពុំបានមកក្នុងឱកាសបុណ្យនេះទេ ។

សូមទទួលបដិសណ្ឋារៈនិងសេចក្តីស្វាយដ៏ស្មោះត្រង់អំពីខ្ញុំករុណា ។

នាម និងហត្ថលេខា

x x x

---

១ បើបុណ្យអ្វីឲ្យចុះឈ្មោះបុណ្យនោះឬក៏និមន្តទៅកំសាន្តយកខ្យល់អាកាស ។ ២ សាមណេរចាស់វស្សាក៏អាចប្រើទៅតាមបែបនេះបាន ។ ៣ "បានជ្រាប" គឺមនុស្សតូចជាងឬស្មើគ្នា ។ ៤ "ចុតហ្មាយ" ជាសាធារណៈ សូម្បីសំបុត្រភស្តុក៏ហៅបាន ។ ៥ ខ្ញុំបាព្រះទេ បើខ្ចីវស្សាជាង ។ ៦ បើនិមន្តទៅដើម្បីកិច្ចអ្វីឲ្យចុះទៅតាមនោះ ។

www.elibraryofcambodia.org

បព្វជិតធ្វើថ្វាយព្រះរាជាជាអម្ចាស់ផែនដី

ឬព្រះអគ្គមហេសី(១)

វត្ត... នៅថ្ងៃទី... ខែ.. ឆ្នាំ...

សូមថ្វាយព្រះពរបរមបពិត្រព្រះករុណា

ជាអម្ចាស់ជីវិត

សូមទ្រង់ជ្រាប ។

អាត្មាភាពបានឧបសម្បទជាភិក្ខុភាវៈ ក្នុងបវរពុទ្ធសាសនាបាន(២).. វស្សា; បានសិក្សាបរិយត្តិនិងវិបស្សនាធុរៈតាមសតិបញ្ញា សូមថ្វាយព្រះរាជកុសល ។

www.elibraryofcambodia.org

ក្នុងសម័យនេះស្រុកទេសកើតអសន្តិសុខ រាជការសឹកខាងបារាំងបានទៅដុតបំផ្លាញទីវត្ត...(៣) ខ្ទេចខ្ទីអស់ ដោយចោទប្រកាន់សង្ស័យថា វត្តនេះទទួលឲ្យពួកឥស្សរៈនៅស្នាក់, តែតាមការពិតនោះពុំមែនដូច្នោះទេ, ពួកឥស្សរៈនេះគ្រាន់តែទៅមកម្ដង ១ មួយពេលមួយភ្លែតប៉ុណ្ណោះ, អាត្មាភាពពុំអាចហាមឃាត់រាំងដូចម្ដេចកើត ព្រោះសុទ្ធតែជាពួកមានអំណាច ។

ហេតុនេះអាត្មាភាព នឹងទ្រាំនៅជាបព្វជិតទៅពុំបាន សូមព្រះរាជទានព្រះបរមរាជវរោកាសថ្វាយព្រះពរលាចាកសិក្ខាបទ(៤) កំណត់នៅ

---

១ ព្រះរាជនិពន្ធសម្ដេចព្រះរាជអយ្យកោវរបក្ររណរិទ្ធិ ។ ២ ចុះចំនួនវស្សា ។ ៣ ចុះឈ្មោះវត្ត ។
៤ ឬបើលាចេញទៅនៅទីណាឲ្យចុះទីថ្មីនោះ ។

ថ្ងៃ... ខែ... ឆ្នាំនេះ ។

សូមព្រះរាជទានព្រះបរមរាជានុញ្ញាត ។

គួរពុំគួរសូមទ្រង់ព្រះករុណាប្រោស ។

អាត្មាភាពព្រះ...

ហត្ថលេខា និងនាម

x x x

បញ្ជិតផ្ញើថ្វាយក្សត្រជំទ្រង់យសជាសម្តេច (១)

វត្ត... នៅថ្ងៃទី... ខែ... ឆ្នាំ...

សូមថ្វាយព្រះពរទ្រង់ព្រះករុណាពិសេស

សូមទ្រង់ជ្រាប ។

www.elibraryofcambodia.org

អាត្មាភាពបានទទួលវត្ត ដែលទ្រង់មានព្រះរាជសទ្ធាបរិច្ចាគក្នុងការសិក្សាបរិយត្តិផ្លូវសាសនូបត្ថម្ភពុំឲ្យអន្តរាយ ។

អាត្មាភាពសូមថ្វាយព្រះរាជកុសល សូមទ្រង់សម្រេចឥដ្ឋមនុញ្ញផលតាមព្រះរាជបណិធិ ។

គួរពុំគួរទ្រង់ព្រះករុណាប្រោស

អាត្មាភាព...

នាម និងហត្ថលេខា

x x x

---

១ ព្រះរាជនិពន្ធព្រះរាជអយ្យកោវរចក្រវណរិទ្ធិ ។

## បត្រផិតធ្វើថ្វាយក្សត្រីព្រះអង្គម្ចាស់(១)

វត្ត... នៅថ្ងៃទី... ខែ... ឆ្នាំ...

សូមថ្វាយព្រះពរទ្រង់ព្រះករុណាពិសេស

សូមទ្រង់ជ្រាប ។

ដ្បិតនៅថ្ងៃ... ខែ... ឆ្នាំ... ពួកពុទ្ធបរិស័ទវត្តអាត្មាភាពនឹងរៀបចំ ធ្វើបុណ្យផ្កាព្រមទាំងថ្វាយអាហារទានដល់ព្រះភិក្ខុសង្ឃសាមណេរ ។

មានប្រាថ្នាចង់អញ្ជើញទ្រង់ព្រះករុណាពិសេស ស្ដេចទៅជាអធិបតីក្នុងពិធីបុណ្យនេះ ។

គួរពុំគួរសូមទ្រង់ព្រះមេត្តាប្រោស

www.elibraryofcambodia.org

អាត្មាភាពព្រះ.... ចៅអធិការ

ហត្ថលេខា

x x x

## បត្រផិតធ្វើថ្វាយក្សត្រីអ្នកអង្គម្ចាស់(២)

វត្ត... នៅថ្ងៃទី... ខែ... ឆ្នាំ...

សូមថ្វាយព្រះពរ សូមទ្រង់ជ្រាប ។

អាត្មាភាពបានទទួលបុត្រហ្លាយទ្រង់ប្រទានទៅចុះថ្ងៃ.. ខែ.. ឆ្នាំ... មានសេចក្ដីបញ្ញាថា គតិលោកនិងគតិធម៌ បទត្រង់ណាដែលត្រង់ត្រូវគ្នា ។

---

១ ព្រះរាជនិពន្ធ សម្ដេចព្រះរាជអយ្យកោ វរចក្ររណរិទ្ធិ ។ ២ ព្រះរាជនិពន្ធ សម្ដេចព្រះរាជ-អយ្យកោ វរចក្ររណរិទ្ធិ ។

បញ្ហានេះបើតាមអត្តភាពសន្និដ្ឋាន ឃើញត្រូវគ្នាត្រង់បទប្រដៅថា៖ កុំឲ្យធ្វើទុច្ចរិត ឲ្យធ្វើតែសុចរិត ។ នេះជាពាក្យប្រដៅទូទៅរបស់អ្នកប្រាជ្ញគ្រប់ប្រទេស ត្រង់គ្នាដែលអ្នកស្រុកគេទុកជាការមិនល្អ ។ គតិធម៌ ហាមមិនឲ្យប្រព្រឹត្តទុច្ចរិតដោយកាយវាចាចិត្ត ដើម្បីយកសុខទាំងបច្ចុប្បន្ននិងអនាគត សឹងមានបទព្រះបរមពុទ្ធវចនៈ សម្ដែងទុកមកហើយយ៉ាងពិស្ដារគម្ភីរភាព ដូចទ្រង់ជ្រាបបូលព្រះទ័យស្រាប់ ។

គួរពុំគួរសូមប្រទានទោស

អាត្មាភាពព្រះគ្រូ...

តាម និងហត្ថលេខា

www.elibraryofcambodia.org

x x x

បព្វជិតធ្វើជូនមន្ត្រីជាចៅហ្វាយខេត្តតាមផ្លូវការ

លេខ ..

វត្ត... នៅថ្ងៃទី.. ខែ... ឆ្នាំ...

ព្រះ... មេគណខេត្ត... សូមចម្រើនពរមកព្រះតេជព្រះគុណ លោកអ្នកឧកញ៉ា... ចៅហ្វាយខេត្ត...

សូមជ្រាប ។

តាមដីកាអមលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ...

បញ្ជូនសារាចរលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ពីក្រសួងធម្មការ ដែលឲ្យមេគណក្នុងព្រះរាជាណាចក្រ ហាមប្រាមកុំឲ្យភិក្ខុសាមណេរ

និមន្តទៅកាន់ទីជាអគោចរ មាននិមន្តទៅកាន់ទីផ្សារជាដើម ដែលជាទីទំនាស់នឹងពុទ្ធប្បញ្ញត្តិ ។

អាត្មាភាពបានប្រជុំភិក្ខុសាមណេរក្នុងវត្តបញ្ញត្តជាដាច់ខាតឲ្យប្រព្រឹត្តតាមសារាចរនេះសព្វគ្រប់រួចហើយ ព្រមទាំងបានបញ្ជូនសារាចរនេះទៅគ្រប់វត្តឲ្យប្រតិបត្តិតាមកុំឲ្យធ្វេសប្រហែសផង ។ តែអាត្មាភាពសូមឲ្យប៉ូលិសខេត្ត-ស្រុក ជួយជាកម្លាំងដល់សាសនាផង បើមានភិក្ខុសាមណេរណានិមន្តដើរពាសពេញក្នុងទីផ្សារឬទីឯណាដែលមិនសមរម្យ សូមឲ្យសួរនាមឈ្មោះនិងនាមវត្តកត់ផ្ញើទៅឲ្យអាត្មាភាព ដើម្បីនឹងដាក់ឲ្យគណៈកម្មការសង្ឃធ្វើទណ្ឌកម្មតាមច្បាប់ពុទ្ធចក្រ ។

www.elibraryofcambodia.org

អាត្មាភាពព្រះ...

នាម និងហត្ថលេខា ត្រា

x x x

បព្វជិតផ្ញើជូនមន្ត្រីធីៈសេនាបតីនិងមន្ត្រីមានសក្តិធំ

វត្ត... នៅថ្ងៃទី... ខែ... ឆ្នាំ...

សូមចម្រើនពរមកព្រះតេជព្រះគុណ(១)...

សូមជ្រាប ។

ដ្បិតវត្តអាត្មាភាពឈ្មោះ... ដែលព្រះតេជព្រះគុណបានអញ្ជើញទៅពីថ្ងៃទី... ខែ... ឆ្នាំនេះ នៅឱកាសបុណ្យកឋិនទាន បានឃើញតាមផ្លូវ[illegible]ដែលចែកពីថ្នល់រាជការចូលទៅកាន់វត្តនេះ មានសេចក្តីលំបាក

១ បើសក្តិធំជាងរដ្ឋមន្ត្រី ត្រូវដាក់ជាឯកឧត្តម ។ ត្រង់ចំណុច ៣ ត្រូវថែមងារ ។

នឹងចេញចូលពេក ព្រោះផ្លូវនេះទាបហើយមិនបានក្រាលថ្ម មានភក់ផុង ក្នុងរដូវវស្សាចេញចូលទៅកាន់វត្តដោយលំបាកពេកណាស់ ៗ ហេតុនេះ អាត្មាភាពសុំពឹងលើបុណ្យព្រះតេជព្រះគុណ មេត្តាពន្យល់ទៅអស់លោកមន្ត្រីខេត្តនេះ សុំឲ្យជួយទំនុកបម្រុងធ្វើផ្លូវនេះឲ្យបានស្រួលឲ្យទាន់ផង ៗ

អាត្មាភាព សុំទទួលអំណរជាមុនដោយមានសង្ឃឹមថាផ្លូវនេះនឹងបានក្រាលក្រួសថ្ម ដោយសារបុណ្យព្រះតេជព្រះគុណទុកជាកេរ្តិ៍តទៅពុំខាន ៗ

គួរពុំគួរសូមអភ័យទោស

អាត្មាភាពព្រះគ្រូ...

ហត្ថលេខា តាមនិងត្រា

x x x

## គម្រូសំបុត្រសុំ (ទីត្រឺដង់ទីតេ) សម្រាប់ការគោចរឲ្យបានស្រួល

វត្ត... នៅថ្ងៃទី... ខែ... ឆ្នាំ...

ភិក្ខុ... នៅវត្ត... ជាតិជាខ្មែរ អាយុ... ឆ្នាំ... មាតានាម... បិតានាម... កើតនៅភូមិ... សង្កាត់... ស្រុក... ខេត្ត... សូមចម្រើនពរមក

លោកអ្នកឧកញ៉ា... ចៅហ្វាយស្រុក...

សូមជ្រាប ៗ

អាត្មាភាពត្រូវការសុំសំបុត្រអត្តសញ្ញាណប័ត្រ(ទីត្រឺដង់ទីតេ)ដើម្បីជា

www.elibraryofcambodia.org

ការសំអាងដាក់ច្បាស់ក្នុងការគោចរ ។ ជូនមកជាប់នៅនេះរូបថត៤សន្លឹក បដិញ្ញាណមេឃុំ១...១ច្បាប់,សូមលោកអ្នកឧកញ៉ាចាត់ការចេញច្បាប់នេះ តាមសុំឲ្យបាន

អាត្មាភាពនាម...

ហត្ថលេខា

x x x x

គម្រូសំបុត្រសុំ "ប៉ាស្បូរ" ចេញទៅប្រទេសក្រៅ

វត្ត... នៅថ្ងៃទី... ខែ... ឆ្នាំ...

ភិក្ខុ.. ជាតិជាខ្មែរ អាយុ... ឆ្នាំ ញោមប្រុសឈ្មោះ... ញោមស្រីឈ្មោះ... កើតនៅភូមិ... សង្កាត់... ស្រុក... ខេត្រ...

www.elibraryofcambodia.org

សូមក្រាបនមស្ការចូលមក

ព្រះតេជព្រះគុណ... អនុគណស្រុក...

សូមបានជ្រាប ។

ដ្បិតខ្ញុំព្រះករុណាត្រូវការទៅប្រទេសថៃ[1] ដើម្បីរកជាវគម្ពីរ[2]ធម៌អាថ៌ផ្សេងៗសម្រាប់ការសិក្សា ។

សូមព្រះតេជព្រះគុណមេត្តាបញ្ជូនពាក្យនេះ ដោយយល់ព្រមផង ទៅភជការ[3] មុខក្រសួងសម្រេចច្បាប់ឲ្យបានតាមសុំ ។

---

១ ចុះឈ្មោះប្រទេសដែលត្រូវទៅ ។ ២ ចុះហេតុដែលត្រូវទៅ ។ ៣ សំបុត្រនេះត្រូវឲ្យចៅសង្កាត់បញ្ជាក់ផង ។

សូមជូនមកជាប់នៅនេះ រូបថត៤សន្លឹក និងអត្តសញ្ញាណប័ត្រ ១ ច្បាប់ ។

គួរពុំគួរសូមទានអភ័យទោស

តាមខិត ហត្ថលេខា

x x x

## បណ្ឌិតជាសិស្សទៅកាន់បណ្ឌិតជាគ្រូ

វត្ត... នៅថ្ងៃទី... ខែ... ព.ស. ២៥.. / គ.ស. ១៩...

ភិក្ខុ(១)... សូមនមស្ការមកព្រះតេជព្រះគុណព្រះ... (ងារ) ។

សូមទានជ្រាប ។

ខ្ញុំព្រះករុណា បានមកដល់វត្ត... បាននៅស្នាក់លើកុដិព្រះតេជព្រះគុណ (នាមនិងគោរម្យងារ) លោកមេត្តាទទួលឲ្យនៅ ។ ខ្ញុំព្រះករុណាបានចូលរៀនព្រះបរិយត្តិក្នុងសាលាបាលីរងវត្តនេះ គឺពេលព្រឹករៀនព្រះបរិយត្តិ ពេលល្ងាចនិងយប់រៀនព្រះធម៌វិន័យ ។ សព្វថ្ងៃខ្ញុំព្រះករុណាសុខសប្បាយជាទេ ។ ពាក្យទូន្មានទាំងប៉ុន្មានដែលព្រះតេជព្រះគុណប្រដៅទូន្មាន ខ្ញុំព្រះករុណាតែងតែខំប្រតិបត្តិតាម ហើយខិតខំរៀនមិនមានធ្វេសប្រហែស ។ នៅទីក្រុង ការអាស្រ័យនៅរៀនសូត្រចុះប្រាក់កាសណាស់ ។

គួរពុំគួរសូមទានអភ័យទោស

ភិក្ខុ... ជាសិស្ស

ហត្ថលេខា

x x x

---

១ បើសាមណេរឬតាមភេទខ្លួន ។

## គម្រូសំបុត្រប្រគេនឆន្ទៈ

វត្ត... ថ្ងៃទី... ខែ... ព.ស.២៥... / គ.ស.១៩...

ភិក្ខុ... នាមឆាយា ...នៅកុដិ... ក្រុម... សូមក្រាបនមស្ការចូលមក

ព្រះ... ជាអធិបតីសង្ឃ ដោយសេចក្ដីគោរព

សូមបានជ្រាប ។

ខ្ញុំព្រះករុណាមាន... សូមប្រគេនឆន្ទៈចំពោះ..., មេត្តាអនុញ្ញាតច្បាប់ឲ្យបានចំនួន... លុះដល់ពេលប្រជុំធ្វើឧបោសថថ្ងៃក្រោយនឹងចូលមកកាន់ទីប្រជុំសង្ឃវិញតាមរបៀបសង្ឃករណីយកិច្ច ។

សេចក្ដីគួរពុំគួរសូមមេត្តាប្រោស

www.elibraryofcambodia.org

បានឃើញ

មេកុដិ

នាម និងហត្ថលេខា　　　　　　　　នាម និងហត្ថលេខា

x x x

## គម្រូសំបុត្របុះឈ្មោះរៀនបរិយត្តិក្នុងសាលាបាលីរង

វត្ត... នៅថ្ងៃទី... ខែ... ព.ស.២៥... / គ.ស.១៩...

សាមណេរ... អាយុ... ឆ្នាំ បួសបាន... វស្សា ទីលំនៅសព្វថ្ងៃ នៅវត្ត... សង្កាត់... ស្រុក... ខេត្ត...

សូមក្រាបថ្វាយបង្គំចូលមក

ព្រះតេជព្រះគុណព្រះអាចារ្យសាលាបាលីរង់វត្ត...

សូមបានជ្រាប ។

ខ្ញុំព្រះករុណា មានប្រាថ្នាសិក្សាព្រះបរិយត្តិធម៌ ក្នុងសាលាបាលីរង វត្ត... នេះ ក្នុងថ្នាក់ឆ្នាំទី... ។ សូមព្រះតេជព្រះគុណមេត្តាអនុញ្ញាតឲ្យចុះឈ្មោះខ្ញុំព្រះករុណាក្នុងបញ្ជីសិស្សពេញទីថ្នាក់ទី... ឲ្យបានតាមសេចក្ដីសុំ ខ្ញុំព្រះករុណាសូមប្ដេជ្ញាថា នឹងប្រតិបត្តិតាមច្បាប់បញ្ញត្តិរបស់សាលាបាលីរងនេះដោយដាច់ខាត មិនហ៊ានប្រព្រឹត្តល្មើស ដោយសេចក្ដីប្រមាទដោយហេតុណាមួយឡើយ ។ ក្រែងពុំប្រាកដ ខ្ញុំព្រះករុណាសូមចុះហត្ថលេខាជាភស្តុតាង ខាងក្រោមនេះស្រាប់ ។

សេចក្ដីគួរពុំគួរ សូមបានមេត្តាអភ័យទោស ហត្ថលេខា

សាមណេរ...

www.elibraryofcambodia.org

x x x

គម្រូសំបុត្រសុំច្បាប់ឈប់សម្រាកដោយមានធុរៈ

វត្ត... នៅថ្ងៃទី... ខែ... ព.ស. ២៥... / គ.ស. ១៩..

សាមណេរ... នៅភូមិ... ក្នុងក្រុម... វត្ត... ខ្ញុំព្រះករុណាសូមក្រាបអភិវាទបួលមកព្រះតេជព្រះគុណធម្មាចារ្យ ថ្នាក់ឆ្នាំទី... នៃសាលា... ដោយសេចក្ដីគោរព

សូមបានជ្រាប ។

ខ្ញុំព្រះករុណាមានធុរៈ...(១) សូមព្រះតេជព្រះគុណអនុញ្ញាតច្បាប់ឲ្យបានចំនួន... ថ្ងៃ គិតពីថ្ងៃ... ដល់ថ្ងៃ...; លុះដល់កំណត់ហើយ

---

១ ដាក់ឲ្យចំកិច្ចធុរៈ

នឹងចូលមករៀនវិញតាមកាលវេលារបស់សាលារៀន ។

សេចក្តីគួរពុំគួរសូមទានមេត្តាអភ័យទោស

បានឃើញ　　　　　　　　　　　　　　　　ហត្ថលេខា

មេគុង　　　　　　　　　　　　　　　　　សាមណេរ...

ព្រះគ្រូ...

x x x

គម្រូសំបុត្រសុំប្រឡងចេញពីសាលាបាលីរង(១)

វត្ត... នៅថ្ងៃទី... ខែ .. គ ស ១៩...

សាមណេរ... អាត្មាភាពសូមចម្រើនពរចូលមក

ឯកឧត្តមលោកអ្នកឧកញ៉ាពតក្កសាសនៈ រដ្ឋមន្ត្រីក្រសួងធម្មការ

និងសាសនសិក្សាធិការ

សូមជ្រាប ។

អាត្មាភាពសព្វថ្ងៃនៅវត្ត... សង្កាត់... ស្រុក... ខេត្ត... បាន

សិក្សាព្រះបរិយត្តិធម៌ ក្នុងសាលាបាលីរងវត្តនេះគ្រប់ចំនួន ៣ ឆ្នាំហើយ

ឥឡូវសុំប្រឡងចេញពីសាលាបាលីរងក្នុងខែ... ឆ្នាំ... នេះ តាមកាល

បរិច្ឆេទដែលពជការអនុញ្ញាតឲ្យប្រឡង ។

សូមឯកឧត្តមមេត្តាអនុញ្ញាតឲ្យចុះឈ្មោះអាត្មាភាព ឲ្យអាត្មាភាព

បានចូលប្រឡងក្នុងឆ្នាំ... នេះឲ្យបាន ។

---

១ ជូនតាមរយៈអាចារ្យបង្រៀន ឬហៅអធិការវត្តដែលតាំងសាលានេះ ។

ឯរូបថតនិងសំបុត្រកំណើតដូចបិទជូនមកជាមួយស្រាប់ ។

រូបថត

សេចក្ដីគួរពុំគួរសូមអភ័យទោស

ឆាប និងហត្ថលេខា

x x x

គម្រូសំបុត្រសុំប្រឡងចូលសាលាបាលីជាន់ខ្ពស់

វត្ត... ថ្ងៃ... ។ ... ឆ្នាំ... សក ព.ស. ២៥...

គឺថ្ងៃទី... ខែ... គ.ស. ១៩...

សាមណេរមហា... អាយុ... ឆ្នាំ អាត្មាភាពសូមចម្រើនពរបូលមក

ឯកឧត្ដមលោកអ្នកឧកញ៉ាពិភ័ក្តិសាសនៈរដ្ឋមន្ត្រីក្រសួងធម្មការ

www.elibraryofcambodia.org

សូមជ្រាប ។

អាត្មាភាពបានប្រឡងជាប់បានសញ្ញាប័ត្រសាលាបាលីរងវត្ត... សង្កាត់... ស្រុក... ខេត្ត... ពី គ.ស. ១៩... រួចហើយ ដូចមានចម្លងប្រដូចជូនជាប់មកជាមួយ(១)នេះ; សព្វថ្ងៃនៅវត្ត...(២) ។

អាត្មាភាពត្រូវការនឹងប្រឡងចូលសាលាបាលីជាន់ខ្ពស់ដើម្បីនឹងបានសិក្សាតទៅទៀត ។

សូមឯកឧត្ដមមេត្តាអនុញ្ញាតឲ្យចុះឈ្មោះអាត្មាភាព ឲ្យបានប្រឡងក្នុងឆ្នាំ ១៩... នេះឲ្យបាន ។

---

១ បើមិនទាន់ទទួលសញ្ញាប័ត្រទេត្រូវសរសេរសេចក្ដីថាមិនទាន់បានទទួលសញ្ញាប័ត្រនៅឡើយ ។ ២ បើនៅក្រុងភ្នំពេញត្រូវដាក់ខេកុងនិងខេក្រុង ។

| |
|---|
| រូបថត |

សេចក្ដីគោរពគួរសូមទានអភ័យទោស

សាមណេរមហា...

ហត្ថលេខា

x x x

គម្រូសំបុត្រសម្គាល់កិរិយាមារយាទ

លេខ...

វត្ត... ថ្ងៃ... ៗ ... ឆ្នាំ... ស័ក ព.ស. ២៥...

គឺថ្ងៃទី... ខែ... គ.ស. ១៩...

ចៅអធិការវត្ត... (គណៈមហានិកាយ) ចម្រើនពរចូលមក

www.elibraryofcambodia.org

ឯកឧត្ដមលោកអ្នកឧកញ៉ាពតក្ដីសាសនៈរដ្ឋមន្ត្រី ក្រសួងធម្មការ

សូមទានជ្រាប ៗ

ដ្បិតសាមណេរមហា... សព្វថ្ងៃនៅវត្ត... សង្កាត់... ស្រុក... ខេត្ត... មានសញ្ញាប័ត្រសាលាបាលីរង់វត្ត... សង្កាត់... ស្រុក... ខេត្ត... ពី គ.ស. ១៩... មានបំណងធ្វើជាបេក្ខសមណៈប្រឡងប្រដែងចូលសាលាបាលីជាន់ខ្ពស់ក្នុងខែ... គ.ស. ១៩... នេះ ៗ

សូមឯកឧត្ដមមេត្តាអនុញ្ញាតឲ្យចុះឈ្មោះសាមណេរមហា... នេះជាបេក្ខសមណៈនៃសាលាបាលីរង់វត្ត... ដើម្បីប្រឡងប្រដែងតាមសុំ ៗ សាមណេរនេះមានកិរិយាមារយាទត្រឹមត្រូវល្អ ឥតដែលមានរឿងហេតុហ្មោះហ្មងអ្វីឡើយ ៗ

ជូនជាប់មកជាមួយនេះ លិខិតរបស់សាមីរូប ៣ ច្បាប់គឺ :

— ពាក្យសុំមានរូបថត ១ ច្បាប់

— សំបុត្រកំណើតមួយសន្លឹក

— សេចក្តីចម្លងសញ្ញាប័ត្រសាលាបាលីរង ១ សន្លឹក

ហត្ថលេខា និងនាម

x x x

បព្វជិតនៅបព្វជិតពីសុំផ្ញើសិស្សឲ្យទៅស្នាក់រៀនសូត្រ

វត្តឥន្ទកោសី នៅថ្ងៃទី ១០ កក្កដា $\frac{\text{ព.ស. ២៥១២}}{\text{គ.ស. ១៩៦៨}}$

វរមេធោ, ចៅអធិការ សូមនមស្ការមក

ព្រះតេជព្រះគុណព្រះធម្ម[illegible] ( [illegible] )

សូមមានជ្រាប ។

សាមណេរសុធន (វិជិតបណ្ឌិតោ ) ដែលកាន់សំបុត្រនេះមកជាកូនសិស្សខ្ញុំព្រះករុណា, រៀនសូត្របានប្រឡងជាប់ទីមហាបរិយត្តិបឋមវិជ្ជាហើយ បន់មករៀនឯក្នុងពេញ ដើម្បីត្រៀមចាំប្រឡងចូលសាលាបាលីជាន់ខ្ពស់, សូមព្រះតេជព្រះគុណមេត្តាផែលលកបែកកន្លែងស្នាក់មួយកន្លែងលើកុដិព្រះតេជព្រះគុណឲ្យសាមណេរនេះនៅ ទុកជានិស្ស័យនេ្តវាសិក ហើយសុំស្តីប្រដៅទូន្មានឲ្យមានផង ដ្បិតសាមណេរនេះកំព្រាគ្មានញោមឧបដ្ឋាកនឹងគេទេ, ខ្ញុំព្រះករុណាទំនុកបម្រុងសាមណេរនេះតាំងពីកុមារតូចមក ឃើញមានកិរិយាមារយាទល្អ ជាអ្នកស្លូតសុភាពរៀបសា ។

www.elibraryofcambodia.org

១ ទៀតសូមផ្ញើអង្ករ ១ ការុង និងស្ករ១ស្រាក់មកប្រគេន ។

សេចក្ដីគួរពុំគួរសូមអភ័យទោស

ជា-សុខ វរមេធា

ហត្ថលេខា

x x x

បណ្ឌិតជាសិស្សទៅកាន់បណ្ឌិតជាគ្រូ

វត្ត... នៅថ្ងៃទី... ខែ... ឆ្នាំ...

ភិក្ខុ(១)... សូមក្រាបថ្វាយបង្គំចូលមក

ព្រះតេជព្រះគុណចៅអធិការវត្ត .. ជាធម្មាចារ្យ(២)

www.elibraryofcambodia.org

សូមទានជ្រាប ។

ព្រះតេជព្រះគុណជាធម្មាចារ្យ បានប្រកបដោយសេចក្ដីសុខដូចកាលសព្វដងរៀងមកទេ ឬដូចម្ដេច ?

ចំណែកខ្ញុំព្រះករុណា បានសេចក្ដីសុខ-ទុក្ខជាធម្មតាទេ, ប៉ុន្តែសព្វថ្ងៃនេះ មានចិត្តនឹករលឹកមកព្រះតេជព្រះគុណរឿយ ៗ, តែងប្រតិបត្តិតាមឱវាទរបស់ព្រះតេជព្រះគុណជានិច្ចពុំហ៊ានប្រហែសធ្វេស ។

មួយវិញទៀត ខ្ញុំព្រះករុណាបានប្រឡងប្រជែងចូលសាលាបាលីជាន់ខ្ពស់ជាប់ហើយ នឹងខំប្រឹងប្រែងរៀនសូត្រឲ្យចាល់តែដល់ទីបំផុតពុំខាន ។

---

១ ត្រូវប៉ុះនាមខ្លួន ។ ២ ត្រូវដាក់ងារឋានៈរបស់លោកគ្រូ ជាអ្វី ?

សូមផ្ញើទេយ្យវត្ថុតាមបម្រើនេះមក គឺ តែជ័ល្អ ៣ កញ្ចប់, ស្ករតាំងស៊ិន ១ ប្រអប់, ទឹកម៉ូណាត់ ៣ ដប, សូមព្រះតេជព្រះគុណទទួលដោយសេចក្ដីសង្គ្រោះ ។

សេចក្ដីគួរពុំគួរសូមទានអភ័យទោស

ភិក្ខុ... ខ្ញុំព្រះករុណាជាសិស្ស

ហត្ថលេខា

x x x

កម្រងសំបុត្រសរសេរទៅមិត្រភក្តិជាបព្វជិតដូចគ្នា

វត្តជោតនារាម នៅថ្ងៃទី២០ សីហា ពស២៤៩៦ / គស១៩៥៣

ពិតមកញាណប្បទីបោ ជាកល្យាណមិត្ត ។

www.elibraryofcambodia.org

សុំសួរសេចក្ដីសុខ-ទុក្ខគ្រប់ប្រការរបស់កល្យាណមិត្ត, ខ្ញុំព្រះករុណានៅឯនាយបានសេចក្ដីសុខ-ទុក្ខសម្រាប់ខន្ធជាធម្មតា, តែងមានចិត្តនឹករលឹកមកមិត្រជឿយៗ ដោយនឹកស្រណោះភ្ជាប់នៅរួបរួមរៀនសូត្រ ជាមួយគ្នា ។

មួយទៀតខ្ញុំករុណាទើបតែនឹងប្រឡងជាប់ទីមហាបរិយត្តិបឋមវិជ្ជា (សាលាបាលីរង) ក្នុងខែមុននេះ, ឥឡូវចង់មកស្នាក់រៀនសូត្រត្រៀមចាំប្រឡងចូលសាលាបាលីជាន់ខ្ពស់ សូមមិត្រជួយទំនុកបម្រុងរកទីកន្លែងក្នុងកុដិណាមួយដើម្បីស្នាក់រៀនសូត្របន្តវិជ្ជា ។ បើបានឬមិនបាន, សូមមិត្រឲ្យដំណឹងទៅខ្ញុំករុណាវិញផង ។

សូមមិត្រទទួលនូវសេចក្ដីរាប់អានដ៏ស្មោះស្ម័គ្រ និងអំណរគុណទុកជាមុនអំពីខ្ញុំករុណា ។

ឧត្តម-ឯក (សត្ថានុរក្ខិតោ)

ហត្ថលេខា

x x x

បព្វជិតទៅបព្វជិតជាគ្រូសុំលាចាកសិក្ខាបទ

វត្ត... នៅថ្ងៃទី... ខែ... ឆ្នាំ ..

សូមពានភិក្ខុ ម៉ី-ម៉ាន់ (ញាណវិន្ទោ) សូមនមស្ការចូលមក

ព្រះតេជព្រះគុណព្រះមុនីសង្វរ (វិធុរបណ្ឌិតោ) វត្តមុនីពម

www.elibraryofcambodia.org

សូមពានជ្រាប ។

ដ្បិតខ្ញុំព្រះករុណាដែលបានបង្គំលាទៅរៀនសូត្រ ឯក្រុងភ្នំពេញចំនួន ៤ ឆ្នាំហើយនោះ ឥឡូវប្រឡងជាប់ទីមហាបរិយត្តិឧត្តមវិជ្ជា ចេញពីសាលាបាលីជាន់ខ្ពស់ហើយ ។

វិជ្ជាដ៏ប្រសើរដែលព្រះតេជព្រះគុណប្រទានឲ្យហូរហែមក ធ្វើឲ្យខ្ញុំព្រះករុណាមានកេរ្ដិ៍ឈ្មោះរហូតមកដល់សព្វថ្ងៃ, ខ្ញុំព្រះករុណាឥតមានធ្វេសប្រហែសនឹងនឹកគុណទាំងប៉ុន្មានរបស់ព្រះតេជព្រះគុណទេ; ពុំដឹងនឹងបានអ្វីតបស្នងសងនូវគុណដ៏ធ្ងន់ក្រៃលែងនេះ, មានតែសេចក្ដីគោរពពាក្យប្រៀនប្រដៅនេះ ដែលខ្ញុំព្រះករុណាមិនហ៊ានធ្វើឲ្យកន្លងឡើយ ។

ម្យ៉ាងទៀត មើលទៅពុំសង្ឃឹមថានឹងប្រព្រឹត្តព្រហ្មចរិយៈឲ្យអស់កាល

ដឹងអន្លង់ទៅបានព្រោះមានសេចក្ដីអផ្សុក ខ្ញុំព្រះករុណានឹងទ្រាំទ្រទៅជាបព្វជិតគាន់គេចបព្វជ្ជាតទៅពុំកើត ខ្ញុំព្រះករុណាសូមលាចាកសិក្ខាបទនៅថ្ងៃទី ១០ កុម្ភៈឆ្នាំនេះ, សូមមេត្តាអនុញ្ញាតឲ្យបាន ។

សេចក្ដីគួរពុំគួរសូមបានអភ័យទោស

ម៉ុ-ម៉ាន់(ញាណទិន្នោ) ជាសិស្ស

ហត្ថលេខា

x x x

បព្វជិតនៅកាន់មាតាបិតា ជាគ្រហស្ថ

វត្ត.. នៅថ្ងៃទី... ខែ... ឆ្នាំ...

...(១)ចម្រើនពរមកញោម(២)

www.elibraryofcambodia.org

សូមជ្រាប ។

សូមសួរសេចក្ដីសុខ-ទុក្ខញោម(៣) ។ អាត្មាភាព សព្វថ្ងៃនេះបានសេចក្ដីសុខ-ទុក្ខដូចធម្មតាទេ, តែមានចិត្តនឹករលឹកមកញោមព្រមទាំងបងប្អូនទាំងអស់គ្នារឿយ ៗ ។ សព្វថ្ងៃអាត្មាភាពកំពុងប្រឹងប្រែងខំរៀនសូត្រព្រះបរិយត្តិធម៌ និងព្រះធម្មវិន័យ បានជាមិនបានមកសួរសេចក្ដីសុខ-ទុក្ខផ្ទាល់ ៗ ម្យ៉ាងទៀត ដល់ជាប់ឆ្នាំនេះនឹងប្រឡងចូលសាលាបាលីជាន់ខ្ពស់ទៀត ។

អាត្មាភាពត្រូវការបច្ច័យចំនួន... រៀល ដើម្បីយកទៅរក

---

១ ត្រូវដាក់ជាភិក្ខុ ឬសាមណេរ ។ ២-៣ បើសរសេរទៅឪពុកធំ មា ម៉ីង ឬញោមខបផ្លាក ឲ្យប្ដូរតាមនោះ ។

ជាវគម្ពីរនិងសៀវភៅផ្សេង ៗ ដែលត្រូវការសិក្សា ។

គួរពុំគួរសូមអភ័យទោស

ហត្ថលេខា

x x x

## គ្រូជាបព្វជិតទៅកាន់សិស្សមានបណ្ដាស័ក្តិជា

## គ្រហស្ថ

វត្ត... ទៅថ្ងៃទី... ខែ... ឆ្នាំ...

ព្រះគ្រូ... ចៅអធិការវត្ត... សង្កាត់... ស្រុក... ខេត្ត...

ចម្រើនពរមកឧកញ៉ា... ចៅហ្វាយស្រុក... ជាសិស្ស

www.elibraryofcambodia.org

បានជ្រាប ។

អាត្មាទើបតែបានទទួលដំណឹងថា រាជការបានតាំងឧកញ៉ាឲ្យមកកាន់តំណែងជាចៅហ្វាយស្រុក... ដែលជាស្រុកសម្បូរសប្បាយ ។ អាត្មាមានសេចក្ដីត្រេកអរពន់ពេក សុំឲ្យឧកញ៉ាបំពេញករណីយកិច្ចនេះដោយសុចរិត តាមសេចក្ដីវាងវៃរបស់ឧកញ៉ា ដើម្បីឲ្យបានមានកេរ្តិ៍ឈ្មោះតទៅ ។ អាត្មាផ្ញើពរជូនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ចូរមានដល់ឧកញ៉ានិងភរិយាបុត្រព្រមទាំងមាតាបិតារបស់ឧកញ៉ា ។

ហត្ថលេខា

x x x x

## គ្រូជាបព្វជិតទៅកាន់សិស្សជាគ្រហស្ថសាមញ្ញ

(គ្រហស្ថ)

វត្ត... នៅថ្ងៃទី... ខែ... ឆ្នាំ...

...[១] ចៅអធិការវត្ត .. សង្កាត់... ស្រុក... ខេត្ត...

ចម្រើនពរមកអ្នកបណ្ឌិត... ព្រមទាំងភរិយា

បានដឹង ។

អាត្មាសួរសុខទុក្ខមកអ្នកបណ្ឌិត ព្រមទាំងគ្រួសារ ។ ចំណែកអាត្មា បានសេចក្ដីសុខទុក្ខជាធម្មតាទេ ។ ឯគម្ពីរដីការបស់អ្នក ដែលអ្នកបានតម្កល់នៅទីវត្តនោះ អាត្មាបានដាក់ឲ្យកុលបុត្រសិក្សាតែសព្វថ្ងៃ, សុំឲ្យអ្នកទទួលកុសលនេះជាកំណាប់ទ្រព្យទៅអនាគតចុះ, សុំឲ្យអ្នកបានប្រកបដោយសេចក្ដីសុខចម្រើនគ្រប់ប្រការតទៅ ។

www.elibraryofcambodia.org

នាម និងហត្ថលេខា

x x x

## សិស្សមានបណ្ដាស័ក្តិនិងសិស្សជាសាមញ្ញជន ទៅកាន់គ្រូជាបព្វជិត

...[២] នៅថ្ងៃទី... ខែ... ឆ្នាំ...

សូមនមស្ការមកព្រះតេជព្រះគុណ....

សូមទានជ្រាប ។

---

១ បើជាមន្ត្រីសង្ឃត្រូវចុះងារ, បើជាចៅអធិការសាមញ្ញត្រូវចុះនាមឆាយា ។ ២ ឈ្មោះភូមិលំនៅ ។

ក្រោយពីកាលដែលខ្ញុំព្រះករុណាចេញពីសំណាក់ព្រះតេជព្រះគុណទៅ ខ្ញុំព្រះករុណាមែនផ្លាស់ប្ដូរទីកន្លែងញឹក ៗ អណ្តែតដូចបក ពុំសូវបាននៅនឹងមួយកន្លែងទេ ថែមទាំងមានកង្វល់នឹងការងារជាសម្មាអាជីវៈផង ។ ហេតុនេះបានជាពុំសូវបានមកថ្វាយបង្គំសួរសុខ-ទុក្ខ, ប៉ុន្តែតែងប្រតិបត្តិតាមសេចក្ដីទូន្មានរបស់ព្រះតេជព្រះគុណជាដរាបរៀងមក ។

ខ្ញុំព្រះករុណាតែងមានចិត្តនឹករលឹក ដល់ព្រះគុណធ្ងន់ក្រៃពេកថា ថ្ងៃណាមួយនឹងនាំគ្រួសារមកក្រាបថ្វាយបង្គំពុំខាន ។

ខ្ញុំព្រះករុណាសូមផ្ញើតម្លៃបច្ច័យចំនួន... រៀល មកប្រគេន, បើព្រះតេជព្រះគុណត្រូវការបច្ច័យណាមួយ, សូមមានសួរកេយកពីវេយ្យាវច្ចករឲ្យស្មើនឹងតម្លៃ....រៀល ជារបស់ខ្ញុំព្រះករុណា ទាល់តែគ្រប់ចំនួនឲ្យបាន ។

គួរពុំគួរសូមមានអភ័យទោស

នាម ហត្ថលេខា

x x x x

សេចក្ដីរំលឹក

១- បើយើងសរសេរលិខិត ត្រូវសរសេរដោយក្រដាស ស ឈាត មិនត្រូវយកក្រដាសបន្ទាត់ស្រាប់មកសរសេរឡើយ ។

២- តាមទំនៀមទម្លាប់ពីបុរាណមក លិខិតទាំងឡាយដែលសរសេរជាការផ្ទាល់ខ្លួនថ្វាយព្រះរាជា ជាអម្ចាស់ផែនដី, ក្សត្រ, មន្ត្រីសក្តិធំ ឬជនជាបុព្វការី ត្រូវសរសេរដោយក្រដាសបត់ជាប់គ្នាពីរសន្លឹកជាដរាប ។

www.elibraryofcambodia.org

ការសរសេរទៀត ក៏ត្រូវសរសេរឲ្យរៀបរៀងទៅតាមទំព័រ កុំរលងទំព័រឲ្យសោះ, ហើយត្រូវទុកក្បាលសន្លឹកឲ្យធំបន្តិច ឧបមាថា បើក្រដាសទំហំ១៨×២៤ត្រូវឲ្យសល់ខាងដើមបន្ទាត់ចំនួន៥សន្ទីម៉ែត្រ ។

៣- ការសរសេរលិខិត ត្រូវតែយើងវែលគឲ្យបានសមល្អ គឺថាត្រូវវែលទំហំក្រដាសឲ្យសមទៅតាមសេចក្តីវែង-ខ្លី ។

៤- លិខិតផ្ទាល់ខ្លួនមិនត្រូវបោះត្រាសម្រាប់ការទេ ។

៥- ចុតហ្មាយផ្ទាល់ខ្លួន ឬជាផ្លូវការដែលថ្វាយទៅព្រះមហាក្សត្រិយ៍ ក៏មិនត្រូវបោះត្រាសម្រាប់ការដែរ ។

www.elibraryofcambodia.org

## វគ្គទី ៧

## គម្រូកម្មវិធីបុណ្យផ្សេងៗ

### បែបបោះពុម្ព

សេចក្ដីប្រើបានជាសាធារណៈ វៀរតែធ្វើថ្វាយព្រះរាជា
ជាអម្ចាស់ផែនដី (ប្រើក្រដាសរឹមខ្មៅ)

www.elibraryofcambodia.org

**មរណៈ**

ឧកញ៉ា... និងភរិយា

ព្រះ... និងភរិយា

នាងក្រមុំ... នាយ...

យើងខ្ញុំមានទុក្ខជាទម្ងន់ ដ្បិតលោក... ជាបិតាក្មេក បិតាបង្កើត ជីតាក្មេក ជីតាបង្កើត ទទួលមរណភាព នៅវេលាម៉ោង... នៃថ្ងៃ... ខែ... ឆ្នាំ... ក្នុងកំណត់ជន្មាយុ... ឆ្នាំ

សពនេះនឹងរំកិលចេញចាកគេហស្ថានលេខ... ផ្លូវ... ក្រុង.... នៅថ្ងៃ... វេលាម៉ោង... ដើម្បីធ្វើឈាបនកិច្ច (ឬបញ្ចុះ) នៅទី... វេលា... ម៉ោង... ។

# បែបការខ្នងសំបុត្រ

បុរសឬស្ត្រី ធ្វើថ្វាយព្រះរាជា

សូមព្រះរាជទានក្រាបបង្គំទូលថ្វាយ
ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង
ព្រះបរមរាជវាំងចតុម្មុខ។

បុរសឬស្ត្រីធ្វើថ្វាយក្សត្រធំ

ក្រាបបង្គំទូលថ្វាយ
សម្តេចឬព្រះអង្គម្ចាស់ . . .
វាំងស្រះបទុម (ឬអ្វីតាមនាម)

បុរសឬស្ត្រី ធ្វើថ្វាយក្សត្រទីអ្នកអង្គម្ចាស់

ថ្វាយ
អ្នកអង្គម្ចាស់ . . .
ភ្នំពេញ

បព្វជិតឬបុរសស្ត្រី ធ្វើជូនមន្ត្រីធំទីសម្តេច

លោកសម្តេច . .
ភ្នំពេញ

www.elibraryofcambodia.org

បព្វជិតធ្វើថ្វាយព្រះរាជា

ថ្វាយ
ព្រះករុណា ជាអម្ចាស់ជីវិត
ព្រះបរមរាជវាំងចតុម្មុខ

បព្វជិតធ្វើថ្វាយក្សត្រទីអ្នកអង្គម្ចាស់

ថ្វាយ
អ្នកអង្គម្ចាស់ . . .
ភ្នំពេញ

បព្វជិតធ្វើថ្វាយក្សត្រធំ

ថ្វាយ
សម្តេចឬព្រះអង្គម្ចាស់ . . .
វាំង (នាមអ្វី)

បព្វជិតឬបុរសស្ត្រីធ្វើជូនមន្ត្រីទីសេនាបតី

លោកអ្នកឧកញ៉ា . . .
សេនាបតីក្រសួង . . .
ភ្នំពេញ

ថ្វាយព្រះសង្ឃនាយក

| |
|---|
| ថ្វាយ |
| សម្តេចព្រះ(នាម) ... |
| សង្ឃនាយកគណៈមហានិកាយ |
| វត្តឧណ្ណាលោម |

ថ្វាយព្រះសង្ឃនាយក

| |
|---|
| ថ្វាយ |
| សម្តេចព្រះ . . . |
| សង្ឃនាយកគណៈធម្មយុត្តិ |
| វត្តបទុមវតី |

ប្រគេនព្រះរាជាគណៈឬឋានានុក្រម

| |
|---|
| ប្រគេន |
| ព្រះតេជព្រះគុណព្រះ ... |
| វត្ត . . . |

ប្រគេនលោកចៅអធិការ

| |
|---|
| ប្រគេន |
| លោកគ្រូចៅអធិការវត្ត . . . |
| សង្កាត់... ស្រុក... ខេត្ត... |

www.elibraryofcambodia.org

ជូនមន្ត្រីមិនមែនសេនាបតី

| |
|---|
| លោក . . . |
| នាយការិយាល័យ |
| ក្រសួង . . . |
| ក្រុងភ្នំពេញ |

សម្រាប់ភិក្ខុឥតឋានន្តរស័ក្តិ

| |
|---|
| ព្រះភិក្ខុ . . . |
| វត្ត... សង្កាត់... ស្រុក... |
| ខេត្ត... |

ផ្ញើតាមប៉ុស្តិ៍សម្រាប់អ្នកក្រុង

| |
|---|
| ស៊ុម-វណ្ណ, លេខ ១៤ ផ្លូវអង្គឌួង កំពត |
| តែមប្រៃ |
| លោក . . . |
| ផ្ទះលេខ . . . វិថី . . . |
| ក្រុង . . . |

អ្នកស្រែ-ចម្ការដែលឥតបណ្តាស័ក្តិ

| |
|---|
| នាយឬអ្នក ... |
| ភូមិ... សង្កាត់... ស្រុក... |
| ខេត្ត... |

# របៀបធ្វើសំបុត្រអញ្ជើញភ្ញៀវបែបទី ២

## វិវាហមង្គល

| | |
|---|---|
| ឧកញ៉ាឬព្រះ... (នាម) និងភរិយា | ឧកញ៉ាឬព្រះ... ឬនាយ... (នាម) |
| ខ្ញុំរៀបការកូនប្រុសនាមនាយ (នាមកូនប្រុស) | និងភរិយា |
| ស្មៀនសាលាខេត្ត...ឬនាយការិយាល័យ... | ខ្ញុំរៀបការកូនស្រីនាមនាង (នាមកូនស្រី) |

ចំរើនព្រះពុទ្ធមន្តនៅថ្ងៃ... ខែ... ឆ្នាំ... នេះ ព្រឹកឡើងសំពះទទួលស្លាពារ

សូមអញ្ជើញ

ជាសិរីសួស្តីជ័យមង្គលព្រមទាំងពិសារលៀងភោជនាហារដោយមេត្រី នៅគេហដ្ឋានខាងស្រី

លេខ... ផ្លូវ... ក្រុង... នៅវេលាម៉ោង.... ថ្ងៃ... ខែ... ឆ្នាំ.... នេះ ។

www.elibraryofcambodia.org

## បែបបោះពុម្ព

សេចក្ដីធ្វើពាក្យយ៉ាងមធ្យម ប្រើបានជាសាធារណៈ វៀរមួយតែធ្វើថ្វាយព្រះរាជាជាម្ចាស់ផែនដី ។

## ចូឡាភេបធមង្គល

ឧកញ៉ា . . . ឬនាយ . . . និងភរិយា នឹងរៀបមង្គលកោរសក់ នាយ . . . ជាបុត្រ (១) ឬនាង . . . ជាបុត្រី ។

ចំរើនព្រះបរិត្តនៅថ្ងៃទី... ខែ... ឆ្នាំ... វេលាម៉ោង... ល្ងាច កោរសក់នៅថ្ងៃទី... វេលាម៉ោង... ព្រឹក ។

សូម(អញ្ជើញ(២)ទៅ) ជាសិរីសួស្ដីជ័យមង្គល ព្រមទាំងទទួលការជប់លៀងភោជនាហារវេលាម៉ោង... ថ្ងៃ... ខែ... ឆ្នាំ... នាគេហដ្ឋានលេខ... ផ្លូវ... ក្រុង... ។

## កម្មវិធីបុណ្យកឋិន

សូមជំរាបអស់លោក–អ្នក ជាសប្បុរសទាំងឡាយ សូមជ្រាប ។ វត្តអម្ពិល ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង មានកុដិ សាលា វិហារ ចាស់ទ្រុឌទ្រោមគ្រាំគ្រាស្ទើរតែទាំងអស់ ។ សព្វថ្ងៃពួកឧបាសកឧបាសិកាជើងវត្ត មានព្រះគ្រូមុនីសោភ័ណ សេក–នាង សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ជាអ្នកជួយចាត់ការ កំពុងនាំគ្នាកសាង

---

១ ដាក់ថា «បុត្រ» ប៉ុណ្ណឹងបានហើយ មិនបាច់ដាក់ថា «បុត្រា» ទេ, បើជាវត្តយត្រកូលវិញ ដាក់ថា «បុត្រា» ក៏បាន ។ ២ ត្រង់វង់ក្រចកនេះ បើអញ្ជើញក្សត្រ គោរពសរសេរថា «ស្ដេចទៅ» ។

www.elibraryofcambodia.org

សាលាបាលីរង ១ ខ្នង ដោយឥដ្ឋ-ស៊ីម៉ងត៍-ឈើ បានកំពស់ពីដីជាង ៤ ម៉ែត្រហើយ ប៉ុន្តែនៅខ្វះគ្រឿងទព្វសម្ភារៈច្រើន ។

ឥឡូវនេះ យើងទាំងអស់គ្នា ដូចមាននាមខាងក្រោមនេះ បានព្រមព្រៀងគ្នាផ្តើមធ្វើអង្គកឋិនមួយ ដើម្បីព្រះសង្ឃដែលគង់ចាំព្រះវស្សាអស់ត្រៃមាសក្នុងវត្តនោះផង ដើម្បីជួយទំនុកបម្រុងការកសាងសាលា-បាលីរងក្នុងវត្តនោះផង ។

សូមអស់លោក-អ្នក ជាសប្បុរសទាំងឡាយ អញ្ជើញទៅជួយឧបត្ថម្ភបុណ្យនេះ តាមកម្លាំងសទ្ធា ដូចមានកាលបរិច្ឆេទតទៅនេះ

## កាលបរិច្ឆេទ

ថ្ងៃសៅរ៍ ៩កើតខែអស្សុជ ឆ្នាំម្សាញ់បញ្ចស័ក (ត្រូវ [illegible]-១០-៥៣ www.elibraryofcambodia.org វេលាម៉ោង៨យប់ចំរើនព្រះបរិត្ត ទេសនា នៅសាលាបុណ្យវត្តស្វាយជ្រំ ឃុំស្វាយជ្រំ ស្រុកស្វាយរៀង ខេត្តស្វាយរៀង ។ ព្រឹកឡើងថ្ងៃអាទិត្យ ១០ កើត ខែឆ្នាំដដែល វេលាម៉ោង៩ ដង្ហែអង្គកឋិនឆ្ពោះទៅវត្តអម្ពិលនោះ វេរកឋិនផ្គងបង្ហើយបុណ្យក្នុងពេលនោះ ។

## អ្នកផ្តើមបុណ្យ

១– លោកគ្រូ ដុក-ផង់ ចៅអធិការវត្តស្វាយជ្រំ

២– មេឃុំ ស្រី-នួន និងអ្នកស្រី អន-ពៅ ឃុំស្វាយជ្រំ

៣ . . . . . . . . . . . . . . . . . . . . . .

៤ . . . . . . . . . . . . . . . . . . . . . .

៥ . . . . . . . . . .

x x x

# បុណ្យផ្កា

## សាងសង់វិហារនៅលុម្ពិនី

ព្រះមហាក្សត្រិយ៍ប្រទេសនេប៉ាល់ ទ្រង់មានព្រះរាជហឫទ័យជ្រះថ្លាចំពោះព្រះពុទ្ធសាសនា ទ្រង់បានប្រោសប្រទានព្រះបរមរាជានុញ្ញាតដល់ពុទ្ធិកសមាគមហៅថា ធម្មោទយសភា នៅក្រុងកត្តមណ្ឌុ ប្រទេសនេប៉ាល់ ឲ្យសាងសង់វិហារមួយនៅលុម្ពិនី គឺត្រង់តំបន់ដែលព្រះសក្យមុនីសម្មាសម្ពុទ្ធជាបរមគ្រូទ្រង់ប្រសូតិ ៗ ធម្មោទយសភាបានជូនដំណឹងមកយើងថា: នឹងត្រូវធ្វើបុណ្យយ៉ាងធំ, ត្រូវប្រជុំធ្វើនៅលុម្ពិនី នៅថ្ងៃទី ២៧ និងទី ២៨ ឧសភា ១៩៥៣ នេះ ដោយមាន

www.elibraryofcambodia.org

ពុទ្ធសាសនិកជនជាតំណាងប្រទេសនានានៅជួបជុំផង ៗ ប្រទេសកម្ពុជាយើងក៏គួរតែចេញមុខចូលបច្ច័យតាមសទ្ធា យកទៅជួយកសាងវិហារនោះ ជាមួយនឹងគេផងដែរ ទើបសមដល់តម្លៃរបស់ប្រទេសយើងដែលគោរពព្រះពុទ្ធសាសនា ៗ

ដោយហេតុនេះ ពុទ្ធិកសមាគម កម្ពុជរដ្ឋ និងសមាគមមិត្រសាលាបាលី យល់ឃើញថា: ត្រូវយើងប្រជុំគ្នាធ្វើបុណ្យផ្កាពិសេសមួយ ដោយរួបរួមគ្នាឲ្យបានបច្ច័យតាមកម្លាំងសទ្ធា យកទៅជួយកុងការសាងសង់វិហារនោះ ដើម្បីឲ្យប្រទេសខ្មែរមានឈ្មោះជាម្ចាស់នៃវិហារនោះជាមួយនឹងគេផង ៗ បុណ្យផ្កាពិសេសនោះ នឹងធ្វើនៅសាលាបាលីជាន់ខ្ពស់តាមកម្មវិធីដូចខាងក្រោមនេះ :

ថ្ងៃសុក្រ ១០ កើត ខែជេស្ឋ គឺថ្ងៃទី ២២ ឧសភា ១៩៥៣ នេះ វេលាម៉ោង ៨ យប់ និមន្តព្រះសង្ឃចំរើនព្រះបរិត្ត រួចនិមន្តសម្តេចព្រះមហាសុមេធាធិបតី ថ្លែងសេចក្តីអំពីប្រវត្តិនៃលុម្ពិនីជាទីតាំងដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រសូតិ ព្រមទាំងសម្តែងអំពីការដែលព្រះមហាក្សត្រិយ៍ប្រទេសនេប៉ាល់ទ្រង់ផ្តើមការសាងសង់វិហារនោះផង ។ បន្ទាប់មក ត្រូវប្រកាសពីបច្ច័យដែលបានក្នុងឱកាសបុណ្យផ្កាពិសេសនោះ ។

ការកុសលនេះ រាប់ចូលក្នុងសេនាសនទានដែរ ប៉ុន្តែប្លែកគ្នាត្រង់ការកសាងជាសាកលផង ត្រង់ការសាងសង់វិហារនោះនៅកន្លែងដែលព្រះសព្វញ្ញុពុទ្ធជាបរមគ្រូរបស់យើងទ្រង់ប្រសូតិនោះផង ដែលគួរឲ្យយើង

www.elibraryofcambodia.org

មានសេចក្តីពេញចិត្ត មានសេចក្តីជ្រះថ្លា ។

សូមពុទ្ធបរិស័ទជួយឧបត្ថម្ភតាមកម្លាំងសទ្ធា ដើម្បីជាកំណប់បុណ្យរបស់យើង និងកិត្តិយសនៃប្រទេសខ្មែរ ។

x x x

## បុណ្យឆ្លងមហាកុដិ

កុដិធំថ្មីវត្តឧណ្ណាលោម សម្រាប់សម្តេចព្រះសង្ឃនាយក ដែលយើងជាពុទ្ធបរិស័ទក្នុងក្រុងភ្នំពេញនិងខេត្រក្រៅ បានរួបរួមគ្នាសង់នោះ ហើយស្រេចគួរធ្វើបុណ្យឆ្លងបានហើយៗ ឯកំផែងខាងមុខកុដិធំនោះពុំទាន់បានធ្វើនៅឡើយ ចាំកាលណាមានស៊ីម៉ង់ត៍មកដល់សឹមធ្វើតទៅទៀត ។

យើងខ្ញុំបានប្រឹក្សាព្រមព្រៀងគ្នាថា ត្រូវធ្វើបុណ្យឡើងឲ្យទាន់ក្នុងឱកាសប្រជុំមន្ត្រីសង្ឃដែលត្រូវនិមន្តពីគ្រប់ខេត្តគ្រប់ស្រុកមកប្រជុំក្នុង ១ ឆ្នាំម្តង ៗ នៅថ្ងៃទី ១៥ កើត និងថ្ងៃ១រោច ខែបុស្សរៀងរាល់ឆ្នាំ, ដើម្បីឲ្យបានធ្វើទានចំពោះព្រះសង្ឃគ្រប់ខេត្តគ្រប់ស្រុកផង ទាន់ពេលលោកនិមន្តមកស្រាប់ ដោយមិនបាច់ចាំពិបាកនិមន្តលោក ព្រោះការនិមន្តព្រះសង្ឃច្រើនអង្គគ្រប់ខេត្តគ្រប់ស្រុកឆ្ងាយ ៗ មិនមែនបានដោយងាយទេ ។

## កម្មវិធី

ថ្ងៃទី ១– ថ្ងៃព្រហស្បតិ៍១៤កើតខែបុស្ស (១០មករា ១៩៥២) ជាថ្ងៃចូលបុណ្យ

www.elibraryofcambodia.org

ម៉ោង ៥ កន្លះល្ងាច ព្រះករុណាជាម្ចាស់ជីវិតលើត្បូងទ្រង់ស្តេចយាងមកជាព្រះរាជាធិបតីក្នុងពិធីវេរគុជ-ឡើងគុជ ។ លុះតំណាងពុទ្ធបរិស័ទថ្លែងសុន្ទរកថាចប់ ។ វេរគុជរួចហើយ ព្រះករុណាជាម្ចាស់ជីវិតលើត្បូងទ្រង់ស្តេចយាងចេញពីបារំជាព្រះពន្លា ខាងស្តាំខាងកើតគុជ ស្តេចទៅប្រទានទក្សិណោទកលើព្រះហស្តសម្តេចព្រះមហាសុមេធាធិបតី ដែលគង់ក្នុងបារំខាងទិសឦសានគុជ ។ បន្ទាប់មក, លោកកុម្ម៉ៃស៊ែរនៃសាធារណរដ្ឋបារាំងប្រចាំប្រទេសកម្ពុជា, ឯកឧត្តមប្រធានរដ្ឋសភា, ឯកឧត្តមប្រធានក្រុមប្រឹក្សាព្រះរាជាណាចក្រ, ឯកឧត្តមនាយករដ្ឋមន្ត្រី, ឯកឧត្តមរដ្ឋ-មន្ត្រីគ្រប់ក្រសួង និងអគ្គទូតទាំងឡាយជជុះរលាស់ទក្សិណោទកលើព្រះហស្តសម្តេចព្រះសង្ឃនាយក តាមលំដាប់មុនក្រោយ ៗ លុះព្រះសង្ឃ

សូត្រធម៌អនុមោទនាចប់ហើយ; ព្រះករុណាជាម្ចាស់ជីវិតលើត្បូងស្ដេច យាងជាមួយនឹងលោកកុម្ម៉ុយស៊្រេជាដើម តាមដំណើរខាងមុខ ស្ដេចឡើងទៅលើកុដិធំ ប្រទានកិច្ចបើកទ្វារធំខាងមុខ ជាសុវត្ថិមង្គល ហើយស្ដេចយាងចូលទៅក្នុងកុដិ ជាមួយនឹងលោកកុម្ម៉ុយស៊្រេជាដើម ។ លុះស្រេចកិច្ចទស្សនាការក្នុងកុដិហើយ ព្រះករុណាជាម្ចាស់ជីវិតលើត្បូងស្ដេចយាងចុះតាមដំណើរខាងមុខមកគង់ប្រថាប់ក្នុងបាក់ជាព្រះពន្លាដដែលវិញ ជាមួយនឹងលោកកុម្ម៉ុយស៊្រេជាដើម ។ ពុទ្ធបរិស័ទថ្វាយជូនភេសជ្ជៈតាមគួរដល់វេលា, រួចហើយស្ដេចយាង-អញ្ជើញត្រឡប់ទៅវិញ ។

ម៉ោង៧យប់ ប្រគេនភេសជ្ជៈដល់ព្រះសង្ឃ ។ ម៉ោង៨យប់និមន្ត www.elibraryofcambodia.org ព្រះសង្ឃ៦៩អង្គចំរើនព្រះបរិត្ត រួចពុទ្ធបរិស័ទប្រគេនទេយ្យទាន, បន្ទាប់មក, និមន្តធម្មកថិកសំដែងធម៌តាមសមគួរដល់វេលា ។

ថ្ងៃទី ២– ថ្ងៃសុក្រ ១៥ កើត ខែបុស្ស (១១ មករា ១៩៥២)

ម៉ោង ១១ ប្រគេនចង្ហាន់ដល់ព្រះសង្ឃ ៣០០ អង្គ ។ ម៉ោង៧យប់ប្រគេនភេសជ្ជៈដល់ព្រះសង្ឃ ។ ម៉ោង ៩ កន្លះនិមន្តធម្មកថិកសំដែងធម៌តាមសមគួរដល់វេលា ។

ថ្ងៃទី ៣ – ថ្ងៃសៅរ៍ ១ រោចខែបុស្ស (១២ មករា ១៩៥២)

ម៉ោង ១១ ប្រគេនចង្ហាន់ព្រះសង្ឃ ចែកជាពីរផ្នែកគឺ មួយផ្នែកខាងកុដិធំ ចំនួន ១៥០ អង្គឬច្រើនជាងនេះ, មួយផ្នែកទៀត ឯសាលាកត្តក្នុងវត្ត

ឧណ្ណាលោម ដល់មន្ត្រីសង្ឃក្នុងក្រុងនិងខេត្តក្រៅ មិនមានកំណត់ចំនួន ព្រោះនឹងកំណត់ពីចម្ងាយមិនកើត ។

វេលាយប់ មានការប្រគេនគេសជ្ជៈដូចថ្ងៃមុន ។ បើពួកបរិស័ទត្រូវការធ្វើធម្មសាកច្ឆាឬនិមន្តធម្មកថិកសំដែងធម៌ក៏បាន ។

ថ្ងៃទី ៤ - ថ្ងៃអាទិត្យ ២ កើតខែបុស្ស (១៣ មករា ១៩៥២)

ម៉ោង ១០ ដាក់បាត្រភិក្ខុសាមណេរវត្តឧណ្ណាលោម មិនឲ្យសល់ ១ អង្គ ទោះបីភិក្ខុសាមណេរជាអាគន្តុកៈ ដែលមកសំណាក់ក្នុងវត្តនេះ ក៏ត្រូវនិមន្តឲ្យទទួលបិណ្ឌបាតដែរ, ដោយស្មានទៅរួមទាំងអស់ប្រហែល៧០០អង្គ ។

ពិធីបុណ្យ[illegible]ហើយស្រេចត្រឹមប៉ុណ្ណេះ

www.elibraryofcambodia.org

យើងខ្ញុំបានប្រឹក្សាព្រមព្រៀងគ្នាថា បង្ហាន់ក្នុងឧកាសបុណ្យឆ្លងកុដិទាំង៣ថ្ងៃនេះ សុំឲ្យពុទ្ធបរិស័ទចាត់ចែងធ្វើពីផ្ទះរៀងខ្លួន ត្រូវមានបាយនិងសម្ល ១ មុខ បង្អែម ១ មុខ យកមកអង្គាសបង្ហាន់រួបរួមគ្នា ។ នៅថ្ងៃ ២ កើត បើធ្វើម្ហូបខ្ចប់ជាកញ្ចប់ ៗ ស្រួល ស្រណុកដាក់បាត្រលោក ។

ពុទ្ធបរិស័ទអ្នកចាត់ការបុណ្យឆ្លងកុដិ

※ ※ ※

កម្មវិធី

ដង្ហែព្រះបរមធាតុនៅកាន់ស្ថានីយយន្តហោះ

ពោធិចិនតុងវិលត្រឡប់នៅកាន់ប្រទេសឥណ្ឌាវិញ

ថ្ងៃទី ១១ ខែតុលា ១៩៥២

ម៉ោង៧.០០

– សមាជិករដ្ឋាភិបាល

– សមាជិករដ្ឋសភា

- សមាជិកក្រុមប្រឹក្សាព្រះរាជអាណាចក្រ ព្រមទាំងនាម៉ឺនសព្វមុខមន្ត្រីគ្រប់តំណែង នៅរង់ចាំទទួលគោរពព្រះករុណា ជាម្ចាស់ជីវិតលើត្បូង នៅមុខវត្តព្រះកែវមរកត, ចំណែកសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ សម្តេចឧត្តមប្រឹក្សា[១] ប្រតិភូប្រទេសឥណ្ឌា និងប្រតិភូប្រទេសនានា និមន្តនិងអញ្ជើញចូលទៅក្នុងព្រះវិហារ, ព្រះករុណា ជាម្ចាស់ជីវិតលើត្បូង ស្តេចយាងមកដល់ (សំពត់ពណ៌តាមថ្ងៃ អាវកុតស) ។

ម៉ោង ៧,១៥ ព្រះករុណាជាម្ចាស់ជីវិតលើត្បូងដោយមានព្រះរាជវង្សានុវង្សនិងទីប្រឹក្សាឯកជនអមព្រះអង្គតាមហែទៅផងនោះ ស្តេចយាងមកកាន់វត្តព្រះកែវមរកត ដើម្បីស្តេចយាងចូលក្នុងព្រះវិហារ ។ ទាហានក្រុមរក្សាព្រះអង្គ - ក្រុមខេមរកុមារ - ក្រុមក្មេងបាកាំងព្រះរាជទ្រព្យ រង់ចាំធ្វើគារវកិច្ច ។

ម៉ោង ៧,៣០ ព្រះករុណាជាម្ចាស់ជីវិតលើត្បូង ទ្រង់ស្តេចយាងចូលក្នុងព្រះវិហារព្រះកែវមរកត ហើយសម្តេចព្រះសង្ឃនាយកគណៈមហានិកាយ

១ ព្រះនាម ល្វី-ឯម (វជិរប្បញ្ញោ) គង់វត្តលង្កា ។

ថ្វៃសេចក្ដីគោរពនិមន្ដព្រះបរមធាតុចេញពីក្នុងព្រះវិហារព្រះកែវមរកត ។

ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ទ្រង់លើកព្រះសារីរិកធាតុ (ថ្វាយគ្រឿងសក្ការៈតាមលំដាប់) ។

សម្ដេចព្រះមហាឧបរាជបិតា ទ្រង់លើកព្រះអរហន្ដធាតុ (ថ្វាយគ្រឿងមួយដៃ ក្រៅពីនេះសម្រាប់ព្រះសារីរិកធាតុ) បារគូថ្វាយស័ង្ខ ។

ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង និងសម្ដេចព្រះមហាឧបរាជបិតាទ្រង់ទ្រព្រះបរមធាតុមកតម្កល់លើបុស្បុករថយន្ត ដែលមានអាចារ្យ ៤ នាក់[១] អង្គុយគោរពអមព្រះបរមធាតុដូចមុន (ក្រុមភ្លេងធ្វើការវាទ្យការតាមរបៀប) ។

ម៉ោង៨,០០ រៀបក្បួនហែព្រះបរមធាតុចេញទៅកាន់ស្ថានីយអាកាសយានពោធិ៍ចិនតុង តាមវិថីដូចមានខាងក្រោម :

www.elibraryofcambodia.org

១- វិថីព្រះបរមរាជវាំង, ២. វិថីប្រាង្គស៊ីគាតេ,

៣-មហាវិថីឧកញ៉ាដឹឡាគ្រេ, ៤-វិថីវ៉ៃរណាវិល,

៥-មហាវិថីមិស, ៦- វិថីកំពត ។

ប្រហែលម៉ោង ៨,៤៥ ក្បួនហែព្រះបរមធាតុ បានមកដល់ស្ថានីយអាកាសយានពោធិ៍ចិនតុង ក្រុមភ្លេងដែលចាំធ្វើការវាទ្យចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូងតាមទំនៀម ។

ម៉ោង ៨,៥០ សម្ដេចព្រះសង្ឃនាយកទាំង២ព្រះអង្គ លើកព្រះបរមធាតុពីបុស្បុករថយន្ដទៅតម្កល់លើបវរាសនៈ ក្នុងព្រះពន្លាដែលហើយ

---

១ ម៉ី-ឆាត, ទិន-ក្ដួត, ឈឹម-ស៊ុម, ញ៉ូង-សឿង ។

ក្រុមបារគូថ្វាយស័ង្ខ មានភ្លេងមហោស្រពប្រគំតាមក្រោយស័ង្ខបន្តិច ចប់ហើយសម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ(១) ថ្លែងសេចក្ដីគោរពថ្វាយព្រះពុទ្ធដំណើរ(២) ។ ពុទ្ធបរិស័ទបន្លឺសាធុការ ៣ ដងយ៉ាងខ្លាំងៗព្រមគ្នា រួចហើយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់លើកព្រះសារីរិកធាតុនៃព្រះសម្ពុទ្ធ (ថ្វាយក្លស់ស័ង្ខតាមលំដាប់) សម្ដេចព្រះបរមរាជបិតា ទ្រង់លើកព្រះអរហន្តធាតុនៃព្រះអគ្គសាវ័កទាំងគូ(ថ្វាយក្លស់១ដែរ តែក្លស់នោះសម្រាប់ព្រះសារីរិកធាតុ) មានភ្លេងមហោស្រពទទួលក្រោយស័ង្ខរហូតដល់យន្តហោះចេញ ។ ព្រះករុណានិងសម្ដេចព្រះបរមរាជបិតា ទ្រង់ទ្រព្រះបរមធាតុយកទៅប្រតិស្ឋានលើយន្តហោះ ។

www.elibraryofcambodia.org

វេលាអាកាសយានឡើងផុតពីដីព្រះករុណាជាអម្ចាស់ជីវិតលើត្បូង, សម្ដេចព្រះបរមរាជបិតា, សម្ដេចសង្ឃទាំងបី, ព្រមទាំងឥស្សរជននានា និងពុទ្ធបរិស័ទទាំងឡាយបន្ទន់កាយគោរពព្រះបរមធាតុ ។

ម៉ោង ៩,១៥ លុះអាកាសយានចេញផុតទស្សនវិស័យហើយ ព្រះនរបតីទ្រង់ស្ដេចយាងត្រឡប់មកកាន់ព្រះបរមរាជវាំងវិញ ។

(របៀបភ្លេងធ្វើគារវកិច្ចតាមរបៀប)

---

១ ព្រះនាម ជួន ណាត (ជោតញ្ញាណោ) វត្តឧណ្ណាលោម ។ ២ សេចក្ដីនេះពិរោះក្រៃលែង ហាក់ដូចថ្លែងសន្ទនាផ្ទាល់នឹងព្រះពុទ្ធបរមគ្រូ ដែលទ្រង់ព្រះជន្មនៅឡើយ កន្លងទៅ ១១ ឆ្នាំ ហើយមកដល់ឆ្នាំ ១៩៦៤ នេះ អ្នកស្ដាប់ក្នុងកាលនោះ នៅពិរោះជាប់ តែងនិយាយប្រាប់គ្នា ដល់សព្វថ្ងៃនេះ ។ (ឈឹម-ស៊ុម) ។

## ក្បួនទទួលសម្តេចព្រះសង្ឃនាយក

## នៅវត្តជោតញាណារាម កំពង់ចាម

ថ្ងៃសៅរ៍៥កើត ខែពិសាខ គឺថ្ងៃទី២ឧសភា ពស២៤៩៦ / គស១៩៥៣

១- នៅពេលម៉ោង ៤ រសៀល ចាប់ពីមុខរោងបុណ្យ ពួកព្រះភិក្ខុសង្ឃឈរជាពីរជួរទៅទល់ត្រឹមសាឡុំ តពីនោះទៅពួកស្រី ៗ មួយជួរ ប្រុសៗមួយជួរ ទៅទល់ក្លោងទ្វារវត្តទី៣ ។

២.កូនសិស្សលិសេ ឈរតម្រៀបគ្នាពីក្លោងទ្វារវត្តទៅទល់ក្លោងទ្វារទី២ (ក្រោយបន្ទាយទាហាន) តពីនោះទៅពួកកូនសិស្សសាលាព្រីមែរឈរតម្រៀបគ្នាពីក្លោងទ្វារទី២រហូតទៅក្លោងទ្វារទី១នៅខាងផ្លូវធំ ដែលចូលមកកាន់វត្ត ។

www.elibraryofcambodia.org

ពួកអ្នកទទួលទាំងប៉ុន្មានត្រូវបន្លឺវាចាថា "សួស្តី" ព្រមគ្នា រួចត្រូវដើរដង្ហែតាមក្បួនរថយន្ត ដែលបើកបន្តិចៗចូលទៅក្នុងវត្ត, លុះដល់ក្លោងទ្វារមុខវត្ត, និមន្តសម្តេចចុះពីលើរថយន្ត និមន្តរហូតដល់រោងបុណ្យ ។

មានកុមារី៤នាក់ស្លៀកពាក់ឯកសណ្ឋាន ដើរមុន បាចផ្ការហូតដល់រោងបុណ្យ ។

៣- លុះចូលមកដល់រោង ពួកព្រះភិក្ខុសង្ឃគង់តម្រៀបគ្នាខាងក្រោយបុស្សបុក តពីសម្តេចទៅ,

-ពួកអស់លោកមន្ត្រីតូចធំអង្គុយតម្រៀបគ្នានៅជួរខាងកើត,

–ពួកពុទ្ធបរិស័ទអង្គុយតពីនោះទៅជាលំដាប់,

–ពួកឧបាសកអង្គុយប៉ែកខាងលិច,

–ពួកកូនសិស្សឈរព័ទ្ធជុំវិញរោងបុណ្យ,

–ពួកប៉ូលិសដើរយាមល្បាតពីខាងក្រៅរបងជុំវិញរោង និងទីកុដិដែលសម្តេចគង់ ព្រមទាំងតាមទីផ្លូវធ្លាខាងក្រៅវត្ត ។

–សម្តេចគង់សម្រាកនៅត្រង់មុខកុដិដែលរៀបចំទាំងទទួលចំនួន ១០ នាទី សម្តេចនិមន្តឡើងលើបុស្សបុក ពុទ្ធបរិស័ទថ្លែងសុន្ទរកថាថ្វាយ, សម្តេចថ្លែងទទួលអំណររួចនិមន្តចុះពីលើបុស្សបុកមក, ពួកព្រះភិក្ខុសង្ឃសូត្រជយន្តោថ្វាយរួចសម្តេចនិមន្តឡើងទៅសាក់លើមហាកុដិ ។

www.elibraryofcambodia.org

៤.ដល់ម៉ោង៨យប់ សម្តេចនិមន្តពីមហាកុដិទៅកាន់រោងបុណ្យ លោកអាចារ្យ ចៅ ប្រកាសជូនពរដល់ពុទ្ធបរិស័ទជាម្ចាស់កសាងសេនាសនៈ កុដិធំ សាឡា ដល់ម្ចាស់សាមីដើមការអ្នកកសាងតុតាំងសម្រាប់សាលាបង្រៀន រួចសព្វគ្រប់ម៉ោង៨កន្លះ សម្តេចប្រទានធម៌ទេសនារហូតដល់ម៉ោង ១២ យប់ ។

ព្រឹកឡើងថ្ងៃអាទិត្យ ម៉ោង ៨ ព្រឹកសម្តេចទទួលចង្ហាន់ព្រឹក ស្រស់ស្រួបហើយចេញរថយន្តឆ្ពោះទៅក្រុងភ្នំពេញ ។

****

## ពិធីបញ្ចុះខណ្ឌសីមា(១)

របៀបតាមនៃថ្ងៃដំបូងត្រូវមានពិធីបួងសួងទេវតា ។

ពិធីនេះមានរបៀប :

១– តុមួយមានកម្រាល មានបង្គោលបង់ឆត្រឬក្លុបបាំងពីលើ ។

២– លើតុនោះត្រូវមានឧបហ្វូមួយជាសព្រមទាំងបាយ ហើយនិងបង្អែមមួយជាសព្រមទាំងទឹក ១ ផ្តិលផង ផ្កា១ថូ សំពត់ស១គូ សំពត់ពណ៌ ១គូ ទៀនធូបសម្រាប់អុជ ។

៣– អាចារ្យអ្នកប្រកាសទេវតា គួរតែស្លៀកពាក់ស បើហាចណាស់ ក៏គួរពានាសំពត់សដែរ ។

www.elibraryofcambodia.org

---

១ ពិធីនេះខ្ញុំ (ឈឹម-ស៊ុម) បានតែងឡើងក្នុងគ្រាដែលក្រសួងធម្មការតម្រូវឲ្យខ្ញុំបាត់ការ បុណ្យបញ្ចុះខណ្ឌសីមា (ព្រះរាជទ្រព្យ) វត្តជោតញ្ញាណ នៅក្រុងព្រះសីហនុ ពីឆ្នាំ ១៩៦៤ ។ មុននឹងតែងរៀបរៀងពិធីនេះ ខ្ញុំបានពិគ្រោះជាមួយនឹងលោក អ្នកព្រះពិនិត្យប្រីជា ឯក ញ៉ិល ក្រុមរាជបណ្ឌិត្យ ក្នុងព្រះបរមរាជវាំង ដើម្បីបានតម្រូវពីនោះខ្លះ ហើយខ្ញុំសរសេរថ្វាយសម្តេច ព្រះសង្ឃរាជ (ជ.ណ. ជោតញ្ញាណោ) សូមទ្រង់ពិនិត្យ ។ សម្តេចជាអម្ចាស់ទ្រង់ពិនិត្យហើយ ទ្រង់ព្រះរាជទានបាលីវេរសេនាសនៈ និងផ្តុំឋនិមិត្តសីមា ព្រមទាំងពាក្យប្រែទាំងស្រុង ឲកឲ្យខ្ញុំ បញ្ចូលបន្តទុកជាតម្រូវថ្មីបតទៅនេះ ។ ទោះបីក្នុងឆ្នាំនោះអាក់ខានពុំបានបញ្ចុះខណ្ឌសីមាក្នុង វត្តជោតញ្ញាណ ក្រុងព្រះសីហនុក៏មែនពិត ប៉ុន្តែពិធីនេះ ខ្ញុំពុំបានបោះបង់ចោលទេ ខ្ញុំយកទៅ បាត់ការក្នុងបុណ្យបញ្ចុះខណ្ឌសីមាវត្តជោតញ្ញាណមួយទៀត នៅឃុំបានសៀក ជិតសាលាខេត្ត រតនគិរី ដែលជាវត្តព្រះរាជទ្រព្យដែរ ។ មិនតែប៉ុណ្ណោះ លោកអាចារ្យឯទៀតៗច្រើនរូប បាន ខ្ចីតម្រូវនេះទៅបាត់ការបុណ្យសីមាច្រើនវត្តរួចមកហើយផង ។

តមក វត្តជោតញ្ញាណក្រុងព្រះសីហនុ ដែលត្រូវបញ្ចុះសីមាក្នុងឆ្នាំ ១៩៦៦ ខាងក្រោយវិញ ក៏ប្រើរបៀបនេះដែរ ។

៤ - ពាក្យប្រកាសបួងសួងទេវតា ដូចតទៅនេះ :

ភោន្តោ ទេវសង្ឃា ! បពិត្រពពួកទេពនិករ អមរ ទេវតា ដែលឋិតនៅនាគីរីបព្វតា លើព្រៃព្រឹក្សា លើផែនពសុធា ជ្រោះជ្រងជ្រលង បឹង ស្ទឹង ទន្លេ សមុទ្រក្តី តាំងទេពកោសិយ៍ គឺព្រះឥន្ទ្រាធិរាជ ដែលមានអំណាចត្រួតត្រាលើឋានចាតុម្មហារាជិកាទាំង ៤ និងឋានតាវត្តឹង្សក្តី ស្តេចចាតុម្មហារាជិកាទាំង ៤ ព្រះអង្គ គឺព្រះបាទធតរដ្ឋ ព្រះបាទវិរូបក្ខៈ ព្រះបាទវិរុឡ្ហៈ ព្រះបាទកុវេរវេស្សវ័ណ ជាស្តេចធំក្នុងឋានចាតុម្មហារាជិកា ត្រួតត្រាមនុស្សលោកក្រោមព្រះអធិបតីភាពនៃព្រះឥន្ទ្រក្តី សូមលោកជ្រាប សូមទ្រង់ជ្រាប ។

www.elibraryofcambodia.org

ដ្បិតសម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋនៃប្រទេសកម្ពុជា ដោយសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង មានព្រះរាជហឫទ័យសោមនស្សរីករាយផង ទ្រង់កសាងវត្តមួយលើកំពូលភ្នំនេះ ។

ឯកឧត្តមព្រះរាជប្រតិភូប្រចាំក្រុងព្រះសីហនុនេះ បានរួបរួមជាមួយនឹងក្រសួងសាធារណការ បានស្ថាបនាព្រះវិហារ កុដិ សាលា បង្កើតបានទ្រង់ព្រាយជាវត្តថ្មីមួយនេះ ថ្វាយសម្តេចព្រះប្រមុខរដ្ឋហើយ ។ ថ្ងៃនេះសម្តេចព្រះប្រមុខរដ្ឋជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ទ្រង់នឹងស្តេចមកវេរវត្តថ្មីនេះ ចំពោះព្រះសង្ឃ ទ្រង់នឹងប្រោសព្រះរាជពិធីបញ្ចុះសីមា ចាប់ផ្តើមពីថ្ងៃនេះតទៅ ដល់យប់ជាគម្រប់ ៣ ជាកិច្ចសម្រេចព្រះរាជពិធីបុណ្យ ។

ហេតុដូច្នេះ សូមពពួកទេវតា ដូចដែលយើងខ្ញុំបានរៀបរាប់ព្រះនាម មកហើយ ទទួលជ្រាបនូវដំណឹងនេះ ហើយសូមស្តេច សូមអញ្ជើញ មកទទួលអំណរខួបអរសោទរ ជួយថ្វាយព្រះពរមង្គលសិរីសួស្តី ចំពោះ សម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះប្រមុខ រដ្ឋ សូមទ្រង់មានព្រះពជតេជះ ឈ្នះមារសត្រូវគ្រប់ទិសទី ៗ ដុំថ្មធំ ៗ ជានិមិត្តសីមា ដែលសម្តេចព្រះប្រមុខរដ្ឋទ្រង់បញ្ចុះក្នុងព្រះវិហារ កប់ទុក នឹងថ្កល់ ខ្យល់ប៉ះមិនដល់ មិនកម្រើកយ៉ាងណា, កម្ពុជរដ្ឋឯករាជ្យ អព្យាក្រិត ដែលមានសម្តេចព្រះនរោត្តម សីហនុ ជាព្រះប្រមុខរដ្ឋ សូមឋិត នៅជាស្ថាពរ នឹងថ្កល់ សត្រូវប៉ះពាល់ពុំដល់យ៉ាងនោះ ៗ

www.elibraryofcambodia.org

–សទ្ធតេជោ សូមតេជៈនៃសម្តេចព្រះប្រមុខរដ្ឋបានសម្រេច !

–សិទ្ធីកិច្ចំ សូមកិច្ចការនយោបាយរបស់សម្តេចព្រះប្រមុខរដ្ឋ បាន សម្រេច !

–សិទ្ធីសន្តិភាវេ សូមសន្តិភាពបានសម្រេច !

មួយទៀត បពិត្រពពួកទេវតាទាំងឡាយ ! ខ្ញុំសូមប្រកាសសារជាថ្មី ម្តងទៀតថា : សម្តេចព្រះប្រមុខរដ្ឋ ទ្រង់ពុំមែនបណ្តេញទេវតាណា ដែល ធ្លាប់មានលំនៅ នៅលើកំពូលភ្នំនេះមកហើយនោះទេ ទ្រង់គ្រាន់តែ សព្វព្រះរាជហឫទ័យសាងវត្តពុទ្ធសាសនាលើភ្នំនេះប៉ុណ្ណោះ, ទេវតាណា មានចិត្តសប្បុរស ក៏ទ្រង់នឹងអនុញ្ញាតឲ្យនៅក្នុងទីនេះដដែលដែរ ដើម្បី ជួយថែរក្សាការពារភិក្ខុ-សាមណេរកុំឲ្យមានសេចក្តីអន្តរាយផង ដើម្បី

ជួយសម្រុះសម្រួលទេវតាកំណាចខ្លះប្រសិនបើមាន ឲ្យស្ងួត ឲ្យយល់ត្រូវ ឲ្យជួយថែរក្សាព្រះពុទ្ធសាសនា និងក្រុងព្រះសីហនុទាំងមូល ឲ្យបាន សេចក្ដីសុខ សន្តិភាពតរៀងទៅ ។

មួយទៀត សូមពួកទេវតាជួយថែរក្សាពលរដ្ឋទាំងប្រទេស ទាំងបព្វជិត ទាំងគ្រហស្ថ ដែលបានតាមដង្ហែសម្ដេចព្រះប្រមុខរដ្ឋគ្រប់វិស័យទាំងអស់ ព្រមទាំងបានចូលកសាងវត្តជាតញាណនេះដោយសោមនស្ស ទោះបីអស់លោក-អ្នក សប្បុរសទាំងនោះ បានមកក្នុងពិធីបុណ្យនេះក្ដី ពុំបានមកក្ដី ក៏សូមឲ្យអស់លោក-អ្នក បានសេចក្ដីសុខ-ចម្រើន កើនផលប្រយោជន៍ដូចសេចក្ដីប្រាថ្នា ! លោកណាអ្នកណា មានប្រាថ្នាចង់បានសម្បត្តិទីណា ឋានណា ក៏សូមឲ្យបានសម្រេចដូចសេចក្ដីប្រាថ្នា កុំបីឃ្លៀងឃ្លាត ! ដរាបដល់អវសានជាតិ សូមឲ្យបានសម្រេចព្រះនិព្វានជាទីបំផុតហោង ។

www.elibraryofcambodia.org

អនុមោទនា (បា ៣ ដង) ។ សាធុ ! (បា ៣ ដង)

តពីការបួងសួងទេវតា ដល់ពេលព្រលប់ជួបជុំឧបាសក ឧបាសិកា លោកអាចារ្យត្រូវនាំឧបាសក ឧបាសិកា នមស្ការព្រះរតនត្រ័យ វែងឬខ្លី តាមត្រៃប្រណាម ហើយសុំសីល ៗ សមាទានសីលហើយ លោកអាចារ្យត្រូវវេរវត្តទាំងមូល (ព្រោះវត្តថ្មីស្ទួ) ដូចតទៅនេះ :

## បាលីវេរវត្តថ្មីទាំងមូល

## ព្រមទាំងឧបោសថាគារ និងកុដិថ្មីផង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

(សូត្រតាំងអស់គ្នា ៣ ចប់)

ឱកាស, មយំ ភន្តេ ឥមំ ឧបោសថាគារាទី សសេនាសនំ នវវិហារំ ការាបេត្វា ជោតញ្ញាណោ ឥតិ ឥមស្ស នាមំ កិត្តេត្វា ឥទានិមំ សសេនាសនំ ចាតុទ្ទិសស្ស ភិក្ខុសង្ឃស្ស និយ្យាទេម, សាធុ ភន្តេ ភិក្ខុសង្ឃោ សបរិនិដ្ឋិត – សេនាសនំ ឥមំ វិហារំ

www.elibraryofcambodia.org

បដិគ្គណ្ហាតុ, បដិគ្គហេត្វាន ពុទ្ធានុញ្ញាតា–នុសារេន យថិច្ឆិតំ វលញ្ជេតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

សូមគោរព, បពិត្រព្រះគន្ដែងសង្ឃដ៏ចំរើនហើយ, យើងខ្ញុំទាំងឡាយ បានធ្វើការ ឲ្យសាងនូវវត្តថ្មីនេះ ព្រមទាំងសេនាសនៈ មានឧបោសថាគារ គឺវិហារ ជាពេធឧបោសថជាដើម រួចស្រេចហើយ បានកំណត់នាម នៃវត្តថ្មីនេះ ថាវត្តជោតញ្ញាណ, ឥឡូវនេះ (យើងខ្ញុំ) សូមវេរនូវវត្តនេះ ព្រមទាំងសេនាសនៈ ប្រគេនដល់ព្រះសង្ឃ ដែលនិមន្តមកពីទិសទាំង ៤, បពិត្រព្រះគន្ដែងសង្ឃដ៏ចំរើន, សូមព្រះភិក្ខុសង្ឃ ទទួល

នូវវត្ថុជាតញ្ញាណនេះ ព្រមទាំងសេនាសនៈ ដែលបានស្ថាបនារួចស្រេចហើយ, លុះទទួលរួចហើយ សូមនិមន្តប្រើប្រាស់ តាមលំអាននៃពុទ្ធានុញ្ញាត តាមគួរដល់សេចក្តីត្រូវការចុះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលដ៏វែងឆ្ងាយទៅហោង ។

(ព្រះសង្ឃទទួលថា សាធុ ព្រម ៗ គ្នា ៣ ដង)

ចំពោះវត្ថុជាតញ្ញាណនេះ លុះបានវេរវត្ថុព្រមទាំងឧបោសថាគារនិងកុដិជួរចេះរួចហើយ ត្រូវវេរដុំថ្មទាំង ៩ ដុំ ជានិមិត្តសីមា ប្រគេនព្រះភិក្ខុសង្ឃជាបន្ទាប់គ្នាទៅទៀត (មិនបាច់តាំង នមោ ទៀតឡើយ) ។

www.elibraryofcambodia.org

ឱកាស, មយំ ភន្តេ ឥមេ មហន្តេ បាសាណ-បិណ្ឌេ សីមាយ និមិត្តការណត្ថាយ ភិក្ខុសង្ឃស្ស ទេម, សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមេ បាសាណ-បិណ្ឌេ បដិគ្គណ្ហាតុ, បដិគ្គហេត្វាន ឥមេសំ និមិត្តំ កាត្វា ខណ្ឌសីមំ សម្មន្នតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

«សូមគោរព, បពិត្រព្រះគម្ពង់សង្ឃដ៏ចម្រើនអើយ, យើងខ្ញុំទាំង-ឡាយ សូមវេរ នូវដុំថ្មធំៗ ទាំងឡាយនេះ ប្រគេនដល់ព្រះភិក្ខុសង្ឃ ដើម្បីប្រយោជន៍ ដល់ការធ្វើ នូវនិមិត្តនៃសីមា, បពិត្រព្រះគម្ពង់សង្ឃដ៏

ចម្រើនហើយ, សូមព្រះភិក្ខុសង្ឃ ទទួលនូវដុំថ្មទាំងឡាយនេះ ហើយ
សន្មត នូវខណ្ឌសីមាចុះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្ប
សេចក្តីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលវែងឆ្ងាយទៅហោង" ។

(ព្រះភិក្ខុសង្ឃទទួលថា សាធុ ព្រម ៗ គ្នា ៣ ដង)

រាល់កាលវេរទាំងពួង ត្រូវនមស្ការព្រះរតនត្រ័យរួចសុំសីល ស្រេចហើយសឹមវេរ
រួចហើយលោកអាចារ្យ អារាធនាព្រះបរិត្ត រួចព្រះភិក្ខុសង្ឃចម្រើនព្រះបរិត្តទៅ ។

(បើវត្តចាស់ មានកុដិសាលាចាស់ស្រាប់ ចំត្រឹមតែឧបោសថាគា
(ពេញឧបោសថ) ប៉ុណ្ណោះ បើពុទ្ធបរិស័ទធ្វើបុណ្យឆ្លងឧបោសថាគារនេ
ចង់បញ្ចុះខណ្ឌសីមាជាថ្មីទៀតផង លោកអាចារ្យត្រូវនាំឧបាសក-សិក
www.elibraryofcambodia.org
វេរឧបោសថាគារ (វិហារ) មុន ដូចតទៅនេះ :

ឧកាស, មយំ ភន្តេ ឥមំ ឧបោសថាគារំ គារ
បេត្វា ឥធានិមំ ចាតុទ្ទិសស្ស ភិក្ខុសង្ឃស្ស ឧណោ
ទេម, សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមំ ឧបោសថាគា
បដិគ្គណ្ហាតុ, បដិគ្គហេត្វាន ពុទ្ធានុញ្ញាតានុសារេន យថិ
ច្ឆិតំ វលញ្ជតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ

"សូមគោរព, បពិត្រព្រះគម្លែងសង្ឃដ៏ចម្រើនហើយ, យើងខ្ញុំទាំង
ឡាយ បានបាតការឲ្យស្ថាបនា នូវឧបោសថាគារនេះ រួចស្រេចហើ
ឥឡូវនេះ (យើងខ្ញុំទាំងឡាយ) សូមវេរ នូវឧបោសថាគារនេះ ប្រគ
ដល់ព្រះភិក្ខុសង្ឃ ដែលនិមន្តមក ពីទិសទាំងបួន, បពិត្រព្រះគម្លែងស

ដ៏ចម្រើន, សូមព្រះភិក្ខុសង្ឃ ទទួលនូវឧបោសថាគារនេះ, លុះទទួលរួចហើយ សូមនិមន្តប្រើប្រាស់ តាមសំគាល់នៃពុទ្ធានុញ្ញាត តាមគួរដល់សេចក្តីត្រូវការចុះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់យើងខ្ញុំទាំងឡាយ អស់កាលវែងឆ្ងាយទៅហោង" ។

(ព្រះសង្ឃទទួលថា សាធុ ព្រម ៗ គ្នា ៣ ដង)

លុះវេរឧបោសថាគារ (វិហារ) រួចហើយ ត្រូវវេរដុំថ្មទាំង ៩ ដុំជានិមិត្តសីមា ដូចមានហើយខាងដើមនេះស្រាប់ (បើដុំថ្មគឺថ្មដែរ) ។ លុះណាតែទាយកទាយិកាវេរឧបោសថាគារ ព្រមទាំងដុំថ្ម រួចស្រេចហើយទើបព្រះភិក្ខុសង្ឃអាចធ្វើសង្ឃកម្មតាមច្បាប់សង្ឃក្នុងសីមាវិនិច្ឆ័យបាន ។ ព្រះភិក្ខុសង្ឃមិនត្រូវធ្វើសង្ឃwww.elibraryofcambodia.org[illegible]ដែលទាយកទាយិកាវេរទេ ព្រោះវិហាររបស់គេ ដុំថ្មរបស់គេ គេមិនទាន់ប្រគេន ។

(ឈឹម-ស៊ុម)

x x x

## ពិធីចម្រើនព្រះជន្ម

សម្តេចព្រះមហាសុមេធាធិបតីព្រះសង្ឃរាជគណៈមហានិកាយពីថ្ងៃ ២ ៗ ១០ ៩ ឆ្នាំមមី

ព.ស. ២៥១០ (៦-៣-៦៧)

របៀបចាត់ការ : គណៈកម្មការសង្ឃ និងគណៈកម្មការគ្រហស្ថសម្រាប់វត្តឧណ្ណាលោម បានប្រជុំព្រមព្រៀងគ្នាចាត់របៀបបុណ្យ ចែកមុខការគ្នាជាក្រុម ៗ មានប្រធានមួយរូប ៗ ជាអ្នកទទួលខុសត្រូវ គឺ :

១– ក្រុមរៀបចំសេនាសនៈ:

២– ក្រុមតែងប្រទីបផ្កាលា

៣- ក្រុមតែងតាំងគ្រឿងសក្ការៈ

៤- ក្រុមចាត់ចែងភេសជ្ជៈ

៥- ក្រុមចាត់ចែងភត្តាហារ

៦- ក្រុមហិរញ្ញវត្ថុ (ចំណូលចំណាយ)

៧- ក្រុមចាត់ចែងសង្ឃ

អង្គប្រជុំសម្រេចតម្រូវឲ្យបួងសួងទេវតានាទីមហាចេតិយ ក្រោយព្រះ វិហារ ក្នុងវេលាម៉ោង ១៦ នៃថ្ងៃទី ៦-៣-៦៧ ។ ឯរបៀបបួងសួងទេវតា ដូចបាននិយាយហើយ ក្នុងពិធីបញ្ចុះខណ្ឌសីមាខាងដើមនេះ, ទាំងពាក្យ បួងសួង គឺខ្ញុំយកតាមនោះមកប្រើដែរ ប្លែកតែខាងចុងបន្តិចដូចតទៅនេះ :

www.elibraryofcambodia.org

គោណ្ដា ទេវសង្ឃា . . . . . . . . . . .

. . . . . . . . . . . . . . . . . . .

ដ្បិតសម្ដេចព្រះមហាសុមេធាធិបតី (ជ.ណ.ជោតញ្ញាណោ) ព្រះ សង្ឃរាជគណៈមហានិកាយជាអម្ចាស់ មានព្រះជន្មាយុគ្រប់ ៨៣ ឆ្នាំ ក្នុង ថ្ងៃនេះ ថែមទាំងមានព្រះរោគក្នុងព្រះកាយទៀតផង ។ យើងខ្ញុំទាំងឡាយ ទាំងបព្វជិត ទាំងគ្រហស្ថ មានសេចក្ដីរន្ធត់ក្នុងហឫទ័យក្រៃពេក ទើប ប្រជុំព្រមព្រៀងគ្នាថា នឹងធ្វើបុណ្យចម្រើនព្រះជន្មព្រះអង្គ ។ ឥឡូវនេះ ម៉ោង ១៦ នៃថ្ងៃនេះ ជាពេលចូលបុណ្យ, យើងសូមស្ដេច សូមអញ្ជើញ ទេវតាទាំងឡាយដូចរាប់រៀបមកហើយនេះមកជាកេរ្តិ៍កិត្តិយសរបស់យើង, សូមទេវតាទាំងឡាយ អនុមោទនានូវការកុសលរបស់យើង ហើយសូម

ជួយកំចាត់បង់នូវព្រះរោគាពាធ ឲ្យឃ្លាតចេញអំពីព្រះកាយនៃសម្ដេចព្រះសង្ឃរាជជាអម្ចាស់ ឲ្យបានជ្រះស្រឡះក្នុងពេលនេះជាកម្រិត ដោយទេវរិទ្ធិដ៏មហស្ចារ្យ ដែលយើងគ្រប់គ្នាធ្លាប់មានជំនឿថា ទេព្ដាមានមែន !

មួយទៀត សូមទេព្ដាទាំងនោះ ដែលយើងរាប់អាន កុំបីមានការធ្វេសប្រហែសឡើយ ក្នុងកិច្ចជួយអភិបាលរក្សា ការពារ ពារាំង ឃាត់ឃាំង នូវសត្រូវ និងសេចក្ដីអន្ដរាយគ្រប់ប្រការ កុំឲ្យមានមកប៉ះពាល់ដល់ព្រះរូបព្រះកាយ និងព្រះកិត្តិនាម ព្រះកិត្តិយស របស់សម្ដេចព្រះសង្ឃរាជជាអម្ចាស់បានឡើយ ។

សូមទេព្ដាកុំព្រងើយកន្ដើយ សូមជួយទ្រទ្រង់អង្គសម្ដេចព្រះសង្ឃរាជជាអម្ចាស់ ឲ្យមានព្រះជន្មយឺនយូរ [illegible] ដើម្បីជាបង្គោលនៃព្រះពុទ្ធសាសនា និងជាម្លប់ដ៏ត្រជាក់ ជាទីជ្រកកោននៃសិស្សានុសិស្ស និងពុទ្ធបរិស័ទតរៀងទៅ ។

www.elibraryofcambodia.org

សូមសម្ដេចព្រះសង្ឃរាជជាអម្ចាស់មានព្រះជន្មច្រើន ជាងរយវស្សា!

សាធុ !

សូមសម្ដេចព្រះសង្ឃរាជជាអម្ចាស់មានព្រះជន្មច្រើន ជាងរយវស្សា!

សាធុ !

សូមសម្ដេចព្រះសង្ឃរាជជាអម្ចាស់មានព្រះជន្មច្រើន ជាងរយវស្សា!

សាធុ ! (ឈឹម-ស៊ុម)

x x x

# ការប្រកាសបួងសួងទេព្តា(១)

## ក្នុងពិធីច្រោះព្រំកីឡាឋានអូឡាំពិច

## ក្រុងភ្នំពេញ

នៅថ្ងៃទី ២ វិច្ឆិកា ឆ្នាំ ១៩៦៤

ភោន្តោ ទេវសង្ឃា ! បពិត្រពពួកទេពនិករ អមរទេវតា ដែលឋិតនៅក្នុងទីនានា ភុម្មទេវា ទាំងទេព្តាដែលរក្សាគពាក់ផែនដែន ពសុធា អាកាសដ្ឋានទីក្រុងព្រះនគរបវររាជបុរី រុក្ខទេវា ទាំងទេព្តារក្សា ព្រឹក្សព្រៃគិរីបព្វតា ជលទេវា ទាំងទេព្តារក្សាជ្រោះជ្រងជ្រលងស្ទឹងព្រែក ស្ទឹងបឹង www.elibraryofcambodia.org ទេវា ទាំងទេព្តារក្សាផ្ទៃអាកាស មានពិមានអណ្តែតលើនភាល័យ ទាំងទេពកោសីយ៍ គឺព្រះឥន្ទ្រាធិរាជ ដែលមានអំណាចត្រួតត្រាលើឋានចាតុម្មហារាជិការទាំងបួន និងសហភាព

១- សេចក្តីបួងសួងនេះ ខ្ញុំ (ឈឹម-ស៊ុម) បានតែង ហើយថ្លែងប្រកាសខ្លួនឯង ក្នុងគ្រា ដែលព្រះរាជរដ្ឋាភិបាលបាត់ឲ្យធ្វើពិធីនេះ ក្រោមអធិបតីភាព នៃឯកឧត្តម ឧត្តមសេនីយ៍ឯក លន់-នល់ (នាយករដ្ឋមន្ត្រី) និងឯកឧត្តម ទេព ផន ព្រះរាជប្រតិភូប្រចាំក្រុងភ្នំពេញ ក្នុងចំណោម នៃវរជនគ្រប់ក្រសួង និងមហាជនទាំងទាហាន ទាំងស៊ីវិល ទាំងកីឡាករគ្រប់ប្រភេទ ក្នុងរាជធានីនិងខេត្តក្រៅទាំងអស់ ។ ក្រោយបញ្ចប់ការបួងសួងហើយ លោកវរសេនីយ៍ ៨ នាក់កាន់ផ្តិល ទឹកពុទ្ធមន្ត ៩ ផ្តិល មានព្រះសង្ឃជាចៅអធិការ ៨ វត្តទៅកាន់កីឡាមណ្ឌលទាំងអស់ ព្រោះ ព្រំផ្ទុះរណាល់ ដើម្បីឲ្យកីឡាឋាននេះមានប្រសិទ្ធិភាពតរៀងទៅ ។ តមកទើបធ្វើពិធីសម្ពោធ ក្រោមព្រះបរមរាជាធិបតីភាពនៃសម្តេចព្រះប្រមុខរដ្ឋ ។

តាវត្តិង្ស ទាំងស្តេចចាតុម្មហារាជិកាទាំងបួនព្រះអង្គ គឺ ព្រះបាទធតរដ្ឋ ព្រះបាទវិរូបក្ខៈ ព្រះបាទវិរុឡ្ហៈ ព្រះបាទកុវេរវេស្សវ័ណ ជាស្តេចធំក្នុងឋានចាតុម្មហារាជិកា គ្រួតត្រាមនុស្សលោកក្រោមព្រះរាជាធិបតីភាពនៃព្រះឥន្ទ្រាធិរាជ កាមាវចរទេវា ទាំងទេព្តាដែលឋិតនៅក្នុងឋានយាមា តុសិត បរនិម្មិត និងបរនិម្មិតវសវត្តី ដែលរាប់រួមគ្នាជាឆក្កាមាវចរសួគ៌ ទាំងទេព្តាក្នុងទិសទស ទាំងសោឡសមហាព្រហ្ម សូមព្រះអង្គ សូមលោកស្តាប់ខ្ញុំ ។

ដ្បិតសម្តេចព្រះឧបយុវរាជ នរោត្តម·សីហនុ ព្រះប្រមុខរដ្ឋនៃប្រទេសកម្ពុជា ជាបិតា សន្តិភាពបិតាកីឡាជាតិ ជាទីគោរព ជាទីស្រឡាញ់ ស្មើដោយជីវិត នៃប្រជាពលរដ្ឋខ្មែរទាំងសកល ទ្រង់តែងតែផ្តល់នូវវឌ្ឍនភាពគ្រប់វិស័យ ដល់ប្រជាពលរដ្ឋខ្មែរ ដោយព្រះរាជហឫទ័យមេត្តាករុណាជានិច្ចនោះ ទ្រង់សព្វព្រះរាជហឫទ័យឲ្យស្ថាបនានូវកីឡាឋានអូឡាំពិចដើម្បីជាប្រយោជន៍ដល់យុវជន យុវតី ជាកូនចៅរបស់ព្រះអង្គ, ទ្រង់ត្រាស់ព្រះរាជបញ្ញា ឲ្យព្រះរាជរដ្ឋាភិបាលចាត់ការស្ថាបនាកីឡាឋានអូឡាំពិចនេះ ។ គណៈកម្មការជាតិ ទទួលបន្ទុកខាងការរៀបចំកីឡា ឧបទ្វីបអាស៊ីអាគ្នេយ៍ បានចាត់ការស្ថាបនាកីឡាឋាននេះ លេចរូបរាងឡើងប្រកបដោយទស្សនីយភាព ជាទីគាប់ភ្នែកនៃមហាជននានា ល្មមប្រើការបានហើយ ។ ឥឡូវនេះ សម្តេចព្រះប្រមុខរដ្ឋជាអម្ចាស់ជីវិតលើត្បូង ទ្រង់សព្វព្រះរាជហឫទ័យឲ្យធ្វើពិធីប្រោះព្រំ តាមបវេណីនៃសាសនា ក្នុង

www.elibraryofcambodia.org

ថ្ងៃនេះ ៗ គណៈកម្មការចម្រុះ ដែលមានសាលាក្រុងភ្នំពេញ, អគ្គស្នងការដ្ឋាននៃកីឡា និងក្រសួងធម្មការជាដើម បានចាត់ធ្វើពិធីនេះ ៗ ឥឡូវនេះ សមាជិកទាំងឡាយនៃពិធីនេះមានឯកឧត្ដម ឧត្ដមសេនីយ៍ឯក និងឯកឧត្ដមព្រះរាជប្រតិភូប្រចាំក្រុងភ្នំពេញជាប្រធាន បានមូលមកជួបជុំគ្នាអស់ហើយ ៗ

បពិត្រទេវតាទាំងឡាយ!

សូមព្រះអង្គ សូមលោកទាំងឡាយ ដែលខ្ញុំប្រកាសចេញព្រះនាមរួចហើយ ស្ដេចយាងមក អញ្ជើញមក ជាភ្ញៀវដ៏ប្រសើររបស់ប្រទេសកម្ពុជា, សូមព្រះអង្គ សូមលោកទាំងឡាយ ទទួលជ្រាបនូវពលិការដែលយើងខ្ញុំរៀបចំនេះ ទាំងជាបដិសណ្ឋារកិច្ច ចំពោះព្រះអង្គ ចំពោះលោកទាំងឡាយ, សូមទេវតាទាំងអស់នោះ ទទួលអនុមោទនា ហើយប្រសិទ្ធីកីឡាឋាន អូឡាំពិចនេះ ឲ្យជាទីមានជោគជ័យ, សូមប្រសិទ្ធីអ្នកកីឡាទាំងប្រុសទាំងស្ត្រី ឲ្យមានអត្តពល តទល់នឹងកីឡាគ្រប់ប្រភេទ កុំឲ្យមានឧបសគ្គ គ្រោះថ្នាក់អ្វីឡើយ ៗ ( ទះដៃ ! )

អ្នកកីឡាណា បានហ្វឹកហាត់រួចហើយ នឹងប្រកួតជាមួយនឹងអ្នកកីឡាបរទេសក្នុងទីនេះ, សូមទេវតាដ៏អង់អាច ជួយទ្រទ្រង់តម្រង់ស្មារតីឲ្យអ្នកកីឡាទាំងប្រុសទាំងស្ត្រីនោះ មានការវាងវៃ មានក្ដីអង់អាច មានឫទ្ធិអំណាចអាចយកជ័យជំនះបានគ្រប់កាល គ្រប់វេលា ៗ (ទះដៃ!)

បពិត្រទេវតាទាំងឡាយ! បើពួកកីឡាករនៃប្រទេសកម្ពុជាធ្វើដំណើរ

ទៅប្រកួតកីឡានៅប្រទេសណា ៗ តាមផ្លូវអាកាសវេហាស៍ តាមផ្លូវសមុទ្រជលធារ ឬតាមមាគ៌ាផ្លូវគោក សូមលោកជួយបីបាច់ថែរក្សា ឲ្យអ្នកកីឡាខ្មែរបានសេចក្ដីសុខសាន្តរហូតទៅ រហូតមក, សូមឲ្យអ្នកកីឡាខ្មែរ មានជ័យជំនះឈ្នះគូប្រយុទ្ធ បានកេរ្តិ៍ពិរោះឈ្មោះល្អបំផុត គ្រប់ទីឋាន គ្រប់កាលគ្រប់វេលា ។ (ទះដៃ!) ។

បពិត្រទេព្តាទាំងឡាយ !

សូមលោកជួយទ្រទ្រង់ជានិច្ចនូវអង្គការកីឡានៃប្រទេសកម្ពុជានេះ ៗ ផងចុះ យើងខ្ញុំសូមអារាធនាទេព្តាមានឫទ្ធិអំណាចអស្ចារ្យ មកគង់ជាប្រក្រតី ដើម្បីថែរក្សាការពារនូវអង្គការនេះ ឲ្យមានជោគជ័យជានិច្ច ៗ (ទះដៃ!)

សូមប្រទេសកម្ពុជា [illegible] ដោយសារអង្គការកីឡា ៗ (ទះដៃ!) ៗ

សូមប្រទេសកម្ពុជា ល្បីកិត្តិនាមខ្ទរខ្ទារដោយសារអង្គការកីឡា ៗ (ទះដៃ!)

- សូមគូប្រឆាំងបាក់បបខ្ទបខ្ទាប ៗ (ថាតាម!) ៗ
- បរាជ័យគូប្រឆាំងនឹងប្រទេសកម្ពុជា ៗ (ថាតាម!) ៗ
- បរាជ័យ បច្ចាមិត្រគ្រប់ទីនានា ៗ (ថាតាម!) ៗ
- ជយោព្រះរាជបល្ល័ង្ក ៗ (ថាតាម!) ៗ
- ជយោសម្ដេចព្រះប្រមុខរដ្ឋ ៗ (ថាតាម!) ៗ
- ជយោអ្នកកីឡាខ្មែរ ៗ (ថាតាម!) ៗ

(បញ្ចប់ពិធីបួងសួង)

****

www.elibraryofcambodia.org

## វគ្គទី ៨

### វិធីក្រាលកឋិន, អបលោកនកឋិន, បវារណា, វិធីបវារណារូបិយ, វិធីធ្វើកប្បិយៈ, វិធីប្រកាសមាឃបូជា វិសាខបូជា, បណាមគាថា, នមក្ការគាថា ។

### វិធីក្រាលកឋិន

បពិត្រព្រះគណសង្ឃដ៏ចម្រើនអើយ, អង្គកឋិនទាននេះ ជាកឋិនទានរបស់(១) ឈ្មោះ.... នៅភូមិ. . សង្កាត់... មានសទ្ធាចំណាយទ្រព្យរណ្ដាប់ជាត្រៃចីវរ និងគ្រឿងបរិក្ខារទាំងពួង ហើយដង្ហែចូលមកវេរប្រគេនចំពោះព្រះភិក្ខុសង្ឃ ដែលគង់ចាំវស្សាអស់ត្រៃមាស ក្នុងអារាមវត្ត...នេះ ។

អង្គកឋិនទាននេះ [illegible] ដូចជាសំពត់កោសេយ្យពស្ត្រទិព្វ ដែលអណ្ដែតត្រសែតតាមនភាល័យប្រទេស មកធ្លាក់ចុះក្នុងកណ្ដាលជំនុំសង្ឃ មិនបានសំដៅផ្ដោះត្រង់ភិក្ខុរូបណាមួយក៏ទេ ។

មានពុទ្ធានុញ្ញាតក្នុងវិន័យ កឋិនក្ខន្ធកៈថា: ត្រូវជំនុំសង្ឃព្រមព្រៀងគ្នាបង្អែរអង្គកឋិនទានមានសភាពយ៉ាងនេះ ដល់ភិក្ខុមួយអង្គដែលចេះសហជាតធម ១៥ យ៉ាង គឺអានិសង្ស ៥ មាតិកា ៨ បលិពោធ ២ ព្រមទាំងកឋិនត្ថារកិច្ចផង ហើយអាចញ៉ាំងសង្ឃឲ្យត្រេកអរ ដោយកឋិនត្ថារកិច្ចបានផង ឲ្យជាអ្នកទទួលក្រាលគ្រង, យ៉ាងនេះ, សង្ឃអ្នកអនុមោទនាក៏ឈ្មោះថាបានទទួលក្រាលគ្រងទាំងអស់គ្នា ។

---

(១) បើកឋិនទានព្រះរាជទ្រព្យត្រូវចុះថា នៃព្រះករុណាជាអម្ចាស់ជីវិត ព្រះបាទសម្ដេច... ។

ដោយហេតុនេះ បើបណ្តាភិក្ខុសង្ឃក្នុងទីប្រជុំនេះ មានភិក្ខុអង្គណាចេះសហជាតធម៌ ១៩ យ៉ាងនិងកឋិនត្ថារកិច្ច ហើយត្រូវការនឹងទទួលក្រាលគ្រង នោះចូរធ្វើយមកចុះ, កុំគប្បីគោតញញើតឡើយ. បើជំនុំសង្ឃយល់ឃើញថាសមគួរហើយ នឹងបានឲ្យវិន័យធរ សូត្រញត្តិទុតិយកម្មវាចាប្រគល់អង្គកឋិនទាននេះ ឲ្យភិក្ខុអង្គនោះក្រាលគ្រង ធ្វើសព្វាជូនកុសលដល់អ្នកដើមការ (២) ។

## អបលោកន៍កឋិនទាន

បពិត្រអើយ រយើងខ្ញុំទាំងអស់គ្នា សឹងមានត្រៃចីវរបរិបូណ៌សមគួរដល់ការប្រើប្រាស់ហើយ, ឯអង្គកឋិនទាននេះ ឃើញថាសមគួរឲ្យវិន័យធរ សូត្រញត្តិទុតិយកម្មវាចាប្រគេនដល់ព្រះ(១) ... ជាចៅអធិការវត្ត... ឲ្យក្រាលគ្រងជូនកុសលដល់អ្នកដើមការ(២) ដ្បិតលោកចេះសហជាតធម៌ ១៩ យ៉ាង ហើយអាចញុំាងសង្ឃឲ្យត្រេកអរដោយកឋិនត្ថារកិច្ចបានផង លោកមានសភាពគួរដល់ការក្រាលគ្រងអង្គព្រះកឋិនទាននេះផង ។ បើជំនុំសង្ឃយល់ព្រមតាមវាចាដែលខ្ញុំព្រះករុណាប្រកាសនេះ, សូមបញ្ចេញសទ្ទសញ្ញាថាសាធុគ្រប់អង្គ ឲ្យព្រម ៗ គ្នាមកហាង ។

※ ※ ※

១ បើអង្គណាក្រាលគ្រង, ឲ្យចុះនាមអង្គនោះ ។ ២ បើជាកឋិនទានព្រះរាជទ្រព្យ ឲ្យចុះថាថ្វាយព្រះរាជកុសលព្រះករុណាជាម្ចាស់ជីវិត ។

www.elibraryofcambodia.org

ថែបវេរហិរញ្ញវត្ថុ គឺប្រាក់បុណ្យផ្កា ដែលអ្នកមានសទ្ធា នាំមកអំពីស្រុកឯទៀតៗ ក្រៅពីស្រុកចំណុះវត្តនោះ

បពិត្រព្រះតម្តែងសង្ឃដ៏ចំរើនអើយ(១) យើងខ្ញុំទាំងឡាយ បានដឹងច្បាស់ថា ក្នុងទីតាក់សវត្ត ... នេះ កំពុងមានការកសាងវិហារ ជាកេងឧបោសថថ្មី សម្រាប់ភិក្ខុសង្ឃក្នុងពុទ្ធសាសនា សម្រេចសង្ឃកម្មគ្រប់យ៉ាង, ការកសាងនេះ នៅមិនទាន់ហើយស្រេច, យើងខ្ញុំមានចិត្តជ្រះថ្លា បានព្រមព្រៀងគ្នា បរិច្ចាគហិរញ្ញវត្ថុ គឺប្រាក់ តាមសមគួរដល់កម្លាំងទ្រព្យ និងកម្លាំងសទ្ធា រៀបរៀងទាំងអស់ បានចំនួន ..៛.. ហើយនាំមកក្នុងទីនេះ ជាសង្ឃបូជា តែសន្មត់ហៅថា បុណ្យផ្កា ចំពោះសេនាសនប្បច្ច័យ ដោយ

www.elibraryofcambodia.org

ពិត ពីព្រោះយើងខ្ញុំ វេរហិរញ្ញវត្ថុនេះ ចំពោះការកសាងវិហារថ្មីនេះ ការត្រង់ណា ដែលនៅមិនទាន់ហើយ, យើងខ្ញុំចំពោះ បំពេញការនោះ ដែលមានសេចក្តី ក្នុងវិន័យបិដកថា ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់បញ្ញត្តហាម មិនឲ្យភិក្ខុសាមណេរ ទទួលប្រាក់មាសផ្ទាល់ ទ្រង់អនុញ្ញាតថា ឲ្យគ្រាន់តែទទួលដឹង ហើយឲ្យត្រេកអរ ចំពោះចតុប្បច្ច័យ ដែលកើតអំ, ពីប្រាក់មាស ដែលទាយកទាយិកា អ្នកមានសទ្ធា ចំពោះបច្ច័យទាំង ៤ ឬចំពោះបច្ច័យណាមួយ ហើយបានប្រគល់ប្រាក់មាសនោះ ដល់កប្បិយការកៈ ឲ្យទុកដាក់ សម្រេចកិច្ចប្រគេន ។ ព្រោះហេតុនោះ ឥឡូវនេះ យើងខ្ញុំទាំងឡាយ សូមប្រគល់ហិរញ្ញវត្ថុ ចំនួន...៛.. នេះ ដល់

---

១ អានថា ដំចំរើនណើយ ។

អារាមិកជន គឺអាចារ្យវត្ត ឈ្មោះ.....នេះ ឲ្យជាអ្នកទទួលសម្រេចកិច្ច ក្នុងការកសាងវិហារថ្មីនេះ ឲ្យត្រាតែអស់ ហិរញ្ញវត្ថុ ចំនួន ....រ...នេះ តាមសមគួរដល់កិច្ចការ ដែលត្រូវប្រកប; សូមព្រះភិក្ខុសង្ឃជ្រាប ដោយប្រការដូច្នេះ ហើយសូមព្រះភិក្ខុសង្ឃ ជួយដាស់តឿន ក្រើនរំលឹក ឲ្យខាងតែបានសម្រេច ការកសាងនេះ ដោយប្រពៃ ដើម្បីឲ្យបានសម្រេច ផលានិសង្ស កើតសេចក្ដីចំរើន កើតផលប្រយោជន៍ កើតសេចក្ដីសុខ ដល់យើងខ្ញុំទាំងឡាយ ឲ្យបានអស់កាលដ៏យូរអង្វែង វែងឆ្ងាយតទៅ ។ ម្យ៉ាងទៀត ទីសេនាសនប្បច្ច័យនេះ ចូរជាឧបនិស្ស័យ ឲ្យយើងខ្ញុំទាំងអស់គ្នា បានដល់នូវធម៌ ជាគ្រឿងរំលត់បង់នូវភ្លើងទុក្ខ ភ្លើងកិលេស គឺបាប សូមឲ្យយើងខ្ញុំទាំងអស់គ្នា បានដល់នូវព្រះនិព្វាន នៅឯអនាគតកាល ខាងមុខនោះហោង ។

(ព្រះភិក្ខុសង្ឃត្រូវទទួលដោយតុណ្ហីភាពឬត្រូវទទួលថា សាធុឲ្យព្រមគ្នាក៏ល្អ រួចហើយព្រះថេរៈគួរអនុមោទនា ឬបង្គាប់ឲ្យភិក្ខុអង្គណាមួយដែលចៀវឆ្លាសក្នុងវិធីអនុមោទនា ឲ្យសំដែងអនុមោទនា ជំនួសព្រះភិក្ខុសង្ឃក្នុងទីប្រជុំនោះក៏បាន ឬសូត្រធម៌អនុមោទនាគ្រប់អង្គ តាមបែបអនុមោទនាវិធីក៏ល្អ ដើម្បីនឹងញ៉ាំងសេចក្ដីជ្រះថ្លារបស់ទាយកទាយិកាឲ្យលូតលាស់ចំរើនច្រើនឡើងទៀត) ។

## សេចក្ដីបន្ថែម

សូមរំលឹកដល់អស់លោកទៅអំពីការខ្វះ ផ្សិតគ្រឿងរូបិយ គឺប្រាក់សុទ្ធ ឬ

www.elibraryofcambodia.org

វត្ថុដែលគេហាយជូនសប្រាក់ ដែលពួកពុទ្ធបរិស័ទប្រគេនចំពោះខ្លួនយើង ផ្ទាល់ខ្លួនក្ដី ចំពោះសង្ឃក្ដី មានវិន័យហាមដាច់ខាត មិនឲ្យភិក្ខុសាមណេរ ទទួលកាន់ផ្ទាល់ដៃខ្លួន, រូបិយនេះ ត្រូវមានអាចារ្យវត្ត ឬក្មេងជាសិស្សលោកដែលជាវេយ្យាវច្ចករកាន់កាប់, ហេតុនេះត្រូវបង្ហាត់វេយ្យាវច្ចករនេះឲ្យស្ទាត់ក្នុងវិធីបវារណា តាំងឲ្យចេះទុកដាក់ថែទាំរូបិយនេះ កុំឲ្យវិនាស ។ កាលថ្ងៃសីលគួរលោកគ្រូចៅអធិការពន្យល់បង្ហាត់អាចារ្យវត្ត ឧបាសក ឧបាសិកា និងក្មេងវត្ត ឲ្យបានចេះទាំងអស់គ្នា ទើបស្រួលដល់យើងជាអ្នកបួស ព្រោះចេះការពារមិនឲ្យត្រូវអាបត្តិ ។

ត្រូវពន្យល់តាំងពីរបៀបប្រគេនបង្អាន់ ឲ្យត្រូវហត្ថបាស គឺ ១ ហត្ថ ១ ចំអាមឃ្លាតពីខ្លួនអ្នកប្រគេនទៅទលនឹងព្រះសង្ឃ ដែលត្រូវទទួល ។ ទាំងវត្ថុសម្រាប់ឆាន់ឯទៀតដែលជាអកប្បិយៈ ដូចជាត្រកួនឆៅ សណ្ដែកបណ្ដុះឆៅ ម្ទេស អំពៅ ផ្លែឈើដូចជាត្របែកជាដើម ។ល។ ត្រូវធ្វើកប្បិយៈឲ្យគួរជាមុនទៅទើបចំពោះមុខលោកអ្នកទទួល គឺ ត្រូវយកវត្ថុឆៅនោះទៅស្ងោរឬស្រុសឲ្យឆ្អិនក៏បាន កាត់ឬចិតដោយកាំបិតជាដើមក៏បាន ។ ចំណែកខាងភាជនៈក៏ត្រូវពន្យល់កុំឲ្យព្រះសង្ឃឆាន់ភាជនៈបូលគ្នា, ត្រូវឲ្យអ្នកធ្វើទានបានយល់ក្នុងការរៀបចំបង្អាន់ប្រគេនព្រះសង្ឃផង ។

ចូរមើលវិធីបវារណារូបិយៈ និងវិធីកប្បិយៈនូវវត្ថុដែលជាពីជគាមនិងភូតគាម ក្នុងសៀវភៅនេះមានស្រាប់ ។

x x x

www.elibraryofcambodia.org

## វិធីបវារណារូបិយ(១)

ខ្ញុំព្រះករុណា សូមបវារណាលោកគ្រូម្ចាស់ ដោយបច្ច័យទាំងឡាយបួន គឺ ចីវរប្បច្ច័យ ១ បិណ្ឌបាតប្បច្ច័យ ១ សេនាសនប្បច្ច័យ ១ គិលានភេសជ្ជប្បច្ច័យ ១, បើលោកគ្រូម្ចាស់ត្រូវការបច្ច័យណាមួយ, សូមសួរទារយកពីឈ្មោះ(២) ....ជាវេយ្យាវច្ចករ ឲ្យស៊ើនឹងតម្លៃចំនួន... រៀលជារបស់ឈ្មោះ ....(៣) ។

## វិធីធ្វើកប្បិយៈនូវវត្ថុដែលជាពីជគាម និងភូតគាម ត្រូវធ្វើចំពោះមុខលោកអ្នកទទួលប្រគេនថា

"ឥទំ ភន្តេ កប្បិយំ ភណ្ឌំ" (ប្រែថា) វត្ថុនេះគួរដល់លោកម្ចាស់ ។ www.elibraryofcambodia.org ថាដូច្នេះបណ្ដើរធ្វើបណ្ដើរ ធ្វើដោយចុងកាំបិត ឬដោយក្រចកក៏បាន; សូម្បីសណ្ដែកបណ្ដុះមួយល្អី គ្រាន់តែចុចនឹងចុងក្រចកជាការស្រេច, អំពៅមួយបាច់ គ្រាន់តែយកចុងដែកស្រួចចុច ១ ដើម ជាការស្រេចគួរដល់លោកអ្នកទទួលឆាន់បាន ។

---

១ រូបិយ(ប្រាក់មាស) តាមច្បាប់វិន័យភិក្ខុសង្ឃមិនត្រូវកាន់ប្រាក់មាសខ្លួនឯងទេ, ខុសច្បាប់ត្រូវអាបត្តិ ។ ហេតុនេះអាចារ្យវត្តក្ដី ក្មេងវត្តក្ដី សិស្សបំរើលោកក្ដី ពោងឲ្យចេះវិធីបវារណាឲ្យត្រូវតាមច្បាប់, ទើបលោកសង្ឃរួចពីអាបត្តិ ហើយទានរបស់អ្នកស្រុកក៏មានផលច្រើនផង ។ ២ បើប្រគល់ប្រាក់នោះឲ្យទៅឈ្មោះណា ឬឲ្យទៅក្មេងជាសិស្សលោក ត្រូវថាចេញឈ្មោះនោះ ឬបើខ្លួនអ្នកកាន់ប្រាក់នោះស្រាប់ត្រូវថា: សូមឲ្យទារយកពីខ្ញុំព្រះករុណា ។ ៣ ចេញឈ្មោះម្ចាស់ប្រាក់ ឬបើមិនចាំឈ្មោះម្ចាស់ប្រាក់ ត្រូវថាជារបស់អ្នកស្រុកក៏បាន ។

x x x

## វិធីប្រកាស មាឃបូជា និងវិសាខបូជា(១)

មុននឹងប្រកាស, បើទីតាំងពិធីបុណ្យនេះ មានឱកាសល្មមលោកអាចារ្យនាំឧបាសក-សិកា ដើរប្រទក្សិណបាន, ក៏គួរប្រទក្សិណ ៣ ជុំសិន ហើយសុំសីល ៨ រួចសឹមអានមួយសង្កាត់ម្ដងៗ សម្រួលតាមឃ្លាល្បះ ឲ្យពុទ្ធមាមកជនទាំងអស់ថាតាម ឲ្យព្រម ៗ គ្នា ដូចតទៅនេះ ។

### វិធីប្រកាសមាឃបូជា(២)

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការ ចំពោះព្រះភគវន្តមុនី អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។

សម្មាសម្ពុទ្ធោ វត សោ ភគវា យោ សត្តទុក្ខស្ស បហានាយ ធម្មំ ទេសេសិ តំ សម្មាសម្ពុទ្ធំ អាទរេន នមស្សាម ។ ព្រះភគវន្តមុនីអង្គណា ទ្រង់ត្រាស់សម្ដែងនូវធម៌ ដើម្បីកំចាត់បង់ នូវសេចក្ដីទុក្ខទាំងពួង, ព្រះភគវន្តមុនីអង្គនោះ ជាព្រះសម្មាសម្ពុទ្ធពិតមែន, យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំ នូវព្រះសម្មា-សម្ពុទ្ធអង្គនោះ ដោយគោរព ។

(ក្រាបថ្វាយបង្គំម្ដង)

និយ្យានិកោ វត សោ ធម្មោ យោ សត្តទុក្ខស្ស បហានាយ ស្វាក្ខាតោ តេន ភគវតា តំ ធម្មំ អាទរេន

---

១ ចម្លងតាមសេចក្ដីណែនាំរបស់សម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ (ជ-ណ) ។ ២ សូមមើលសៀវភៅ មាឃបូជា វិសាខបូជារបស់បណ្ណាគារសុមនសុវត្ថិផល ។

www.elibraryofcambodia.org

នមស្សាម ។ ព្រះធម៌ណា ដែលព្រះភគវន្តមុនីអង្គនោះ ទ្រង់ត្រាស់សំដែងហើយដោយប្រពៃ ដើម្បីកំចាត់បង់ នូវសេចក្តីទុក្ខទាំងពួង, ព្រះធម៌នោះ ជាធម៌ស្រោចស្រង់សត្វពិតមែន, យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំនូវព្រះធម៌នោះ ដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

សុប្បដិបន្នោ វតស្ស ភគវតោ សោ សាវកសង្ឃោ យោ សព្វទុក្ខស្ស បហានាយ បដិបន្នោ, តំ សង្ឃំ អានមេន-នមស្សាម ។ ព្រះអរិយសង្ឃណា លោកប្រតិបត្តិ ដើម្បីកំចាត់បង់ នូវសេចក្តីទុក្ខទាំងពួង, ព្រះអរិយសង្ឃនោះ ជាសង្ឃសាវ័ក នៃព្រះភគវន្តមុនីអង្គនោះ លោកប្រតិបត្តិ ដោយប្រពៃពិតមែន, យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំ នូវព្រះអរិយសង្ឃនោះ ដោយគោរព ។

www.elibraryofcambodia.org

(ក្រាបថ្វាយបង្គំម្តង)

ថ្ងៃនេះ ជាតិថីពេញបូណ៌មី នៃខែមាឃ មានព្រះច័ន្ទពេញវង់ ត្រូវនឹងថ្ងៃ នៃសាវកសន្និបាត របស់ព្រះសក្យមុនីអរហន្តសម្មាសម្ពុទ្ធ ជាបរម-គ្រូនៃយើង, សាវកសន្និបាតនោះ ប្រកបដោយអង្គ៤ គឺថ្ងៃពេញបូណ៌មីខែមាឃ ព្រះច័ន្ទបរបូល ក្នុងមាឃនក្ខត្តឫក្ស នេះជាអង្គទី ១, ព្រះភិក្ខុសង្ឃមានចំនួន១.២៥០អង្គ ឥតមានអ្នកណានិមន្ត ឬណាត់វេលាគ្នាសោះឡើយ ក៏ស្រាប់តែមកប្រជុំគ្នា ក្នុងសំណាក់ នៃព្រះបរមសាស្តា នាវត្តវេឡុវ័ន

កលន្ទកនិវាបស្ថាន ក្រុងរាជគ្រឹះ មគធរដ្ឋ នៅវេលាថ្ងៃល្ងាច នេះជាអង្គទី ២, ព្រះភិក្ខុសង្ឃ ទាំង ១.២៥០ អង្គនោះ សុទ្ធតែជាឯហិភិក្ខុ ដូចគ្នាទាំងអស់ នេះជាអង្គទី ៣, ព្រះភិក្ខុសង្ឃ ទាំង ១.២៥០ អង្គនោះ សុទ្ធតែជាខី-ណាស្រពទាំងអស់ នេះជាអង្គទី ៤ ។ ព្រះសព្វញ្ញុពុទ្ធ ទ្រង់ត្រាស់សំដែងនូវឱវាទបាតិមោក្ខ ក្នុងទីប្រជុំ នៃព្រះភិក្ខុសង្ឃនោះ ។ ការប្រជុំបរិកបែបនេះ ហៅថា "ចតុរង្គសន្និបាត" គឺការប្រជុំប្រកបដោយអង្គ ៤ ក្នុងពុទ្ធកាល នៃព្រះសក្យមុនី បរមគ្រូរបស់យើង មានត្រឹមតែម្តងប៉ុណ្ណោះ ។ មួយទៀត កាលដែលព្រះបរមសាស្តានៃយើង ទ្រង់មានព្រះជន្ម បើគិតតាមឈ្មោះខែ នៅខ្វះ ៤ ខែ បើគិតតាមចំនួនថ្ងៃ នៅខ្វះតែ ៨៨ ថ្ងៃទៀត នឹងគ្រប់ ៨០ ឆ្នាំគត់ ព្រះអង្គទ្រង់កំណត់ នូវព្រះជន្មាយុសង្ខារថា "ម្នាលភិក្ខុទាំងឡាយ គិតពីថ្ងៃនេះទៅ នៅខ្វះតែ ៤ ខែទៀតទេ តថាគតនឹងរលត់ខន្ធ ចូលកាន់បរិនិព្វាន" ។ ការកំណត់ព្រះជន្មាយុនេះ នៅថ្ងៃ ១៥ កើត ខែមាឃដែរ ។ តិថីនេះ ជាឧបលក្ខិតសម័យមួយ ដ៏ឧត្តមក្នុងព្រះពុទ្ធសាសនា គឺជាថ្ងៃ សម្រាប់ពុទ្ធមាមកជន ទាំងបព្វជិត ទាំងគ្រហស្ថ ប្រជុំគ្នាធ្វើសក្ការបូជា ចំពោះព្រះសម្មាសម្ពុទ្ធ អង្គនោះ ព្រមទាំងព្រះធម៌ ជាបរមពុទ្ធោវាទ និងព្រះអរិយសង្ឃ ជាសាវ័ករបស់ព្រះអង្គ ។

ឥឡូវនេះ យើងទាំងអស់គ្នា ជាពុទ្ធសាសនិកជន បានមកប្រជុំគ្នា បានរៀបគ្រឿងសក្ការបូជា មានទៀនធូបនិងផ្កាជាដើម ក្នុងទីនេះ ដែល

មានព្រះពុទ្ធរូបស្នងព្រះអង្គ(១) គង់ជាប្រធាន ហាក់ដូចជា ព្រះបរមសាស្តាអង្គនោះ ទ្រង់ស្តេចមកគង់ ក្នុងទីចំពោះមុខ នៃយើងទាំងអស់គ្នា, យើងខ្ញុំសូមថ្វាយ នូវសក្ការបូជាទាំងនេះ ចំពោះព្រះសម្មាសម្ពុទ្ធ ព្រះអង្គនោះ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ រត្នត្រ័យទាំង ៣ ដោយសេចក្តីគោរព ។

បពិត្រព្រះសក្យមុនីបរមគ្រូ ព្រះអង្គជាបូជារហបុគ្គល របស់ទេវតានិងមនុស្សក្នុងលោក ឥតមានបុគ្គលណាមួយ ត្រឹមស្មើនឹងព្រះអង្គឡើយ ទោះបីព្រះអង្គ ទ្រង់ចូលបរិនិព្វាន បាត់ព្រះរូបព្រះកាយ អស់កាលយូរអង្វែងទៅហើយ ក៏ពិតមែន ប៉ុន្តែទ្រង់បានប្រតិស្ឋាន ព្រះវិសុទ្ធោវាទ គឺព្រះធម៌វិន័យ ដ៏បរិសុទ្ធវិសេស ទុកជាតំណាងព្រះអង្គ ទាំងព្រះគុណរបស់ព្រះអង្គ ក៏នៅមានប្រាកដ ទាំងព្រះសារីរិកធាតុ និងព្រះពុទ្ធរូបស្នងព្រះអង្គ ក៏នៅមានប្រាកដដែរ, សូមព្រះដ៏មានបុណ្យជាបរមសាស្តា ទ្រង់ព្រះមេត្តាទទួល នូវគ្រឿងសក្ការបូជា របស់យើងខ្ញុំព្រះអង្គ ដែលរៀបចំថ្វាយក្នុងទីនេះ ដើម្បីជាផលានិសង្ស ឲ្យយើងខ្ញុំព្រះអង្គ បានប្រកប ដោយឥដ្ឋមនុញ្ញផល វិបុលសុខ និងសេចក្តីចំរើនដ៏ធំទូលាយ អស់កាលជាអង្វែងទៅហោង ។

(ក្រាបថ្វាយបង្គំ ៣ ដង)

លុះចប់ពិធីប្រកាសមាឃបូជានេះហើយ ព្រះសង្ឃទាំងអស់សូត្រមេស្ការតាមត្រៃប្រណាម និង

---

១ ត្រង់ចន្លោះនេះបើមានព្រះសារីរិកធាតុត្រូវបញ្ចូលពាក្យថា "និងព្រះសារីរិកធាតុ" ផង ។

www.elibraryofcambodia.org

ធម៌សម្រាប់នមស្ការផ្សេង ៗ ទៀត ដែលអាចសូត្រប្រប់អង្គបាន ស្រេចហើយសូមឱ្យភិក្ខុ ឬសាមណេរពីរ ។ អង្គសូត្រជាបទខ្លីនមស្ការគាថាចប់ ហើយទេសនាតទៅ ។

x x x

## វិសាខបូជា

មុននឹងប្រកាសវិសាខបូជា សូមលោកអាចារ្យនាំឧបាសក-សិកា នមស្ការព្រះរតនត្រ័យ ហើយសុំសីល ៨ រួចសឹមប្រកាសវិសាខបូជា អានមួយសង្កាត់ម្ដង ៗ ឥ ប្រមូលតាមឃ្លាល្បះ ឱ្យពុទ្ធមាមកជនទាំងអស់ថាតាម ឱ្យព្រម ៗ គ្នា ដូចតទៅនេះ :

## វិធីប្រកាសវិសាខបូជា

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការ ចំពោះព្រះភគវន្តមុនី អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ៗ

សម្មាសម្ពុទ្ធោ [illegible] ក, យោ សត្ថុកិច្ចស្ស

បកាសយំ ធម្មំ ទេសេតិ, តំ សម្មាសម្ពុទ្ធំ អភិវន្ទេ

នមស្សាមិ ៗ ព្រះភគវន្តមុនីអង្គណា ទ្រង់ត្រាប់សម្ដែងនូវធម៌ ដើម្បីកំ-ចាត់បង់ នូវសេចក្ដីទុក្ខទាំងពួង, ព្រះភគវន្តមុនីអង្គនោះ ជាព្រះសម្មាសម្ពុទ្ធពិតមែន, យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធអង្គនោះ ដោយគោរព ៗ

(ក្រាបថ្វាយបង្គំម្ដង)

និយ្យានិកោ វត សោ ធម្មោ, យោ សត្ថុកិច្ចស្ស

បកាសយំ ស្វាក្ខាតោ តេន ភគវតា, តំ ធម្មំ អភិវន្ទេ

នមស្សាមិ ៗ ព្រះធម៌ណា ដែលព្រះភគវន្តមុនីអង្គនោះ ទ្រង់ត្រាស់សំ-ដែងហើយដោយប្រពៃ ដើម្បីកំចាត់បង់ នូវសេចក្ដីទុក្ខទាំងពួង ព្រះធម៌

www.elibraryofcambodia.org

នោះ ជាធម៌ស្រោចស្រង់សត្វពិតមែន, យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំ នូវព្រះធម៌នោះ ដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ, យោ សព្វទុក្ខស្ស បហានាយ បដិបន្នោ, តំ សង្ឃំ អាទរេន នមស្សាម ។ ព្រះអរិយសង្ឃណា លោកប្រតិបត្តិ ដើម្បី កំចាត់បង់ នូវសេចក្តីទុក្ខទាំងពួង, ព្រះអរិយសង្ឃនោះ ជាសង្ឃសាវក នៃព្រះភគវន្តមុនីអង្គនោះ លោកប្រតិបត្តិ ដោយប្រពៃពិតមែន, យើងខ្ញុំព្រះអង្គសូមថ្វាយបង្គំ នូវព្រះអរិយសង្ឃនោះ ដោយគោរព ។

www.elibraryofcambodia.org

(ក្រាបថ្វាយបង្គំម្តង)

ថ្ងៃនេះ ជាតិថីពេញបូណ៌មី នៃខែពិសាខ មានព្រះបន្ទូរពេញវង់ ត្រូវនឹងថ្ងៃ ដែលព្រះសក្យមុនី សម្មាសម្ពុទ្ធ ជាបរមគ្រូ ទ្រង់ប្រសូត ទ្រង់បានត្រាស់ ជាព្រះសព្វញ្ញុពុទ្ធ ប្រាកដឡើងក្នុងលោក និងថ្ងៃដែលទ្រង់រលត់ខ័ន្ធ ចូលកាន់បរិនិព្វាន, តិថីនេះ ជាឧបលក្ខិតសម័យមួយ ដ៏ឧត្តម ក្នុងព្រះពុទ្ធសាសនា គឺជាថ្ងៃសម្រាប់ពុទ្ធមាមកជន ទាំងបព្វជិត ទាំងគ្រ-ហស្ថ ប្រជុំគ្នាធ្វើសក្ការបូជា ចំពោះព្រះសម្មាសម្ពុទ្ធព្រះអង្គនោះ ព្រមទាំងព្រះធម៌ បរមពុទ្ធោវាទ និងព្រះអរិយសង្ឃ ជាសាវករបស់ព្រះអង្គ, ឥឡូវនេះ យើងទាំងអស់គ្នា ជាពុទ្ធសាសនិកជន បានមកប្រជុំគ្នា បានរៀប

គ្រឿងសក្ការបូជា មានទៀនធូបនិងផ្កាជាដើម ក្នុងទីនេះ ដែលមានព្រះពុទ្ធរូបស្នងព្រះអង្គ(១) គង់ជាប្រធាន ហាក់ដូចជា ព្រះបរមសាស្ដាអង្គនោះ ទ្រង់ស្ដេចមកគង់ ក្នុងទីចំពោះមុខ នៃយើងទាំងអស់គ្នា, យើងខ្ញុំសូមថ្វាយនូវគ្រឿងសក្ការបូជាទាំងនេះ ចំពោះព្រះសម្មាសម្ពុទ្ធព្រះអង្គនោះ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ រតនត្រ័យទាំង ៣ ដោយសេចក្ដីគោរព ។

បពិត្រព្រះសក្យមុនីបរមគ្រូ ព្រះអង្គជាបូជារហបុគ្គល របស់ទេវតា និងមនុស្សក្នុងលោក ឥតមានបុគ្គលណាមួយ ស្មើនឹងព្រះអង្គឡើយ ទោះបីព្រះអង្គ ទ្រង់ចូលបរិនិព្វាន បាត់ព្រះរូបព្រះកាយ អស់កាលយូរ អន្តរធានទៅហើយ ក៏គង់តែមាន ពុទ្ធ[illegible]ប្រតិស្ឋាន ព្រះវិសុទ្ធោវាទ គឺ ព្រះធម៌វិន័យ ដ៏បរិសុទ្ធវិសេស ទុកជាតំណាងព្រះអង្គ ទាំងព្រះគុណរបស់ព្រះអង្គ ក៏នៅមានប្រាកដ ទាំងព្រះបរមសារីរិកធាតុ និងព្រះពុទ្ធរូបស្នងព្រះអង្គ ក៏នៅមានប្រាកដដែរ, សូមព្រះដ៏មានបុណ្យ ជាបរម-សាស្ដា ទ្រង់ព្រះមេត្តាប្រោសទទួល នូវគ្រឿងសក្ការបូជា របស់យើងខ្ញុំព្រះអង្គ ដែលបានរៀបចំថ្វាយក្នុងទីនេះ ដើម្បីជាផលានិសង្ស ឲ្យយើងខ្ញុំព្រះអង្គ បានប្រកប ដោយឥដ្ឋមនុញ្ញផល វិបុលសុខ និងសេចក្ដីចំរើន ដ៏ធំទូលាយ អស់កាលជាអង្វែងទៅហោង ។

(ក្រាបថ្វាយបង្គំគ្នា)

(ចប់វិធីប្រកាសវិសាខបូជា)

---

១ ត្រង់បន្ទោះនេះ បើមានព្រះសារីរិកធាតុ,ត្រូវបញ្ចូលពាក្យថា “និងព្រះសារីរិកធាតុ” ផង ។

តពីនេះទៅ ព្រះសង្ឃសូត្រនមស្ការតាមវិធីត្រៃប្រណាម និងធម៌សម្រាប់នមស្ការផ្សេងៗទៀតដែលអាចសូត្រគ្រប់អង្គបាន ហើយភិក្ខុ ឬសាមណេរពីរៗអង្គ សូត្រជាបទនូវនមក្ការគាថា ដូចតទៅខាងមុខនេះ, ធម្មកថិកសម្ដែងធម៌ចប់ហើយ ត្រូវសូត្រធម៌បទផ្សេងៗ តាមសៀវភៅគោតមប្រវត្តិជាដើមឲ្យរហូតទើសក្ដីទៅ ៖

យោ កប្បកោដីហិ បិ អប្បមេយ្យំ
កាលំ ករោន្តោ អតិទុក្ករានិ
ខេទំ គតោ លោកហិតាយ នាថោ
នមោ មហាការុណិកស្ស តស្ស ។

www.elibraryofcambodia.org

ព្រះមានជោគណាបាន    យាងចេញក្ដានធ្វើទុក្ករ
អស់កាលអប្បមេយ្យា    រាប់សែនកោដិកប្បច្រើនក្ដាត់ ។
លំបាកព្រះកាយា    ព្រោះប្រាថ្នាប្រយោជន៍សត្វ
ខ្ញុំសូមវន្ទាថ្វាត់    ទ្រង់មានមហាករុណានោះ ។

អសម្ពុធំ ពុទ្ធនិសេវិតំ យំ
ភវាភវំ គច្ឆតិ ជីវលោកោ
នមោ អវិជ្ជាទិកិលេសជាលំ
វិទ្ធំសិនោ ធម្មវរស្ស តស្ស ។

ជីវលោកអន្ទោលសត្វ    វិលកន្លងភពអភព
ព្រោះមិនដឹងធម៌ណា    ដែលពុទ្ធបានស្មោះស្ម័គ្រ ។

ខ្ញុំសូមក្រាបប្រណម្យ ធម៌ឧត្តមដែលបំបាក់
បណ្ដាញកិលេសធ្ងាក់ មានអវិជ្ជាជាដើមនោះ ។

គុណេហិ យោ សីលសមាធិបញ្ញា
វិមុត្តិញាណប្បភុតីហិ យុត្តោ
ខេត្តញ្ជនានំ កុសលត្ថិកានំ
តមរិយសង្ឃំ សិរសា នមាមិ ។

ព្រះអរិយសង្ឃណា គបសីលាសមាធិ
បញ្ញាវិមុត្តិ វិមុត្តិញាណជាអាទិ៍ ។
www.elibraryofcambodia.org
ជាស្រែបុណ្យដ៏ថ្លា អ្នកប្រាថ្នាកុសលស្អាត
ខ្ញុំសូមអភិវាទ ព្រះអរិយសង្ឃនោះដោយត្បូង ។

ឥច្ចេវមច្ចន្ត- នមនស្សនេយ្យំ
នមស្សមានោ រតនត្តយំ យំ
បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ
តស្សានុភាវេន ហតន្តរាយោ ។

យើងខ្ញុំសូមវន្ទា លើកហត្ថាទូនសិរសី
បង្គំកែវទាំងបី ខ្ពស់ឥតអ្វីនឹងពណ៌នា ។
សូមបុណ្យគង់កុសល ចូរមានដល់យើងរាល់គ្នា
ពេញពោរដូចផលសា មានលាភធំទូលាយ ។

សូមឲ្យកំចាត់បង់ អពមង្គលទាំងឡាយ
ឲ្យចៀសចេញចាកឆ្ងាយ ក្ដីអន្តរាយកុំបីមាន ។
ដោយពុទ្ធានុភាព បុញ្ញលាភជាប្រធាន
កងបុណ្យរាសីមាន សូមបានក្សាន្តកុំមានមោះ ។
ដោយគុណនមស្ការ ធំអស្ចារ្យដោយចិត្តស្មោះ
សូមអានិសង្សនោះ ជួយដាក់ដល់និព្វានហោង ។

មហានាគនមស្ការគាថា

“គាថានមស្ការចំពោះព្រះមហានាគ”

សេដ្ឋោ តថាគតោ លោកេ ពុទ្ធនាគោតិ វិស្សុតោ
www.elibraryofcambodia.org
នាគេន ទេសិតោ ធម្មោ និយ្យានិកោតិ សញ្ញតោ
តស្សាបិ សាវកោ សង្ឃោ សន្តិន្ទ្រិយោ អនាសវោ
នាគាវិ ធាបតំ រក្ខុំ តស្មា នាគោតិ វុច្ចរេ ។
វន្ទេហំ ពុទ្ធនាគញ្ច ធម្មំ នាគេន ទេសិតំ
នាគសាវិយសង្ឃញ្ច មហានាគន្តិ វិស្សុតំ ។
ពុទ្ធនាគានិតេជេន ឧប្បន្នា ចេ ឧបទ្ទវា
ភោគា ចេវត្តភយា ច វិនស្សន្តុ អសេសតោ ។

x x x

អដ្ឋវីសសម្ពុទ្ធនមស្ការគាថា

“គាថានមស្ការចំពោះព្រះសម្ពុទ្ធ ២៨ ព្រះអង្គ”

វន្ទេ តណ្ហង្ករំ ពុទ្ធំ  វន្ទេ មេធង្ករំ មុនឹ
សរណង្ករំ មុនឹ វន្ទេ  ទីបង្ករំ ជិនំ នមេ
វន្ទេ កោណ្ឌញ្ញសត្ថារំ  វន្ទេ មង្គលនាយកំ
វន្ទេ សុមនសម្ពុទ្ធំ  វន្ទេ រេវតនាយកំ
វន្ទេ សោភិតសម្ពុទ្ធំ  អនោមទស្សឹ មុនឹ នមេ
វន្ទេ បទុមសម្ពុទ្ធំ  វន្ទេ នារទនាយកំ
បទុមុត្តរំ មុនឹ វន្ទេ  វន្ទេ សុមេធនាយកំ
វន្ទេ សុជាតសម្ពុទ្ធំ  បិយទស្សឹ មុនឹ នមេ
អត្ថទស្សឹ មុនឹ វន្ទេ  ធម្មទស្សឹ ជិនំ នមេ
www.elibraryofcambodia.org
វន្ទេ សិទ្ធត្ថសត្ថារំ  វន្ទេ តិស្សមហាមុនឹ
វន្ទេ ផុស្សមហាវីរំ  វន្ទេ វិបស្សិនាយកំ
សិខឹ មហាមុនឹ វន្ទេ  វន្ទេ វេស្សភុនាយកំ
កកុសន្ធំ មុនឹ វន្ទេ  វន្ទេ កោនាគមនំ ជិនំ
កស្សបំ សុគតំ វន្ទេ  វន្ទេ គោតមនាយកំ
អដ្ឋវីសតិមេ ពុទ្ធា  និព្វានមតទាយកា
នមេ តេ សិរសា និច្ចំ  តេ មំ រក្ខន្តុ សព្វទា ។

x x x

ពុទ្ធាននមក្ការគាថា

"គាថានមស្ការចំពោះព្រះពុទ្ធបាទ"

វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ
តិលោកកេតុំ តិភវេកនាថំ
យោ លោកសេដ្ឋោ សកលំ កិលេសំ
ឆេត្វាន ពោធេសិ ជនំ អនន្តំ ។
យំ នម្មទាយ នទិយា បុលិនេ ច តីរេ
យំ សច្ចពន្ធគិរិកេ សុមនាចលគ្គេ
យំ តត្ថ យោនកបុរេ មុនិនោ ច បាទំ
តំ បាទលញ្ឆនមហំ សិរសា នមាមិ ។
សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ
www.elibraryofcambodia.org
យោនកបុរេ នម្មទាយ នទិយា
បញ្ចបាទវរំ ឋានំ អហំ វន្ទាមិ ទូរតោ ។

x x x

ធាតុចេតិយនមក្ការគាថា

“គាថានមស្ការចំពោះព្រះធាតុចេតិយ”

មហាគោតមសម្ពុទ្ធោ    កុសិនារាយ និព្វុតោ
ធាតុវិត្ថារតំ កត្វា    តេសុ តេសុ វិសេសតោ
ឧណ្ហីសំ ចតស្សោ ទាឋា    អក្ខកា ទ្វេ ច សត្តមា
អសម្ភិន្នា វតា សត្ត    សេសា ភិន្នា វ ធាតុយោ ។
មហន្តា បញ្ចនាឡិ ច    មជ្ឈិមា ច ឆ នាឡិយោ

ខុទ្ទកា បញ្ចនាឡិ ច សម្ភិន្នា តិវិធា មតា ។
មហន្តា ភិន្នមុគ្គា ច មជ្ឈិមា ភិន្នតណ្ឌុលា
ខុទ្ទកា សាសបមត្តា ឯវំ ធាតុប្បមាណិកា ។
មហន្តា សុវណ្ណវណ្ណា មជ្ឈិមា ផលិកប្បភា
ខុទ្ទកា ពកុលវណ្ណា តាបិ វន្ទាមិ ធាតុយោ ។
ឯកោ ថូបោ រាជគហេ ឯកោ វេសាលិយា អហុ
ឯកោ កបិលវត្ថុស្មឹ ឯកោ ច អលកប្បកេ
ឯកោ ច រាមគាមស្មឹ ឯកោ ច វេដ្ឋទីបកេ
ឯកោ បាវេយ្យកេ មល្លេ ឯកោ ច កុសិនារកេ
www.elibraryofcambodia.org
ឯតេ សារីរិកា ថូបា ជម្ពុទីបេ បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ ។
ឯកា ទាឋា តិទសបុរេ ឯកា នាគបុរេ អហុ
ឯកា គន្ធារវិសយេ ឯកា សីហឡទីបកេ
ឥមា ចតូសុ ឋានេសុ សត្តុ ទាឋា បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ ។
ឧទ្ធំ ទក្ខិណទាឋា ច តាវត្តឹសេ បតិដ្ឋិតា
អធោ ទក្ខិណទាឋា ច សីហឡទីបេ បតិដ្ឋិតា
វាមទាឋា ច ឧទ្ធម្បិ គន្ធាររដ្ឋេ បតិដ្ឋិតា
វាមទាឋា ច អធោបិ នាគលោកេ បតិដ្ឋិតា

បូជិតា នរទេវេហិ  អហំ វន្ទាមិ ធាតុយោ ។
ព្រហ្មលោកេ ទុស្សធាតុ  ភមអក្ខកធាតុយោ
សព្វេ ព្រហ្មាភិបូជេន្តិ  ថូបំ ទ្វាទសយោជនំ
តាវត្តឹសម្ហិ ទេវានំ  ចូឡាមណិម្ហិ កេសកំ
សព្វេ ទេវាភិបូជេន្តិ  បសន្នា ពុទ្ធសាសនេ
បូជិតា នរទេវេហិ  អហំ វន្ទាមិ ធាតុយោ ។
ចត្តាឡីសសមា ទន្តា  កេសា លោមា នខាបិច
ទេវា ហរន្តិ ឯកេកំ  ចក្កវាឡបរម្បរា
បូជិតា នរទេវេហិ  អហំ វន្ទាមិ ធាតុយោ ។
www.elibraryofcambodia.org
អដ្ឋារស ទ្វេ វស្សសតេ  ធម្មាសោកោ តទា អហុ
ចតុរាសីតិសហស្ស  ចេតិយោ ច ការាបិតា
បូជិតា នរទេវេហិ  អហំ វន្ទាមិ ធាតុយោ ។

—=*=—

## វគ្គទី ៩

## ការនិងតំណែងសក្តិ ព្រះសង្ឃនាយក

## និងព្រះរាជាគណៈ

*ព្រះរាជក្រមលេខ ១ P. R. ចុះថ្ងៃ ២៦ មេ ១៩៤៨*

*ការព្រះរាជាគណៈសង្ឃក្នុងព្រះរាជាណាចក្រកម្ពុជា*

# គណៈមហានិកាយ

## ព្រះសង្ឃនាយក

ព្រះមហាសុមេធាធិបតី សង្ឃនាយក

(ព្រះរាជាគណៈចែកជា ៤ ពួកដូចមានខាងក្រោមនេះ)

### រាជាគណៈទី ១ មាន ៣ រូប

១– ព្រះធម្មលិខិត, ២ ព្រះពោធិវង្ស, ៣– ព្រះវនរ័តន៍ ។

### រាជាគណៈទី ២ មាន ៦ រូប

១- ព្រះមហាវិមលធម្ម, –ព្រះពុទ្ធឃោសាចារ្យ, ៣– ព្រះធម្មឃោសាចារ្យ, ៤– ព្រះឃោសធម្ម, ៥– ព្រះសាសនមុនី ៦– ព្រះមុនីកោសល ។

www.elibraryofcambodia.org

### រាជាគណៈទី ៣ មាន ៦ រូប

១– ព្រះសិរីសម្មតិវង្ស, ២– ព្រះពុទ្ធវង្ស, ៣– ព្រះសាក្យវង្ស, ៤– ព្រះឧបាលិវង្ស, ៥– ព្រះញាណវង្ស, ៦– ព្រះសុមេធវង្ស, ។

### រាជាគណៈទី ៤ មាន ២០ រូប

១-ព្រះសមាធិធម្ម, ២-ព្រះសិរីសង្គាមមុនី, ៣– ព្រះវិកុញ្ញាណ, ៤–ព្រះធម្មវង្ស, ៥ព្រះគម្ពីរត្ថេរ, ៦–ព្រះឥន្ទមុនី, ៧-ព្រះធម្មវិបស្សនា, ៨–ព្រះសិរីវិសុទ្ធិ, ៩–ព្រះទេពមុនី, ១០– ព្រះទេពសត្ថា, ១១-ព្រះញាណសំវរ, ១២–ព្រះវិន័យសំវរ, ១៣ ព្រះញាណកោសល, ១៤–ព្រះអរិយមគ្គញ្ញាណ, ១៥–ព្រះញាណវិសុទ្ធិវង្ស, ១៦– ព្រះ

ធម្មវិសុទ្ធិវង្ស, ១៧– ព្រះបិដកធម្ម, ១៨ ព្រះវិន័យមុនី, ១៩– ព្រះសីលសំវរ ២០– ព្រះបវរសត្ថា ។

គណៈធម្មយុត្តិ

ព្រះសង្ឃនាយក

ព្រះសុធម្មាធិបតី សង្ឃនាយក

(ព្រះរាជាគណៈចែកជា៤ពួកដូចមានខាងក្រោមនេះ)

រាជាគណៈទី ១ មាន២រូប

១–ព្រះមង្គលទេព្វាចារ្យ, ២ ព្រះពុទ្ធាចារ្យ

រាជាគណៈទី២ មាន ៣ រូប

www.elibraryofcambodia.org

១–ព្រះមហាព្រហ្មមុនី ២ ព្រះធម្មឧត្តម, ៣–ព្រះអរិយកស្សប ។

រាជាគណៈទី៣ មាន៤ រូប

១–ព្រះអរិយវង្ស, ២ ព្រះញាណវង្ស, ៣–ព្រះធម្មកវីវង្ស, ៤–ព្រះមហាវិរវង្សាចារ្យ ។

រាជាគណៈទី៤ មាន១២រូប

១–ព្រះបទុមវង្សា, ២ ព្រះធម្មមុនី, ៣–ព្រះវជិរមេធា, ៤–ព្រះអរិយមុនី, ៥–ព្រះទេព្វមោលី, ៦ ព្រះធម្មត្ថេរ, ៧– ព្រះអមរាភិរក្ខិត, ៨– ព្រះមហារាជធម្ម, ៩– ព្រះរតនមុនី, ១០– ព្រះធម្មត្រៃលោកាចារ្យ, ១១– ព្រះធម្មវរោត្តម, ១២– ព្រះញាណវីរិយៈ ។

# ឈ្មោះនិងតម្លៃសៀវភៅរបស់បណ្ណាគារសុមនសុវត្ថិ

### លេខ ៤២ វិថីសម្តេច កែវ-ជា ភ្នំពេញ

### ផ្នែកសាលាពុទ្ធិកបឋមសិក្សានិងមធ្យមសិក្សា

| | ឈ្មោះសៀវភៅ | នាមអ្នកនិពន្ធ | | តម្លៃ |
|---|---|---|---|---|
| ១ | វេយ្យាករណ៍បាលី | បណ្ឌិតមហា | ឈឹម-ស៊ុម | ៣០៛០០ |
| ២ | វិធីសម្ពន្ធសង្ខេប | ” | ” | ២០៛០០ |
| ៣ | ឧភយពាក្យវិញាសិនី ភាគទី ១ | ” | ” | ២៣៛០០ |
| ៤ | ឧភយពាក្យវិញាសិនី ភាគទី ២ | ” | ” | ២៣៛០០ |
| ៥ | ពុទ្ធប្បវត្តិកថា (ប្រវត្តិទី ១ នៃពុទ្ធសាសនា) | ” | ” | ២៥៛០០ |
| ៦ | ជាតកធម្មបទ (គំរូការតែងរឿង) | ” | ” | ២៧៛០០ |
| ៧ | អធិប្បាយគាថាធម្មបទភាគទី ១ | ” | ” | ២៣៛០០ |
| ៨ | អធិប្បាយគាថាធម្មបទភាគទី ២ | ” | ” | ២៣៛០០ |
| ៩ | អធិប្បាយគាថាធម្មបទភាគទី ៣ | ” | ” | ២៣៛០០ |
| ១០ | អធិប្បាយគាថាធម្មបទភាគទី ៤ | ” | ” | |
| ១១ | គាថាធម្មបទបាលីប្រែពន្យល់វេយ្យាករណ៍ | ” | សោក-កាឡូ | ២៥៛០០ |
| ១២ | ប្រស្នាវិន័យភាគទី ១ | ព្រះវិន័យធរ | ឯក-ញឹម | ២៥៛០០ |
| ១៣ | ប្រស្នាវិន័យភាគទី ២ | បណ្ឌិតមហា | ឈឹម-ស៊ុម | ២៥៛០០ |
| ១៤ | ប្រស្នាវិន័យភាគទី ៣ | ” | ឈឹម-ស៊ុម | |
| ១៥ | ប្រស្នាវិន័យភាគទី ៤ | ” | ” | |
| ១៦ | ភិក្ខុប្បាតិមោក្ខបាលី-ប្រែ | ព្រះគ្រូសង្ឃសត្ថា | ប៊ុណ្យ-សុវណ្ណជ | ៥៥៛០០ |
| ១៧ | សីលវិនិច្ឆ័យ | ព្រះគ្រូសិរីសោភ័ណ | កិម-គួ | ១២៛០០ |
| ១៨ | អភិធម្មត្ថាធិប្បាយ | សម្តេចព្រះធម្មលិខិត | ស៊ូ-ឯម | ៥០៛០០ |

### ផ្នែកសាលារៀនទូទៅ

| | | | | |
|---|---|---|---|---|
| ១៩ | សង្ខេបទសជាតក សម្រាប់ថ្នាក់ទី ២ ទំនើប | បណ្ឌិតមហា | ឈឹម-ស៊ុម | ៥៥៛០០ |
| ២០ | វិបនប្រទីប (ក្បួនរៀនពាក្យ ពន្យល់វិធីអានពាក្យ) | | សុង-ស៊ីវ | ២០៛០០ |

www.elibraryofcambodia.org

២១ ចរិយាសាស្ត្រ (ធម្មត្រានសម្រាប់គ្រប់ថ្នាក់) មាស-រឿង, ឈឹម-ស៊ុម ៥៥៛០០

២២ លោកនីតិសាស្ត្រ (របៀបរាជការ សម្រាប់គ្រប់ថ្នាក់) មាស-រឿង ២៧៛០០

២៣ វិត្តស្វាធ្យាយន៍និងអនាម័យសម្រាប់ថ្នាក់ប្រថមភូមិបំពេញវិជ្ជា មាស-រឿង ៥៣៛០០

២៤ រឿងសម្រាំង ការអាន ការសរសេរតាមសូត្រ ការពន្យល់ពាក្យ ឈឹម-ស៊ុម

២៥ សីលធម៌របស់មនុស្ស ព្រះឧបាលិវង្ស ស្វ-ហាយ ១០៛០០

ផ្នែកបកិណ្ណកៈ

២៦ សរណគមនកថា (បែបទេសនា) លោកគ្រូអាចារ្យ សោក ២០៛០០

២៧ វិន័យវិនិច្ឆ័យ សម្ដេចព្រះធម្មលិខិត ល្វី-ឯម ១៧៛០០

២៨ សង្ឃការណីយកិច្ច (គំរូលិខិតផ្ទៃការខាងពុទ្ធចក្រនិងអាណាចក្រ) ភិក្ខុមាស-រឿង ៣២៛០០

២៩ ទសជាតកសង្ខេប (បែបទេសនា) ព្រះគ្រូ អ៊ុំ-ពៅ ៣០៛០០

៣០ ទេវតាភាសិតនិងពុទ្ធភាសិត (គាថាប្រែ) ព្រះគ្រូធម្មបណ្ឌិត គង់-ស៊ុម ៧៛០០

៣១ កម្មបថកថា នានានិទាន (អាគារវិន័យ) បណ្ឌិតមហា ឈឹម-ស៊ុម ២៥៛០០

៣២ ទសានុស្សតិនឹងព្រះត្រៃលក្ខណ៍ ,, ១០៛០០

៣៣ ធៀបពុទ្ធសាសនានិងគ្រិស្តសាសនា ព្រះឧបាលិវង្ស ស្វ-ហាយ ៦៛០០

៣៤ វិជ្ជាគុណកថា (ពាក្យកាព្យ) បណ្ឌិតមហា ឈឹម-ស៊ុម ៦៛០០

៣៥ គោតមប្រវត្តិ (ពាក្យកាព្យ) ,, ,, ១៥៛០០

៣៦ កាព្យលោកធម៌ សម្ដេចព្រះមហាសុមេធាធិបតី ជួន-ណាត ៣៛០០

៣៧ បទសរភញ្ញ (ពហ្វ, បរា, យស្សបាទេ, ពាហ៊ុំ) និពន្ធបម្រុះ ១០៛០០

៣៨ ភាណវារបាលី ភាគទី ១ (សត្តបរិត្ត) ៧៛០០

៣៩ ,, ភាគទី ២ (ទ្វាទសបរិត្ត) ៩៛០០

៤០ ,, ភាគទី ៨ (ធម៌ជារ) ៧៛០០

៤១ ,, ភាគទី ៧ (មហាសតិបដ្ឋាន) ១៣៛០០

៤២ ភាណវារបាលី-ប្រែ (ធម៌ជារ) ព្រះសាសនមុនី កឹម-ទូ

៤៣ អប្បមាទកថា (បែបអធិប្បាយធម៌ទេសនា) ព្រះគ្រូធម្មបណ្ឌិត គង់-ស៊ុម ១០៛០០

៤៤ តិលក្ខណកថា (របៀបទេសនា) ព្រះមហា ធូរ-សុខ ១០៛០០

៤៥ ពហុការធម្មកថា (របៀបទេសនា) សាស្ត្រាចារ្យ ឈឹម-ស៊ុម ១៣៛០០

៤៦ ធម្មាធម្មកថា (របៀបទេសនា) ,, ឈឹម-ស៊ុម ១០៛០០

www.elibraryofcambodia.org

# សន្លឹកប្រាប់ពាក្យខុស-ត្រូវសៀវភៅសង្ឃករណីយកិច្ច

(សូមកែពាក្យខុសឱ្យត្រូវសិនសឹមប្រើប្រាស់)

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ឲ្យយ៉ាខ្ទីង | ឲ្យយ៉ាងខ្ទី | ៦៦ | ១៣ |
| សូព្រាធម៌ | សូត្រធម៌ | ១០១ | ១ |
| ព្រះមរមរាជបិតា | ព្រះបរមរាជបិតា | ១០៤ | ៤ |
| ឆ័ត្រ ឬក្លប់ | ឆ័ត្រ ឬក្លស់ | ១០៨ | ៤ |
| វត្តដោញ្ញាណ | វត្តដោតញ្ញាណ | ១០៨ | ១៧ |
| គឺព្រះបាទធតរដ្ឋ | គឺព្រះបាទធតរដ្ឋ | ១០៩ | ៦ |
| សូមគេជ: | សូមគេជះ | ១១០ | ១០ |
| ឆាសឈាបិណ្ឌោ | ឆាសាឈាបិណ្ឌោ | ១១៣ | ១០ |
| រាល់កាលវេរ | រាល់ការវេរ | ១១៤ | ៥ |
| ជាបិតា សទ្ធិភាពបិតា | ជាបិតាសត្តភាព បិតាកីឡា | ១១៩ | ៩ |
| គ្រឿងបរិក្ខាតាំងតួង | គ្រឿងបរិក្ខារតាំងតួង | ១២២ | ៧ |
| សាមណេរពីរ ។ អង្គ | សាមណេរពីរ ៗ អង្គ | ១៣២ | ២ |
| ធមសម្បា | ធមស្ពាម | ១៣២ | ១៩ |
| ទ្រង់ប្រសូត | ទ្រង់ប្រសូតិ | ១៣៣ | ១២ |
| ព្រះធជិ. | ព្រះធម៌ | ១៣៤ | ១០ |

www.elibraryofcambodia.org

3/2

www.elibraryofcambodia.org

93 006026 08200693 0060

តម្កល់ទុកតាមច្បាប់លេខ ២៥

[illegible] ១៩៦៩

រោងពុម្ពកំាបូតឌីយ៉ា លេខ ១២៤ វិថីត្រសក់ផ្អែម

១.០០០.

www.elibraryofcambodia.org

www.elibraryofcambodia.org